ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

ភោគ ស៊ីថន

PHOK SITHAN

# ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា
# ករណីសិក្សា៖ ខេត្តសៀមរាប

School Managing Implementation Compares to the Standard of Primary School
A Case study in Siem Reap Province

និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ

ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ភ្នំពេញ ២០១៩

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

ភោគ ស៊ីថន
PHOK SITHAN

# ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា
# ករណីសិក្សា៖ ខេត្តសៀមរាប

School Managing Implementation Compares to the Standard of Primary School
A Case study in Siem Reap Province

និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ
ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត នី រដ្ឋា

ជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩

**ក្រសួងអប់រំ យុវជន និងកីឡា**
Ministry of Education Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**
National Institute of Education

**ភោគ ស៊ីថន**
PHOK SITHAN

# ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា ករណីសិក្សា៖ ខេត្តសៀមរាប

School Managing Implementation Compares to the Standard of Primary School
A Case study in Siem Reap Province

គណៈកម្មការវាយតម្លៃនៃការការពារថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ
ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ
ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

**និក្ខេបបទនេះត្រូវបានវាយតម្លៃដោយ៖**

| | |
|---|---|
| ____________________ ប្រធានគណៈកម្មការ | ____________________ គ្រូវាយតម្លៃទី១ |
| ____________________ គ្រូវាយតម្លៃទី២ | ____________________ គ្រូវាយតម្លៃទី៣ |
| ____________________ សមាជិក | ____________________ សមាជិក |
| ____________________ លេខាកត់ត្រា | |

ឯកភាពដោយ៖

| | |
|---|---|
| **តំណាងក្រសួងអប់រំ យុវជន និងកីឡា** | **នាយកវិទ្យាស្ថានជាតិអប់រំ** |
| **ឯកឧត្តមបណ្ឌិត ជ័យ សារិន** | **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** |

## សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទ **«ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា»** ករណីសិក្សាខេត្តសៀមរាបនេះ សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ឯកទេសវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៅវិទ្យាស្ថានជាតិអប់រំពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថាននេះឬសាកលវិទ្យាល័យណាមួយនៅឡើយ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឬការចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទនេះស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

សៀមរាប ថ្ងៃទី ខែ ឆ្នាំ២០២០

ហត្ថលេខា

**ភោគ ស៊ីថន**

## ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមជាសាស្ត្រាចារ្យដឹកនាំនៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះ សូមបញ្ជាក់ថា បេក្ខជន **ភោគ ស៊ីថន** ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវខាងលើពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

សាស្ត្រាចារ្យដឹកនាំ

**បណ្ឌិត នី រដ្ឋា**

# លិខិតបញ្ជាក់

**បណ្ឌិត នី រដ្ឋា** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា៖**

លោក **តោគ ស៊ីថន** និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ពិតជាបានចុះធ្វើកម្មសិក្សាប្រតិបត្តិនៅសាលាបឋមសិក្សាទាំង១៤មានដូចខាងក្រោម៖

| ល.រ | ឈ្មោះសាលារៀន | ភូមិ | សង្កាត់ | ក្រុង-ខេត្ត |
|---|---|---|---|---|
| ១ | សាលាបឋមសិក្សាខ្នារ | ខ្នារ | ជ្រាវ | សៀមរាប |
| ២ | សាលាបឋមសិក្សាជ្រាវ | ជ្រាវ | ជ្រាវ | សៀមរាប |
| ៣ | សាលាបឋមសិក្សាតាពេជ្រ | ខ្នារ | ជ្រាវ | សៀមរាប |
| ៤ | សាលាបឋមសិក្សាវត្តបូព៌ | វត្តបូព៌ | សាលាកំរើក | សៀមរាប |
| ៥ | សាលាបឋមសិក្សាវត្តស្វាយ | វត្តស្វាយ | សាលាកំរើក | សៀមរាប |
| ៦ | សាលាបឋមសិក្សាវត្តដំណាក់ | វត្តដំណាក់ | សាលាកំរើក | សៀមរាប |
| ៧ | សាលាបឋមសិក្សាមុខនាគ | វាល | គោកចក | សៀមរាប |
| ៨ | សាលាបឋមសិក្សាប្រាសាទគោកចក | វាល | គោកចក | សៀមរាប |
| ៩ | សាលាបឋមសិក្សាហ៊ុនសែនគ្រួស | គ្រួស | ស្វាយដង្គំ | សៀមរាប |
| ១០ | សាលាបឋមសិក្សាកេសរារាម | តាភុល | ស្វាយដង្គំ | សៀមរាប |
| ១១ | សាលាបឋមសិក្សាពោធិ៍លង្កា | ស្លក្រាម | ស្លក្រាម | សៀមរាប |
| ១២ | សាលាបឋមសិក្សាបន្ទាយចាស់ | បន្ទាយចាស់ | ស្លក្រាម | សៀមរាប |
| ១៣ | សាលាបឋមសិក្សាព្រះឥន្ទកោសីយ៍ | ស្លក្រាម | ស្លក្រាម | សៀមរាប |
| ១៤ | សាលាបឋមសិក្សាភូមិថ្នល់ | ថ្នល់ | ស្រង៉ែ | សៀមរាប |

ការចុះប្រមូលទិន្នន័យនេះ គិតចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ដើម្បីបំពេញលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសនាយកសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

សាស្ត្រាចារ្យដឹកនាំ

**បណ្ឌិត នី រដ្ឋា**

# សេចក្ដីថ្លែងអំណរគុណ

ជាដំបូង ខ្ញុំបាទជានិស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ នៃវិទ្យាស្ថានជាតិអប់រំ សូមអរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

-លោកឪពុក **តោគ ស្រី** អ្នកម្ដាយ **លី សុខគីម** ដែលបានផ្ដល់កំណើតដល់កូន និងជួយទំនុកបម្រុងផ្គត់ផ្គង់កូនបានសិក្សាតាំងពីថ្នាក់មត្តេយ្យដល់ថ្នាក់ក្រោយឧត្ដមសិក្សាពិសេសរៀនវគ្គនាយក។

-ឯកឧត្ដម **បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតឱ្យមានវគ្គបណ្ដុះបណ្ដាលនាយកសាលានេះឡើង។

-ឯកឧត្ដម **បណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្ដុះបណ្ដាលវគ្គនាយកសាលា ដើម្បីឱ្យក្លាយជាអ្នកគ្រប់គ្រងអប់រំនៅក្នុងសាលារៀន។

-សាស្ត្រាចារ្យដឹកនាំ**បណ្ឌិត នី រដ្ឋា**បានជួយដឹកនាំនិងណែនាំក្នុងការសរសេរនិក្ខេបបទនេះ។

-គ្រូឧទ្ទេសគ្រប់មុខវិជ្ជានៅវិទ្យាស្ថានជាតិអប់រំបានជួយជ្រោមជ្រែងកិច្ចការស្រាវជ្រាវនេះ។

-មិត្តភក្តិរួមជំនាន់ទី២ទាំងអស់នៃវគ្គនាយកសាលា ដែលបានជួយផ្ដល់យោបល់និងមតិក្នុងការកែលម្អនិក្ខេបបទនេះ។

-លោកប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តសៀមរាប លោកប្រធានការិយាល័យអធិការកិច្ច ដែលបានអនុញ្ញាតច្បាប់សម្រាកដល់ខ្ញុំបាទ ដើម្បីបន្តការសិក្សាវគ្គនាយកសាលា។

-សូមថ្លែងអំណរគុណផងដែរដល់លោកនាយក នាយិកា នាយករង នាយិការង លោកគ្រូ អ្នកគ្រូទាំងអស់នៃ**សាលាបឋមសិក្សាវត្តបូព៌ បឋមវត្តស្វាយ បឋមវត្តដំណាក់ បឋមខ្នារ បឋមជ្រាវ បឋមតាពេជ្រ បឋមមុខនាគ បឋមប្រាសាទគោកចក បឋមហ៊ុនសែនគ្រួស បឋមកេសរារាម បឋមពោធិ៍លង្កា បឋមបន្ទាយចាស់ បឋមព្រះឥន្ទកោសីយ៍ និងបឋមភូមិថ្មល់** ដែលបានអនុញ្ញាតនិងសហការក្នុងការចូលរួមបំពេញកម្រងសំណួរ ធ្វើឱ្យការប្រមូលទិន្នន័យសម្រាប់ការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ សូមគោរពជូនពរលោកអ្នកមានគុណ ឯកឧត្ដម លោក លោកស្រីទាំងអស់ជួបតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

នាយកសាលាជាប្រធានស្ថាប័ននៅក្នុងសាលារៀនសាធារណៈ។ ការងារទាំងឡាយទាំងពួងត្រូវឆ្លងកាត់ការសម្រេចចិត្តនិងធ្វើសុភវិនិច្ឆ័យគ្រប់រឿងដើម្បីកែលម្អនិងរកដំណោះស្រាយធ្វើឱ្យអង្គភាពទទួលបាននូវសុខដុមនីយកម្មគ្រួសារគ្រូបង្រៀន។ ដើម្បីឱ្យសាលារៀនមានប្រសិទ្ធភាពប្រកបដោយគុណភាពអប់រំ ត្រូវដើរទន្ទឹមនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡានិងការយកចិត្តទុកដាក់ពីមជ្ឈដ្ឋានអប់រំទាំង៣មាននាយកនិងបុគ្គលិក សាលារៀននិងគ្រួសារសិស្ស សាលារៀននិងសង្គម។

ការគ្រប់គ្រងសាលារៀននាពេលបច្ចុប្បន្ននេះ ត្រូវធ្វើឡើងទៅតាមស្តង់ដាសាលាបឋមសិក្សា ៩ចំណុច។ ការអនុវត្តការងារនេះរួមមាន(១)វត្ថុបំណងគោលនយោបាយសាលារៀន (២)បំណែងចែកកម្មវិធីនិងការបង្រៀន រៀន (៣)ការងារមាតាបិតាសិស្សនិងសហគមន៍ (៤)សិស្សនិងសេវាជួយសិស្ស (៥)ការដឹកនាំនិងគ្រប់គ្រង (៦)ធនធានមនុស្សនិងរចនាសម្ព័ន្ធគ្រប់គ្រង (៧)កម្មវិធីសិក្សានិងសម្ភារបង្រៀនរៀន (៨)ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន និង(៩)ការគ្រប់គ្រងហិរញ្ញវត្ថុ (ក្រសួងអប់រំ ២០១៧)។

នៅក្នុងការអនុវត្តការគ្រប់គ្រងសាលារៀនបឋមសិក្សាធៀបនឹងស្តង់ដាបឋមសិក្សានេះ អ្នកសិក្សាស្រាវជ្រាវបានចុះប្រមូលទិន្នន័យនៅសាលាបឋមសិក្សាចំនួន១៤ នៅក្នុងក្រុង ខេត្តសៀមរាប មានសាលាបឋមសិក្សាវត្តបូព៌ វត្តស្វាយ វត្តដំណាក់ ខ្នារ ជ្រាវ តាពេជ្រ មុខនាគ ប្រាសាទគោកចក ហ៊ុនសែនគ្រួស កេសរារាម ពោធិ៍លង្កា បន្ទាយចាស់ ព្រះឥន្ទកោសីយ៍ និងភូមិថ្មល់។

សាលាបឋមសិក្សាទាំង១៤មានគ្រូសរុប៦០២នាក់ (ស្រី៤៧៤នាក់) សិស្សសរុប២២២៩៨នាក់ (ស្រី១០៤៩៦នាក់)និងបង្រៀន២វេន។ សាលារៀនមានអគារ៧៧ខ្នង ៣៩៨បន្ទប់និងបន្ទប់រៀន២៩២ គណៈគ្រប់គ្រងសាលារៀន២៦នាក់ (ស្រី៩នាក់) និងគ្រូបង្រៀនសុទ្ធសាធ៤៨២នាក់ (ស្រី៣៩៤នាក់) ហើយគ្រូបង្រៀនថ្នាក់ទី១ដល់ទី៦ចំនួន៤៣៤នាក់ (ស្រី៣៤៦នាក់)។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវបញ្ជាក់ថាការអនុវត្តការងារសាលាបឋមសិក្សាទាំង១៤មិនទាន់បានតាមស្តង់ដារបស់ក្រសួងនៅឡើយ។

ជារួមមក សាលាបឋមសិក្សាទាំង១៤ក្នុងក្រុង ខេត្តសៀមរាបឆ្នាំសិក្សា២០១៨-២០១៩ អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាបានត្រឹម១៥%ប៉ុណ្ណោះ។

ដោយឡែកការគ្រប់គ្រងសាលារៀននៅមានជួបបញ្ហាប្រឈមមួយចំនួនដូចជា ខ្វះខាតអគារសិក្សា បន្ទប់រៀន សួនច្បារ បង្គន់អនាម័យ វិធីសាស្ត្របង្រៀន សៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន សិស្សមិនសូវមករៀន និងសាលាមួយចំនួនតូចគ្មានការសហការពីសហគមន៍ អាជ្ញាធរមូលដ្ឋានក្នុងការជំរុញកូនឱ្យមករៀននិងការកែលម្អអភិវឌ្ឍសាលារៀន។

# មាតិកា

ទំព័រ

សេចក្តីប្រកាសរបស់បេក្ខជន……………………………………………………………………i
លិខិតបញ្ជាក់……………………………………………………………………………ii
សេចក្តីថ្លែងអំណរគុណ……………………………………………………………………iii
មូលន័យសង្ខេប……………………………………………………………………………iv

**ជំពូកទី១៖ សេចក្តីផ្តើម**

១.១-សាវតារ.........................................................................................................១
១.២-បញ្ហានៃការស្រាវជ្រាវ.........................................................................................៨
១.៣-គោលបំណងនៃការស្រាវជ្រាវ................................................................................៩
១.៤-សំណួរស្រាវជ្រាវ...............................................................................................១០
១.៥-សារៈសំខាន់នៃការស្រាវជ្រាវ................................................................................១០
១.៦-វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ..............................................................១០
១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.................................................................................១១

**ជំពូកទី២៖ ការរំលឹកទ្រឹស្តី**

២.១-សេចក្តីផ្តើម.......................................................................................................១២
២.២-និយមន័យពាក្យគន្លឹះ..........................................................................................១២
២.៣-ទ្រឹស្តីពាក់ព័ន្ធ...................................................................................................១៣
    ២.៣.១-ការគ្រប់គ្រងសាលារៀនសតវត្សទី២១..........................................................១៣
    ២.៣.២-ស្វ័យភាពនិងគោលដៅរបស់សាលារៀន.........................................................១៤
២.៤-គោលដៅនិងសមាសភាពទាំង៥នៃការអប់រំ.............................................................១៥
    ក.គោលដៅអប់រំជាតិ………………………………………………………………១៥
    ខ.បញ្ចសុត្តម្ភឬសមាសភាពទាំង៥នៃការអប់រំ……………………………………………១៥
២.៥-ការបំប៉នសមត្ថភាពគណៈគ្រប់គ្រងសាលារៀន........................................................១៥
២.៦-រចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន............................................................................១៦

២.៦.១-បំណែងចែកតួនាទីនិងភារកិច្ចបុគ្គលិកអប់រំ....................................................១៧
ក.តួនាទីនិងភារកិច្ចរបស់នាយកសាលា....................................................១៧
ខ.ភារកិច្ចរបស់នាយករង....................................................១៨
គ.ភារកិច្ចរបស់សិក្ខាបនធារី....................................................១៨
ឃ.គ្រូបន្ទុកថ្នាក់....................................................១៩
ង.ភារកិច្ចរបស់ប្រធានក្រុមបច្ចេកទេស....................................................១៩
២.៦.២-ការគ្រប់គ្រងសាលារៀនរបស់នាយកសាលា....................................................២០
ក.ការងាររដ្ឋបាល....................................................២០
ខ.ការងារបច្ចេកទេស....................................................២៣
គ.ការងារបុគ្គលិក....................................................២៧
ឃ.ការងារហិរញ្ញវត្ថុ....................................................២៩
ង.ការចូលរួមរបស់សហគមន៍....................................................៣០
២.៧-ស្ថានភាពសាលាបឋមសិក្សានៅកម្ពុជា....................................................៣១
ក.សាលាបឋមសិក្សានៅខេត្តសៀមរាប....................................................៣១
ខ.ស្តង់ដាសាលាបឋមសិក្សា....................................................៣១

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**

៣.១-ដំណើរការនៃការស្រាវជ្រាវ....................................................៤៤
៣.១.១-វិធីសាស្ត្រប្រមូលទិន្នន័យ....................................................៤៤
៣.២-ឧបករណ៍និងការប្រមូលទិន្នន័យ....................................................៤៤
៣.២.១-ឧបករណ៍....................................................៤៤
៣.២.៣-ការប្រមូលទិន្នន័យ....................................................៤៥
៣.៣.វិធីសាស្ត្រវិភាគទិន្នន័យ....................................................៤៥

**ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា**

៤.១-សាលាបឋមសិក្សាទី១....................................................៤៦
៤.២-សាលាបឋមសិក្សាទី២....................................................៤៩
៤.៣-សាលាបឋមសិក្សាទី៣....................................................៥២

៤.៤-សាលាបឋមសិក្សាទី៤....................................................................................................៥៥
៤.៥-សាលាបឋមសិក្សាទី៥....................................................................................................៥៨
៤.៦-សាលាបឋមសិក្សាទី៦....................................................................................................៦១
៤.៧-សាលាបឋមសិក្សាទី៧....................................................................................................៦៤
៤.៨-សាលាបឋមសិក្សាទី៨....................................................................................................៦៧
៤.៩-សាលាបឋមសិក្សាទី៩....................................................................................................៧០
៤.១០-សាលាបឋមសិក្សាទី១០................................................................................................៧៣
៤.១១-សាលាបឋមសិក្សាទី១១................................................................................................៧៦
៤.១២-សាលាបឋមសិក្សាទី១២................................................................................................៧៩
៤.១៣-សាលាបឋមសិក្សាទី១៣................................................................................................៨២
៤.១៤-សាលាបឋមសិក្សាទី១៤................................................................................................៨៥
៤.១៥-សាលាបឋមសិក្សាទាំង១៤ក្នុងក្រុងសៀមរាប.......................................................................៨៨
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាននិងសំណូមពរ**
៥.១-សេចក្តីសន្និដ្ឋាន.............................................................................................................៩៤
៥.២-សំណូមពរ.....................................................................................................................៩៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១៖ សេចក្ដីផ្ដើម

## ១.១-សាវតារ

ពិភពលោកសព្វថ្ងៃនេះបានដឹកនាំសង្គមមនុស្ស និងមនុស្សឱ្យរីកចម្រើនឥតឈប់ឈរទៅលើបច្ចេកវិទ្យានិងវិទ្យាសាស្ត្រទំនើប ជាពិសេសបដិវត្តឧស្សាហកម្មប្រព័ន្ធឌីជីថល នាសតវត្សទី២១។ នៅក្នុងឯកសារបកប្រែរបស់លោក តាន់ មុន្នីវិសាល ទំព័រ២ (ឧស្សាហកម្ម៤.០) វ៉ុល១ លេខទី៣ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩ បានចែកបដិវត្តឧស្សាហកម្មជាបួនដំណាក់កាលធំៗមាន (១)ការបង្កើតម៉ាស៊ីនដើរដោយចំហាយទឹកគួបផ្សំជាមួយនឹងការប្រើប្រាស់ផ្លូវរថភ្លើង។ (២) របកគំហើញថាមពលអគ្គីសនី និង ការបង្កើតខ្សែចង្វាក់ផលិតកម្មនៅក្នុងរោងចក្រ។ (៣) គឺការអភិវឌ្ឍផ្នែកបច្ចេកវិទ្យាប្រព័ន្ធអ៊ិនធើណេត ព័ត៌មានវិទ្យា ស៊ីមីកុងឌុចទ័រ (Semi conductor) និង កុំព្យូទ័រភាវូបនីយកម្ម(៤)ការពឹងផ្អែកលើមូលដ្ឋានគ្រឹះរបស់បច្ចេកវិទ្យាឌីជីថលក្នុងឧស្សាហកម្មទី៣ ជាមួយការរួមបញ្ចូលគ្នានូវបច្ចេកវិទ្យាចំនួន៣មានពិភពរូប ពិភពឌីជីថល និងពិភពជីវសាស្ត្រ។

ការប្រើប្រាស់នូវបច្ចេកវិទ្យា ព័ត៌មានវិទ្យា និងសារគមនាគមន៍ ព្រមទាំងចំណេះដឹងទាក់ទងសមត្ថភាពផ្ទាល់ខ្លួនរបស់បុគ្គលសមស្របទៅតាមការវិវត្តន៍របស់សង្គម។ យុគសម័យសេដ្ឋកិច្ចនិងបច្ចេកវិទ្យាព័ត៌មាននេះ ឧត្តមភាពប្រកួតប្រជែងកាន់តែមានសារៈសំខាន់ទៅលើកត្តាធនធានមនុស្សដែលមានចំណេះដឹង ចំណេះធ្វើទូលំទូលាយ មានភាពច្នៃប្រឌិតខ្ពស់ និងមានជំនាញច្បាស់លាស់។

ការអប់រំបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍធនធានមនុស្ស ឱ្យមានចំណេះដឹងសមត្ថភាព មានសម្បទាគ្រប់គ្រាន់ ជំនាញ ភាពច្នៃប្រឌិត នវានុវត្តន៍ ស្មារតីសហគ្រិនភាព និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកនៅក្នុងការលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែងនិងលើកកម្ពស់ផលិតភាព។ ពាក់ព័ន្ធនឹងការអប់រំនេះដែរ នៅក្នុងឯកសារគោលនយោបាយជាតិស្តីពី ការសិក្សាពេញមួយជីវិតរបស់រាជរដ្ឋាភិបាលកម្ពុជា ចេញផ្សាយខែកក្កដាឆ្នាំ២០១៩ ទំព័រ១០ឱ្យដឹងថា ការបណ្តុះបណ្តាលធនធានមនុស្សនេះ មានភាពបត់បែនតាមគ្រប់រូបភាពសំដៅលើកកម្ពស់ការសិក្សាពេញមួយជីវិត។

ការដឹកនាំបានធ្វើឱ្យមានការផ្លាស់ប្តូរ និងការប្រែប្រួល ដោយបង្កើតជាទស្សនវិស័យបង្កើតឱ្យមានការតម្រង់ទិសបង្កើត និងរៀបចំយុទ្ធសាស្ត្រ តម្រង់ទិសមនុស្សនិងបុគ្គលិក ជំរុញទឹកចិត្តនិងបំផុសគំនិតលើកទឹកចិត្តមនុស្ស ផ្តល់អំណាចឱ្យមនុស្សនៅក្រោមបង្គាប់ បំពេញការឆ្លើយតបដែលខកខានមិនបានបំពេញការអភិវឌ្ឍមនុស្សជំរុញទឹកចិត្តខ្លួនឯង(កែវ ចាន់ណានិងញ៉ែត ចាន់២០១០)។

ទាក់ទងនឹងអ្នកដឹកនាំនេះដែរ បណ្ឌិត ហ៊ួ ឈុនគ្រី អគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងអប់រំលើកឡើងថាក្នុងនាមជាអ្នកដឹកនាំ ត្រូវមានសមត្ថភាពវិជ្ជាជីវៈតាមរយៈ ការសហការការងារជាមួយមន្ត្រីរាជការដទៃដើម្បីសម្រេចលទ្ធផលរួម ស្មារតីជាក្រុមមានការទំនាក់ទំនងអន្តរបុគ្គល និងមានសមត្ថភាពអនុវត្តការងារក្រោមសម្ពាធ។

វិស័យអប់រំមានការរីកចម្រើនទៅបាន អាស្រ័យការអប់រំនោះមានធនធានមនុស្សសំបូរបែបជាតម្រូវការដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គម។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានបោះជំហានឈានចូលដល់ការអប់រំបែបបច្ចេកវិទ្យាឌីជីថល ដែលចាំបាច់មនុស្សត្រូវបង្កើនចំណេះវិជ្ជាឱ្យបានច្រើនស្របតាមការវិវត្តន៍របស់ជាតិនិងពិភពលោក។ បើតាមបាឋកថា ឯកឧត្តមហ៊ុនម៉ានីបានបរិយាយអំពីស្ថានភាពអប់រំក្នុងបរិបទកម្ពុជានៅវិទ្យាស្ថានជាតិអប់រំឆ្នាំ២០១៩ថាធនធានមនុស្សសម័យឌីជីថលសតវត្សទី២១ផ្តោតទៅលើសមត្ថភាពនិងចំណេះដឹងរួមមាន ការច្នៃប្រឌិត និងនវានុវត្តន៍ ការត្រិះរិះពិចារណាដោះស្រាយបញ្ហា និងសម្រេចចិត្តត្រឹមត្រូវ មានចំណេះ រៀនដើម្បីចេះរៀន មានទំនាក់ទំនងល្អមានចំណេះក្នុងការសហការ(ធ្វើការជាក្រុម) មានចំណេះឌីជីថល មានចំណេះបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យា មានការអភិវឌ្ឍខ្លួនជាពលរដ្ឋល្អ មានបំណិនគ្រប់គ្រងជីវិត និងការងារ មានការទទួលខុសត្រូវផ្ទាល់ខ្លួននិងក្នុងសង្គម។

នៅក្នុងបរិបទបច្ចេកវិទ្យាដ៏ទំនើបនេះ មនុស្សត្រូវបំពេញការងារ ទៅតាមតួនាទី និងភារកិច្ចព្រមទាំងមានមុខតំណែងក្នុងបណ្តាស្ថាប័ន ក្រសួង មន្ទីរ ឬអង្គភាពណាមួយ ហើយក៏ត្រូវមានមុខជំនាញ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីក្លាយខ្លួនជាអ្នកគ្រប់គ្រងដឹកនាំនៅក្នុងអង្គភាព។

រីឯការគ្រប់គ្រងធ្វើឱ្យមានប្រសិទ្ធភាព ក៏ត្រូវអនុវត្តទៅតាមជំហានមានបង្ហាញសកម្មភាពល្អៗប្រចាំថ្ងៃ ហ៊ានបង្ហាញពីតម្លាភាពនិងគណនេយ្យភាព អ្វីៗដែលបានធ្វើត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយមានមោទនភាពលើវិជ្ជាជីវៈរបស់ខ្លួន បំពេញការងារឱ្យអស់ពីលទ្ធភាពនិងសមត្ថភាព ចេះជ្រើសរើសចំណុចណាជាអាទិភាពមកធ្វើមុន និងហ៊ានធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការដោះស្រាយបញ្ហាប្រឈមព្រមទាំងបង្ហាញឥរិយាបថភាពជាសហគ្រិនភាព (បណ្ឌិត នូវ វីរ៉ា ២០១៩)។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងដឹកនាំ ទៅលើការអភិវឌ្ឍស្តង់ដាគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ក្រសួងអប់រំក៏បានធ្វើការបណ្តុះបណ្តាលបន្ថែមលើកិច្ចការ សកម្មភាព តម្រូវការវិជ្ជាជីវៈ គុណវុឌ្ឍិ។ល។ (ក្រសួងអប់រំ ២០១៦)។

ការកសាងសមត្ថភាព ជាអ្នកដឹកនាំនិងគ្រប់គ្រង ដោយផ្តោតលើគ្រឹះស្ថានអប់រំសាធារណៈ និងការចូលរួមពីអាជ្ញាធរមូលដ្ឋាន មាតាបិតាសិស្ស អ្នកអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធទាំងអស់រៀបចំផែនការអភិវឌ្ឍសាលារៀនរយៈពេល៥ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយមានការចូលរួមពីគណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតាសិស្សនិងសហគមន៍ (ក្រសួងអប់រំ ២០១៨)។

អ្នកដឹកនាំជាច្រើននៅលើសកលលោក បានដាក់ចេញនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ក្នុងនោះគោលដៅទី៤ផ្តោតលើការអប់រំ។ ការអប់រំប្រកបដោយគុណភាពគឺការអប់រំដែលឆ្លើយតបទៅនឹងតម្រូវការរបស់ពិភពលោក។ ការអប់រំប្រកបដោយចីរភាពមានសារៈសំខាន់ដើម្បីធានាបានការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងបរិយាបន្នដែលផ្តល់ឱកាសស្មើៗគ្នាដល់កុមារនិងយុវជនក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធនៅទូទាំងប្រទេស (សារលិខិត សម្តេចតេជោហ៊ុនសែនថ្ងៃបើកបវេសនកាល ២០១៩)។

អ្នកដឹកនាំអប់រំ (នាយកសាលា) ត្រូវប្រកាន់យកនូវសមាសភាពចំនួន៨មានដូចជា (១)ការសហការនិងការចូលរួម (២)ការលើកទឹកចិត្ត (៣)ចេះធ្វើផែនការ (៤)ការសម្រេចចិត្ត (៥)ទំនាក់ទំនងបុគ្គល (៦)ការគ្រប់គ្រងទំនាស់ (៧)ការតាមដាននិងវាយតម្លៃបុគ្គលិក (៨)ការគ្រប់គ្រងបុគ្គលិកនិងការអភិវឌ្ឍវិជ្ជាជីវៈ (បណ្ឌិត ថៅសារ៉ាត់ហ៊ុំ ២០១៩)។ ទាក់ទងអ្នកគ្រប់គ្រងនៅតាមស្ថាប័នអង្គភាពនានាក្នុងតួនាទីជាមន្ត្រីសាធារណៈត្រូវមានមុខងារចំនួន៤ដូចជា ការធ្វើផែនការ ការចាត់តាំង ការដឹកនាំ និងការត្រួតពិនិត្យ។ ស្របគ្នានេះនៅក្នុងបរិបទនៃការអប់រំនាសតវត្សទី២១នេះ ការគ្រប់គ្រងសាលារៀនរបស់នាយកគ្រឹះស្ថានសិក្សាទាមទារឱ្យមាននូវចំណេះដឹងបច្ចេកវិទ្យាទូលំទូលាយ ជាការកសាងចំណេះដឹងនៅក្នុងយុគសម័យឌីជីថល (បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ២០១៩)។ នាយកសាលាក្នុងសម័យឌីជីថលនេះ គឺត្រូវមានបំណិនគមនាគមន៍ ទំនាក់ទំនងសាធារណៈជាមួយសហគមន៍ បំណិនបង្កើតម៉ាក (Branding) ការបង្កលក្ខណៈឱ្យសិស្សរៀន ដោយផ្តោតលើការចេះច្នៃប្រឌិតបរិស្ថានសិក្សា ដែលទាក់ទងដល់ការរៀននិងបង្រៀនដោយប្រើនវានុវត្តន៍។ ការចេះចាប់និងផ្តល់ឱកាសព្រមទាំងបង្កលក្ខណៈឱ្យនាយកសាលាអភិវឌ្ឍវិជ្ជាជីវៈ។ អ្នកដឹកនាំសាលារៀនបែបសតវត្សទី២១ ត្រូវការពង្រឹងសមត្ថភាពខ្លួនឯងឱ្យមានចំណេះដឹងជ្រៅជ្រះ មានបំណិនវិជ្ជាជីវៈកាន់តែច្បាស់ និងមានគោលដៅជីវិតរឹងមាំ និងសម្រាប់ការពង្រឹងដល់ការដឹកនាំនិងបង្រៀននៅក្នុងសាលារៀន (បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន២០១៩)។ ការអប់រំគឺមានសារៈសំខាន់សម្រាប់មនុស្សទាំងអស់គ្នា។ដើម្បីទទួលបានភាពជោគជ័យក្នុងការដឹកនាំ និងគ្រប់គ្រងសាលាគឺនាយកត្រូវចេះធ្វើផែនការ ការចាត់តាំង ការលើកទឹកចិត្តបានល្អរបស់នាយកសាលា ហើយមានសមត្ថភាពសមស្រប។នាយកមានគុណវុឌ្ឍិ បទពិសោធន៍ការងារ ការគិតបែបយុទ្ធសាស្រ្តនិងនវានុវត្តន៍ ( បាន គនហេង ២០១៩)។

នៅក្នុងសតវត្សទី២១នេះ ការគ្រប់គ្រងធនធានមនុស្សបានលើកកម្ពស់ភាពជាពលរដ្ឋប្រកបដោយគុណភាព។ តាមរយៈ សៀវភៅផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ ទំព័រ៣៧-៣៩ បោះពុម្ព ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងអប់រំបានបញ្ជាក់ថា នៅក្នុងកំឡុងឆ្នាំ២០៣០ ប្រព័ន្ធអប់រំកម្ពុជាគឺរឹងមាំ និង មានសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់សម្រាប់សង្គមពុទ្ធិ។ សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងមានគណនេយ្យភាពក្នុងការសម្រេចបាន

នូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ គ្រូបង្រៀនមានសមត្ថភាពវិជ្ជាជីវៈ ហើយសិស្សមានសុខភាពល្អ មានការលើកទឹកចិត្ត និងមានការប្តេជ្ញាចិត្ត ហើយបន្ទប់រៀនជាបន្ទប់រៀនវៃឆ្លាតថែមទៀតផង (ក្រសួងអប់រំ ២០១៩)។

ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ខែកញ្ញា ឆ្នាំ១៩៩៣ ជំពូកទី៣ មាត្រា៣៦ ទំព័រ១៨ចែងថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្រប តាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។ ជំពូកទី៦ មាត្រា៦៥ ទំព័រ២៨-២៩ ច្បាប់ដដែលឱ្យដឹងថា រដ្ឋត្រូវការពារនិងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ ចំណែកច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ខែតុលា ឆ្នាំ១៩៩៤ ជំពូកទី៥ មាត្រា៣៨ ទំព័រ១០ចែងថា អ្នករាជការទាំងអស់ត្រូវបង្ហាញឱ្យឃើញថាខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន។

សព្វថ្ងៃនេះ កម្ពុជាបានកំណត់នូវចក្ខុវិស័យ ក្នុងការបណ្តុះបណ្តាលធនធានមនុស្សក្នុងគោលដៅឆ្ពោះទៅកាន់សង្គមពុទ្ធិ និងវិបុលភាព។ ប្រជាជនមានចំណេះដឹង មានវប្បធម៌ជ្រៅជ្រះ មានផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលភាវូបនីយកម្មដោយឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល មានចក្ខុវិស័យប្រែក្លាយពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្ន ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០និងក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់នាឆ្នាំ២០៥០ (សារលិខិតសម្តេចតេជោហ៊ុនសែនថ្ងៃបើកបវេសនកាល២០១៨)។ ដើម្បីសម្រេចបានគោលដៅនេះ ក្រសួងអប់រំបានធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលមានគោលនយោបាយពីរគឺ (១)ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង (២)ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (ក្រសួងអប់រំ ២០១៨)។

រដ្ឋាភិបាលកម្ពុជាសព្វថ្ងៃ បានធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេស។ សាលារៀនគឺជាកន្លែងសម្រាប់អប់រំនិងបណ្តុះបណ្តាលមនុស្សគ្រប់វ័យនៅក្នុងសហគមន៍ ដើម្បីអភិវឌ្ឍបុគ្គលិក បុគ្គល គ្រួសារ សហគមន៍ និងសង្គម។ សាលារៀនត្រូវអនុវត្តតាមគោលដៅអប់រំជាតិតាមរយៈ ការបណ្តុះបណ្តាលសិស្សានុសិស្សឱ្យក្លាយជាមនុស្សពេញលេញ(ពលរដ្ឋល្អ ពលរដ្ឋថ្លៃថ្នូរ ពលករជំនាញ) ដែលជាប្រភពនៃការអភិវឌ្ឍជាតិនិងគោលនយោបាយវិស័យអប់រំរបស់រដ្ឋាភិបាល ដែលផ្តោតសំខាន់លើមជ្ឈដ្ឋានអប់រំទាំងបី (ក្រសួងអប់រំ ២០១៦) ក្នុងការអប់រំកុមារនិងយុវជនរួមមាន ការឯកភាពរវាងនាយកនិងបុគ្គលិក ការ

ឯកភាពរវាងសាលារៀននិងគ្រូសារសិស្ស ការឯកភាពរវាងសាលារៀននិងសង្គម។ មួយវិញទៀត ក្រសួងអប់រំ ក៏បានធ្វើការផ្ទេរមុខងារ និង ធនធានក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនិង គ្រឹះស្ថានសិក្សា សំដៅបង្កិតការផ្តល់សេវាទៅកៀកជិតជាមួយប្រជាពលរដ្ឋ។ ធនធានទាំងនោះរួម មានធនធានហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស(ក្រសួងអប់រំ២០១៦)។ តួយ៉ាងខេត្តបាត់ដំបង បានអនុវត្តតាមការផ្ទេរការគ្រប់គ្រង និងមុខងារប្រតិបត្តិទៅដល់ក្រុមប្រឹក្សាស្រុក ក្រុងដែលអនុញ្ញាត ដោយក្រសួងអប់រំ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ ក្រោមជាតិនៅថ្ងៃទី២៥ ខែកញ្ញាឆ្នាំ២០១៥ និងអនុក្រឹត្យលេខ១៩១ របស់រាជរដ្ឋាភិបាលស្តីពីការផ្ទេរ មុខងារប្រតិបត្តិទាំងអស់ ដែលទាក់ទងនឹងការគ្រប់គ្រងកុមារតូច បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ ទៅដល់រដ្ឋបាលស្រុកក្រុង(ស៊ឹម វិសុទ្ធ២០១៧)។ ការគ្រប់គ្រងសាលារៀនជាការធ្វើវិមជ្ឈការលក្ខណៈ ជាប្រព័ន្ធទៅឱ្យសាលារៀននូវស្វ័យភាពនិងការទទួលខុសត្រូវលើកិច្ចការសំខាន់ៗនានា ពាក់ព័ន្ធនិង ប្រតិបត្តិការសាលារៀន ដោយស្ថិតក្នុងក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន គោលនយោបាយ កម្មវិធី សិក្សា ស្តង់ដានិងគណនេយ្យភាពដែលកំណត់ដោយថ្នាក់ជាតិ (ក្រសួងអប់រំ ២០១៥)។

ទាក់ទងការគ្រប់គ្រងសាលារៀននេះ មានសមាសភាពចំនួន៥ដូចជា ស្វ័យភាពក្នុងការធ្វើ ផែនការ និងការគ្រប់គ្រងថវិកាសាលារៀន ការគ្រប់គ្រងបុគ្គលិក តួនាទីគណៈកម្មការគ្រប់គ្រង សាលារៀន/SMC និងអភិបាលកិច្ចសាលារៀន ការវាយតម្លៃសាលារៀននិងសិស្ស គណនេយ្យ ភាពសាលារៀន (ក្រសួងអប់រំ ២០១៨)។ ការគ្រប់គ្រងសាលារៀន ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការ គ្រប់គ្រងនិងដឹកនាំរបស់នាយកសាលា។ នៅក្នុងគោលនយោបាយ កែលម្អការគ្រប់គ្រងសាលារៀន បានលើកឡើងថាការលើកទឹកចិត្តគ្រូបង្រៀន និង គណៈគ្រប់គ្រងសាលាគឺជានយោបាយអាទិភាព របស់ក្រសួងអប់រំ (២០១៣-២០១៨) ដែលជំរុញឱ្យមានវិមជ្ឈការ ការគ្រប់គ្រងសាលារៀនព្រមទាំង ការវាយតម្លៃសាលារៀន និងការលើកទឹកចិត្តគ្រូបង្រៀន ដើម្បីធានាបាននូវគុណភាពអប់រំមួយល្អ ប្រសើរសម្រាប់ប្រកួតប្រជែងនៅក្នុងសហគមន៍ (បណ្ឌិត គួយ សូគាន ២០១៨)។ ការគ្រប់គ្រង សាលារៀនជាយន្តការដ៏មានប្រសិទ្ធភាពមួយ នៅក្នុងការអនុវត្តវិមជ្ឈការនៃការអប់រំ ដើម្បីធានាឱ្យ សេវាអប់រំមានប្រសិទ្ធភាពខ្ពស់។ ការគ្រប់គ្រងតាមសាលារៀន គឺការផ្តល់ស្វ័យភាពក្នុងការសម្រេច ចិត្តទៅកម្រិតមូលដ្ឋានដោយផ្អែកលើលទ្ធផល នៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផល សិក្សារបស់សិស្ស (ក្រសួងអប់រំ ២០១៨)។

ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលបានក្លាយជាយុទ្ធសាស្ត្រ ដែលគេបានផ្ទេរទៅកាន់ សាលារៀន ហើយបានដាក់ប្រើប្រាស់នៅប្រទេសអង់គ្លេស មានសាលាជាង២៥០០០ បានអនុវត្ត។ ការគ្រប់គ្រងសាលានេះបានយកមកពិភាក្សាអនុវត្តនៅញូវហ្សេឡែន អូស្ត្រាលី កាណាដា និងសហ រដ្ឋអាមេរិកនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីអប់រំ(APEC) កាលពីខែមេសាឆ្នាំ២០០៤ នៅSantiago Chile ហើយ

ចាត់ទុកជាប្រព័ន្ធគោលនយោបាយអប់រំនាសតវត្សទី២១(បណ្ឌិត គួយ សូគាន២០១៨)។ ដោយឡែក ការគ្រប់គ្រងសាលារៀននៅកម្ពុជា ត្រូវកំណត់ដោយមានរចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាមួយយ៉ាង ច្បាស់ដូចជាក្រុមប្រឹក្សាភិបាល ឬគណៈកម្មការអភិវឌ្ឍសាលារៀន មានសមាសភាពគណៈកម្មការ គ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាកុមារ ប្រធានក្រុមបច្ចេកទេសតាមកម្រិតថ្នាក់រៀន គ្រូបង្រៀន ក្រុម ប្រឹក្សាឃុំសង្កាត់ ប្រធានភូមិ ប្រធានក្រុម មណ្ឌលសុខភាព ប៉ុស្តិ៍នគរបាល និងអ្នកពាក់ព័ន្ធផ្សេង ទៀតដែលអាចជួយអភិវឌ្ឍសាលារៀន (ក្រសួងអប់រំ ២០១៧)។

ការគ្រប់គ្រងតាមសាលារៀននៅកម្ពុជា មានការផ្លាស់ប្តូរជាវិជ្ជមានលើការងាររដ្ឋបាលសាលា រៀន ការរៀននិងបង្រៀន បរិស្ថានសាលារៀន អត្រាឡើងថ្នាក់ ការចូលរួមរបស់សិស្សស្រី គណនេយ្យភាពនៅក្នុងការគ្រប់គ្រងសាលារៀន លទ្ធផលការបំប៉នសមត្ថភាពជាប្រចាំ គោរពក្រម សីលធម៌វិជ្ជាគ្រូបង្រៀនបានប្រសើរនិងធ្វើឱ្យសហគមន៍ មានទំនុកចិត្តលើសាលារៀន។ ការគ្រប់គ្រង សាលារៀននៅកម្ពុជាមានមូលដ្ឋានចំនួនបី (ស៊ឹម វិសុទ្ធ ២០១៧)។ទីមួយធនធានមនុស្សមានរដ្ឋបាល ថ្នាក់រាជធានី ខេត្ត ក្រុង ឃុំ សហគមន៍ នាយកសាលានិងគ្រូបង្រៀន។ ទីពីរធនធានថវិកាជាការបែង ចែកថវិកា ការចាយថវិកា ការគ្រប់គ្រង និងការទូទាត់។ ទីបីការបណ្តុះបណ្តាលសមត្ថភាព (Pre Serviceនិងln Service)។ តាមរយៈលិខិតលេខៈ១៩៣៩ អយក នក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងអប់រំបានផ្ទេរធនធានហិរញ្ញវត្ថុទ្រព្យសម្បត្តិនិងបុគ្គលិកនៃការិយាល័យអប់រំ យុវជន និង កីឡាក្រុង ស្រុក ដែលកំពុងបំពេញការងារបច្ចុប្បន្នឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក។

នៅក្នុងបំណែងចែកកម្មវិធីសិក្សា សម្រាប់បណ្តុះបណ្តាលវគ្គនាយកសាលា របស់វិទ្យាស្ថាន ជាតិអប់រំឆ្នាំសិក្សា២០១៨-២០១៩វិញបានបង្ហាញថាការគ្រប់គ្រងសាលារៀននៅកម្ពុជាមានពីរផ្នែក។
-ការគ្រប់គ្រងសាលារៀនផ្អែកតាមលទ្ធផលតាមរយៈ ការលើកម្ពស់ការបង្រៀននិងរៀន បរិស្ថាន សិក្សា កម្មវិធីសាលាកុមារមេត្រី ការបំពេញការងាររបស់គ្រូ កម្មវិធីសិក្សា អធិការកិច្ចសាលារៀន..។
-ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (ការគ្រប់គ្រងធនធាន) មានការគ្រប់គ្រងគម្រោង កម្មវិធី សាលារៀន (ផែនការ) ការងារបុគ្គលិក សម្ភារៈនិងហិរញ្ញវត្ថុ បញ្ជីសារពើភ័ណ្ឌ...។ ចំណែកទ្រឹស្តីនៃ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលមាន៦សំខាន់ៗរួមមាន ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ ការវិភាជថវិកា យុទ្ធសាស្ត្រគ្រប់គ្រង ការអភិវឌ្ឍបុគ្គលិក ការរៀននិងបង្រៀន ព្រមទាំងធនធាន ផ្សេងៗទៀត (ស៊ឹម វិសុទ្ធ ២០១៧)។

ប្រព័ន្ធគ្រប់គ្រងផ្អែកលើធនធាន គឺមានទំនាក់ទំនងជាមួយការបង្កើតគោលដៅនិងការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ដោយផ្តោតលើការអភិវឌ្ឍសមត្ថភាពសិស្ស គ្រូព្រមទាំង ចែកចាយនូវធនធានសម្ភារៈនិងធនធានហិរញ្ញវត្ថុនានាក្នុងអង្គភាព (បណ្ឌិត គួយ សូគាន ២០១៨)។ ប្រសិទ្ធភាពនៃការគ្រប់គ្រងផ្អែកលើធនធាន ការជះឥទ្ធិពលដល់ការលើកទឹកចិត្ត ការប្តេជ្ញានិងភាព

ជោគជ័យរបស់សិស្សនិងគ្រូតាមរយៈ ការសម្របសម្រួលក្នុងភាពជាអ្នកដឹកនាំសាលារៀន ស្របទៅនឹងបរិបទនិងតម្រូវការនៃសហគមន៍របស់សាលារៀន។ គោលដៅរបស់សាលាចង់ឱ្យសិស្សរៀនក្នុងសាលាមានសុវត្ថិភាព បរិស្ថានក្នុងថ្នាក់ និងសាលាស្អាត គ្រូមានបច្ចេកទេស វិធីសាស្ត្របង្រៀនគ្រប់ជ្រុងជ្រោយ សិស្សមានសុខភាពអនាម័យល្អហើយការងារជួសជុល និងសាងសង់សាលាមានជាបន្តបន្ទាប់តាមដំណាក់កាល។ ការអប់រំគឺសម្រាប់ទាំងអស់គ្នា តាំងពីកម្រិតថ្នាក់មត្តេយ្យរហូតដល់កម្រិតថ្នាក់ក្រោយឧត្តមសិក្សា។ ការសិក្សាគឺពេញមួយជីវិត។ ដោយឡែក នៅក្នុងគោលនយោបាយជាយុទ្ធសាស្ត្រទាំងបួនរបស់ក្រសួងអប់រំ ត្រង់ចំណុចទីមួយបាននិយាយថា សកលកម្មអប់រំចំណេះទូទៅមូលដ្ឋានប្រាំបួនឆ្នាំ និងអភិវឌ្ឍអក្ខរកម្មវិជ្ជាជីវៈ និងបំពេញវិជ្ជា (ក្រសួងអប់រំ ២០១៤)។

ទាក់ទងនិងការគ្រប់គ្រងសាលារៀនកម្រិតបឋមសិក្សា គឺសាលារៀននីមួយៗ ត្រូវកំណត់គោលនយោបាយកម្មវិធីសាលាកុមារមេត្រីរបស់ក្រសួងអប់រំ ដែលបានដាក់ឱ្យអនុវត្តចាប់តាំងពីឆ្នាំ២០០៧រហូតមកដល់សព្វថ្ងៃនេះ។ ការអនុវត្តសមាសភាគទាំងប្រាំមួយ នៃកម្មវិធីសាលាកុមារមេត្រីផ្តល់ឱកាសស្មើៗគ្នាដល់កុមារទទួលបានចំណេះដឹង ជំនាញ សមធម៌ និងចេះរស់នៅជាមួយគ្នាដោយសុខដុមរមនា។ មិនតែប៉ុណ្ណោះ ធានាកុមារទាំងអស់បានចូលរៀន ធានាការបង្រៀននិងការរៀនប្រកបដោយប្រសិទ្ធភាព ធានាសុខភាព សុវត្ថិភាពនិងការពារកុមារ ធានាការឆ្លើយតបទៅនឹងយេនឌ័រ ធានាការចូលរួមរបស់ក្រុមគ្រួសារ និងសហគមន៍ និង ប្រព័ន្ធអប់រំជាតិផ្តល់ការជួយគាំទ្រកម្មវិធីសាលាកុមារមេត្រី និងលើកទឹកចិត្តដល់សាលារៀនឱ្យទៅជាសាលាកុមារមេត្រី។ (ក្រសួងអប់រំ ២០១២)។

បើតាមសៀវភៅស្តង់ដាសាលាបឋមសិក្សាក្រសួងអប់រំ ឆ្នាំ២០១៧បានបង្ហាញថា ការអនុវត្តស្តង់ដាសាលាបឋមសិក្សាជាមគ្គុទ្ទេសក៍សម្រាប់អ្នកពាក់ព័ន្ធត្រូវយល់ដឹងអំពីសាលារៀន ដើម្បីធានាបាននូវប្រសិទ្ធភាព និងធានាគុណភាពនៃការសិក្សា ប្រែកុមារទៅជាពលរដ្ឋសកល (ស្អាត របៀប សុខភាព ទៀងពេល និងសមាធិ) ក្រសួងអប់រំ ២០១៧។ ទាក់ទងការសិក្សារបស់សិស្សធ្វើឡើងតាមរយៈការវាយតម្លៃជាប្រចាំកែលម្អវិធីសាស្ត្របង្រៀន និងដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។ ការរៀបចំកម្មវិធីសិក្សា សម្ភារបង្រៀនផ្សេងៗ ការកែលម្អបណ្ណាល័យ គ្រូបានលើកទឹកចិត្តសិស្សរៀបចំសម្ភារសិក្សា សិស្សស្រាវជ្រាវរៀនសូត្រទៀតផង (ក្រសួងអប់រំ ២០១៨)។ រីឯការសិក្សារបស់សិស្សនៅកម្រិតបឋមសិក្សាអត្រាពិតចូលរៀន១០០% អត្រាពិតនៃការសិក្សា១០០% ហើយអត្រាឡើងថ្នាក់៩៧% និងអត្រាបោះបង់ការសិក្សា១%។ ម៉្យាងវិញទៀត កម្ពុជាសម្រេចបាននូវសកលកម្មនៃការអប់រំនៅបឋមសិក្សា ដោយមានអត្រាពិតនៃការសិក្សា៩៧,៨% ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ប្រសិទ្ធភាពផ្ទៃក្នុងកម្រិតបឋមសិក្សាមានភាពល្អប្រសើរតាមរយៈអត្រាត្រួតថ្នាក់និងបោះបង់ការសិក្សា។ គេសង្កេតឃើញថា អត្រាត្រួតថ្នាក់ បាន

ថយពី១០,៦% ក្នុងឆ្នាំសិក្សា២០០៧-២០០៨ មក៦,៥%ក្នុងឆ្នាំសិក្សា២០១៧-២០១៨។ ចំណែកអត្រាបញ្ចប់ការសិក្សាថយចុះពី៨៨,៩% ឆ្នាំសិក្សា២០១៣-២០១៤មក៨២,៧% ឆ្នាំសិក្សា២០១៧-២០១៨។ ដោយឡែកអត្រាបញ្ចប់ការសិក្សាមានកម្រិតទាប នៅកន្លែងដែលមានអត្រាបោះបង់ការសិក្សាខ្ពស់។ សិស្សប្រុសមានកម្រិតទាបជាងសិស្សស្រី។ សិស្សនៅតាមសាលារៀនពុំបានរៀនសូត្រឱ្យបានគ្រប់គ្រាន់នៅឡើយ។ នៅក្នុងចំណោមសិស្សថ្នាក់ទី៣ដែលបានធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យានៅឆ្នាំ២០១២ មានតែ៥៤,១%ប៉ុណ្ណោះដែលឆ្លើយវិញ្ញាសាខ្មែរបានត្រឹមត្រូវ និង៤៨%ឆ្លើយវិញ្ញាសាគណិតវិទ្យាបានត្រឹមត្រូវ។ នៅក្នុងចំណោមសិស្សថ្នាក់ទី៦ដែលបានធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ មានត្រឹមតែ៤៥,៧%ប៉ុណ្ណោះឆ្លើយបានត្រឹមត្រូវ។ រីឯតេស្តលើមុខវិជ្ជាគណិតវិទ្យាមានតែ៤៤,៣%ឆ្លើយបានត្រឹមត្រូវក្នុងឆ្នាំ២០១៣ (ក្រសួងអប់រំ ២០១៩)។ ជាមួយគ្នានេះ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) បានធ្វើគម្រោងសាលារៀនគោលដៅទាំងអស់ទទួលបានការរីកចម្រើនផ្នែកសាលាកុមារមេត្រី ដោយសារការដឹកនាំនិងគ្រប់គ្រងកាន់តែប្រសើរឡើងរបស់នាយកសាលារៀន។ នៅក្នុងនោះសាលាចំនួន១៤៦បឋមសិក្សា អង្គការបានជួយកែលម្អគណៈគ្រប់គ្រងសាលារៀនតាមរយៈ ផ្តល់ការបំប៉នពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងកែលម្អបរិស្ថានសាលាកុមារមេត្រី ដោយការពង្រឹងសមត្ថភាពគណៈគ្រប់គ្រងសាលារៀន និងផ្តល់អំណោយអភិវឌ្ឍសាលារៀនបញ្ចូលសាលាកុមារមេត្រី ។ ម៉្យាងវិញទៀត ភាពជោគជ័យរបស់នាយកសាលាលើការគ្រប់គ្រងសាលារៀនអាស្រ័យលើការគិតគូរអំពីទស្សនៈវិស័យ គោលដៅ គុណតម្លៃ និងគោលការណ៍ប្រតិបត្តិប្រព័ន្ធនៅក្នុងអង្គភាពជាដើម។ ការគ្រប់គ្រងសាលារៀនជាផ្នែកមួយនៃការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលាធ្វើឱ្យមានដំណើរការសាលា។ ស្ថិតក្រោមការចង្អុលបង្ហាញដោយផ្ទាល់របស់ **ឯកឧត្តម បណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំនិងក្រោមការដឹកនាំផ្ទាល់របស់ **បណ្ឌិត នី វឌ្ឍា**ទើបអ្នកស្រាវជ្រាវបានលើកយកប្រធានបទ«**ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា**» មកសិក្សា។

## ១.២-បញ្ហានៃការស្រាវជ្រាវ

សាលារៀន ជាកន្លែងសម្រាប់ធ្វើការបណ្តុះបណ្តាលរបស់សហគមន៍។ ការបង្កើតឱ្យមានសាលារៀននៅតាមភូមិ ឃុំ ស្រុក ខេត្តទូទាំងប្រទេស ជាយុទ្ធសាស្រ្តចម្បងមួយរបស់ក្រសួងអប់រំនិងរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើនចំនួនកុមារចូលរៀនឱ្យបានច្រើន ស្របតាមបរិបទសង្គម និងអន្តរជាតិ កុមារពេញវ័យអាយុ៧០ខែ ឬ៦ឆ្នាំត្រូវចូលរៀនថ្នាក់បឋមសិក្សា។ អាទិភាពនៃគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាក្នុងវិស័យអប់រំ គឺដើម្បីធានាឱ្យមានការទទួលបានសមភាព និងគុណភាពក្នុងរយៈ៩ឆ្នាំនៃការអប់រំមូលដ្ឋាន។ នៅខែឧសភា ឆ្នាំ២០០៣ រដ្ឋាភិបាលបានដាក់ចេញផែនការអប់រំ

សម្រាប់ទាំងអស់គ្នាសហការជាមួយ UNESCO ដើម្បីធានាគុណភាព និងប្រសិទ្ធភាពប្រសើរឡើង ថា ការកសាងសមត្ថភាពសម្រាប់វិមជ្ឈការតាមរយៈ ការបើកដំណើរការស្វ័យភាពសាលារៀន និងស្ថាប័ន (UNESCO2003)។ នៅក្នុងការគ្រប់គ្រងសាលារៀនមួយ នាយក ឬនាយិកាសាលាតែងជួបប្រទះបញ្ហាប្រឈមជាច្រើន ដែលមានការពិបាកក្នុងការដោះស្រាយ។ ការអនុវត្តការងារក្នុងសាលាមិនបានស្របតាមស្តង់ដាសាលាបឋមសិក្សាទាំង៩របស់ក្រសួងអប់រំ។ បើសិនមានលទ្ធភាពសម្របសម្រួលបញ្ហាទាំងនោះបាន ក៏ត្រូវចំណាយពេលវេលាយូរ ហើយរង់ចាំការសហការពីភាគីពាក់ព័ន្ធការិយាល័យអប់រំស្រុក ក្រុងខណ្ឌ មន្ទីរអប់រំរាជធានី ខេត្ត រហូតដល់ក្រសួងអប់រំព្រមទាំងរដ្ឋបាលរាជធានី ខេត្តទៀតផង។ បញ្ហាប្រឈមដែលសាលាជួបជាញឹកញយរួមមាន ការងារគ្រប់គ្រងបុគ្គលិកអប់រំ (សាលាខ្លះ គ្រូបង្រៀនខ្វះខាត ដោយបំពេញបន្ថែមនូវគ្រូកិច្ចសន្យា ហើយសាលាខ្លះទៀតគ្រូបង្រៀនគ្រប់ចំនួនឬអាចលើសតម្រូវការ)។ សាលាខ្លះទៀត យកគ្រូបឋមភូមិមកបង្រៀននៅកម្រិតបឋមសិក្សា។ មិនតែប៉ុណ្ណោះ បណ្ណាល័យសាលាខ្លះមិនសមស្របតាមស្តង់ដាក្រសួង។ រីឯសៀវភៅសិក្សាគោលមិនមានគ្រប់គ្រាន់តាមមុខវិជ្ជានីមួយៗ បម្រើឱ្យការសិក្សារបស់សិស្សនិងគ្រូ។ ចំនួនសិស្សក្នុងថ្នាក់អាចលើសពីនិយាម។ បាតុភាពអវិជ្ជមានផ្សេងៗកើតមានតិចតួចដូចជា សាលាខ្លះបាត់កង់ឬម៉ូតូ និងសម្ភារៈមួយចំនួនដោយមានជនខិលខូចបន្លំចូលសាលា។ ការអភិវឌ្ឍសាលារៀនមិនសូវទទួលបានការគាំទ្រពីសហគមន៍ទាំងស្រុង។ ការជួសជុលអគារ បន្ទប់រៀន បរិក្ខារសាលា ការរៀបចំបរិស្ថានរបស់សាលារៀន មានឧបសគ្គខ្លះៗចំពោះមុខ ជាពិសេសកង្វះខាតថវិកា។ បង្គន់អនាម័យសាលាមួយចំនួនមានមិនគ្រប់គ្រាន់បង្កផលវិបាកដល់សិស្សនិងគ្រូ។ ចំណែកវិន័យសាលាបានអនុវត្តល្អភាគច្រើន។ ផ្ទុយមកវិញ ការបង្រៀននិងរៀនជួបបញ្ហាតិចតួចដូចជា ខ្វះសម្ភារឧបទេសសម្ភារបង្រៀន សៀវភៅសិក្សា គោលវិធីសាស្ត្របង្រៀនថ្មីជាដើម។ សាលារៀនមួយចំនួនធំមិនទាន់បានអនុវត្តតាមនិយាមស្តង់ដាទាំង៩របស់ក្រសួង គឺបណ្តាលមកពីការខ្វះខាតឧបករណ៍សម្ភារៈនិងធនធានមនុស្សដូចជាបន្ទប់ពិសោធន៍ បន្ទប់រៀនភាសាបរទេស កុំព្យូទ័រ សិល្បៈតូរ្យតន្ត្រី ចម្លាក់គំនូរ សូនរូប រោងជាង អន្តេវាសិកដ្ឋាន អាហារូបករណ៍ ទស្សនកិច្ចសិក្សាគ្រូ និងសិស្ស អាហារពេលព្រឹកនិងថ្ងៃត្រង់ជាដើម។

## ១.៣-គោលបំណងនៃការស្រាវជ្រាវ

ទាក់ទងទៅនឹងការសិក្សាប្រធានបទ អំពីការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា ករណីសិក្សាខេត្តសៀមរាបនេះ គឺអ្នកស្រាវជ្រាវបានកត់សម្គាល់ឃើញពីគោលបំណងដូចខាងក្រោម៖

(១) រកឱ្យឃើញកម្រិតការអនុវត្តការគ្រប់គ្រងនិងដឹកនាំនៅតាមសាលាបឋមសិក្សា ធៀបនឹងស្តង់ដា

សាលាបឋមសិក្សា។
(២) រកឱ្យឃើញបញ្ហាប្រឈមនានា ក្នុងការអនុវត្តការគ្រប់គ្រងនិងដឹកនាំនៅតាមសាលាបឋមសិក្សាធៀបនឹងស្តង់ដាសាលាបឋមសិក្សា។

## ១.៤-សំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើសំណួរចំនួនពីរទាក់ទងប្រធានបទគឺ៖
(១).តើការគ្រប់គ្រងសាលារៀនរបស់នាយកសាលាធៀបនឹងស្តង់ដាសាលាបឋមសិក្សាអនុវត្តបានកម្រិតណា?
(២).តើការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សាជួបបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥-សារៈសំខាន់នៃការស្រាវជ្រាវ

បន្ទាប់ពីបានកំណត់គោលបំណង និងសំណួរស្រាវជ្រាវរួចមក អ្នកស្រាវជ្រាវបានមើលឃើញអំពីសារៈសំខាន់នៃការស្រាវជ្រាវមានដូចខាងក្រោម៖
-ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ នៅក្នុងការយល់ដឹងពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល និងធនធាននៅក្នុងសាលារៀន។
-ការអនុវត្តការងារសាលារៀនធៀបទៅនឹងស្តង់ដាសាលាបឋមសិក្សា។
-ការចូលរួមក្នុងប្រព័ន្ធការគ្រប់គ្រងសាលារៀន តម្រូវឱ្យធ្វើផែនការអភិវឌ្ឍសាលារយៈពេល៥ឆ្នាំ ជាមួយមាតាបិតាសិស្ស និងសហគមន៍ជាដៃគូ និងនាយកសាលា ឬអ្នកដឹកនាំសាលាលើការវាយតម្លៃលទ្ធផលសិក្សា និងតម្រូវការសិក្សារបស់សិស្ស។
-នាយកសាលាត្រូវមានតួនាទីចាត់ចែងទទួលខុសត្រូវការងារសាលា និងប្រគល់ភារកិច្ចដល់បុគ្គលិកឱ្យមានតម្លាភាព សុក្រឹតភាព ការប្រើប្រាស់ថវិកាមានខ្ទង់ចំណូលនិងចំណាយត្រឹមត្រូវ។
-បង្កើតគំនិតយុទ្ធសាស្រ្ត និងនវានុវត្តន៍ ពង្រឹងគណនេយ្យភាពអភិវឌ្ឍទេពកោសល្យ លើកទឹកចិត្តបុគ្គលិក។
-កំណត់ពីចំណុចខ្វះខាតដែលសាលារៀនត្រូវបំពេញ និងតម្រូវការមូលដ្ឋានចាំបាច់នៅសាលា។
-ពង្រឹងសមត្ថភាពដល់គណៈគ្រប់គ្រងសាលារៀនលើការងារដឹកនាំ និងគ្រប់គ្រង។
-ការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន រៀន និងកែលម្អគុណភាពអប់រំនៃការសិក្សានៅសាលារៀន។

## ១.៦-វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

**-វិសាលភាព៖** ការស្រាវជ្រាវនេះធ្វើឡើង នៅសាលាបឋមសិក្សាចំនួន១៤ក្នុងខេត្តសៀមរាប ទៅលើគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនថ្នាក់ទី១ដល់ទី៦ និងសហគមន៍ទាក់ទងទៅនឹងការអនុវត្តការគ្រប់គ្រងសាលារៀនធៀបទៅនឹងស្តង់ដាសាលាបឋមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា។នៅក្នុងនោះមានការចូលរួមបំពេញកម្រងសំណួរពីសំណាក់នាយក នាយិកា នាយករង នាយិការង២៦

នាក់(ស្រី៩នាក់) គ្រូបង្រៀន២៧៦នាក់(ស្រី២២៣នាក់) សហគមន៍៨៤នាក់(ស្រី៧១នាក់)។ រយៈពេលប្រមូលទិន្នន័យនេះចាប់ផ្តើមពីថ្ងៃទី០៧ ខែធ្នូដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ លើទីតាំង៦សង្កាត់ក្នុងក្រុងសៀមរាបរួមមាន សង្កាត់ជ្រាវ៣សាលា សង្កាត់សាលាកំរើក៣សាលា សង្កាត់គោកចក២សាលា សង្កាត់ស្វាយដង្គំ២សាលា សង្កាត់ស្លក្រាម៣សាលា និងសង្កាត់ស្រង៉ែ១សាលា។

**-ដែនកំណត់៖** ការស្រាវជ្រាវនេះ ធ្វើឡើងចំពោះសាលាបឋមសិក្សា១៤ ក្នុងចំណោមសាលាបឋមសិក្សា៥៣សាលា៨កម្រងក្នុងក្រុង ខេត្តសៀមរាប។ អាស្រ័យដោយពេលវេលា ឯកសារនិងធនធានមានកំណត់ទើបអ្នកសិក្សាមិនអាចលើកយកសាលាផ្សេងទៀត ក្រៅពីសាលាខាងលើសម្រាប់ការសរសេរនិក្ខេបបទនេះ។

## ១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា៥ជំពូក៖

-ជំពូកទី១៖សេចក្តីផ្តើមដោយលើកឡើងពីសារតារ បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ។

-ជំពូកទី២៖ រំលឹកទ្រឹស្តីគឺការប្រមូលយកឯកសារ ឬទ្រឹស្តីពាក់ព័ន្ធប្រធានបទផ្សេងៗឬអ្នកសិក្សាស្រាវជ្រាវមុនៗយកមកធ្វើជាគំនិតធ្វើការស្រាវជ្រាវថ្មី ដើម្បីបង្កើតស្នាដៃថ្មី។

-ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ គឺបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ និងប្រភេទគំរូសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យជាដើម។

-ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវនិងការពិភាក្សា គឺការយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយរកឱ្យឃើញនូវកម្រិតនៃការអនុវត្តស្តង់ដាសាលាបឋមសិក្សា និងបញ្ហាប្រឈមនៃការគ្រប់គ្រងសាលារៀនរបស់នាយកសាលា និងគ្រូបង្រៀន។

-ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរជាការសន្និដ្ឋានទៅលើទិន្នន័យដែលបានប្រមូលនិងវិភាគព្រមទាំងផ្តល់ជាការសំណូមពរមួយចំនួនទាក់ទងប្រធានបទ។

# ជំពូកទី២៖ ការរំលឹកទ្រឹស្តី

## ២.១-សេចក្តីផ្តើម

សាលារៀនជាគ្រឹះស្ថានសាធារណៈរបស់រដ្ឋ។ សិស្សនិងគ្រូមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការសាលារៀនក្រោមការគ្រប់គ្រង និង ដឹកនាំផ្ទាល់របស់ប្រធានអង្គភាព គឺនាយកសាលា។ នៅក្នុងគោលការណ៍កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ឆ្នាំ២០១៨ថា ការតែងតាំងនាយកសាលារៀនចំណោះទូទៅត្រូវជ្រើសរើសក្នុងចំណោមបុគ្គលិកអប់រំ គ្រូបង្រៀនដែលមានសញ្ញាបត្រវិជ្ជាជីវៈនាយកសាលាដើម្បីឆ្លើយតបទៅនឹងស្តង់ដានាយកសាលារៀន។ នាយកសាលាយ៉ាងហោចណាស់ មានអតីតភាពការងារ៥ឆ្នាំជាគ្រូបង្រៀន ហើយមានបំណិនការរៀបចំបច្ចេកទេសបង្រៀន ពិនិត្យការងារបង្រៀន រៀបចំផែនការ ការចាត់ចែងការងារ ចេះសម្របសម្រួល ការចរចាប្រាស្រ័យ ទាក់ទងគ្រប់គ្រង និងដឹកនាំគរុកោសល្យ។ សមត្ថភាព ការយល់ដឹងពីវិធីសាស្ត្រគ្រប់គ្រងការងារ និងបុគ្គលិករបស់អង្គភាពយល់ដឹងអំពីលិខិតគតិយុត្តផ្សេងៗ ដែលពាក់ព័ន្ធការងារ និងអាចបកស្រាយពន្យល់ដល់អ្នកនៅក្រោមបង្គាប់ គ្រប់គ្រងអារម្មណ៍ដឹកនាំ និងមានការចងចាំបានល្អ អាចប្រើប្រាស់Computer និងយល់ដឹងការងារសវនកម្ម។

## ២.២-និយមន័យពាក្យគន្លឹះ

នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ ជាដំបូងត្រូវសិក្សាពាក្យការគ្រប់គ្រង សាលារៀនស្តង់ដា និងស្តង់ដាសាលាបឋមសិក្សាជាមុនសិន។ គ្រប់គ្រងតាមវចនានុក្រមខ្មែរ សម្តេចសង្ឃរាជជួនណាត ឆ្នាំ១៩៦៧មានន័យថា បីបាច់ ថែរក្សា រងខុសត្រូវលើខ្លួន។

ការគ្រប់គ្រងគឺការសម្រេចជោគជ័យនូវគោលដៅរបស់អង្គភាព អាជីវកម្មដោយប្រើប្រាស់នូវមុខងារសំខាន់បួនរួមមានការធ្វើផែនការ ការចាត់តាំង ការដឹកនាំនិងត្រួតពិនិត្យ (គោលការណ៍គ្រឹះនៃការគ្រប់គ្រងRULE)។ ការគ្រប់គ្រងជាការរៀបចំ (Preparing) ចាត់ចែង (Organizing) និងអនុវត្ត (Implementing) នូវរាល់វត្ថុ(Things) ទាំងអស់នៅក្នុងសាលាដូចជា ការវិភាគ ថវិកា របាយការណ៍ ការបញ្ជាទិញនិងទទួលនូវសៀវភៅសិក្សា និងសម្ភារៈដទៃទៀត ការរក្សាទីធ្លាសាលាឱ្យស្អាតនិងស្រស់បំព្រង ការធ្វើរបងសាលា។ល។ (ក្រសួងអប់រំ ២០១៦)។ ការគ្រប់គ្រងគឺជាការនូវប្រើប្រាស់ធនធានមនុស្សនិងធនធានផ្សេងៗដើម្បីសម្រេចបាននូវគោលបំណងទាំងឡាយ(ចំណេះដឹងទូទៅ ២០១៧)។ ការគ្រប់គ្រងគឺជាដំណើរការចាត់ចែងការងារដោយប្រើប្រាស់ធនធានមនុស្ស សម្ភារៈ និងថវិកាប្រកបដោយប្រសិទ្ធភាពឆ្ពោះទៅសម្រេចគោលដៅរបស់អង្គភាព (ក្រសួងអប់រំ ២០១២)។

រីឯមូលដ្ឋានគ្រឹះនៃការបញ្ញត្តិការគ្រប់គ្រងសាលារៀន បានក្លាយពីពាក្យសាលារៀន(School) មានន័យថា វប្បធម៌ និងការគ្រប់គ្រង (Management) មានន័យថា តម្លៃ (Brian J.Caldwell2005

SBM UNESCO, Paris,p11)។សាលារៀនជាគ្រឹះស្ថានសិក្សាមួយដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវកន្លែងអង្គុយនិងបរិស្ថានសិក្សាសម្រាប់បង្រៀនសិស្សស្ថិតនៅក្រោមការណែនាំរបស់គ្រូ(បណ្ឌិត គួយ សូគាន ២០១៩)។ សាលារៀនជាកន្លែងសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស។ សាលារៀនជាមជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលវិជ្ជាគ្រប់ផ្នែកដែលមានប្រយោជន៍ដល់ពលរដ្ឋ។ សាលារៀនជាកន្លែងមានគ្រូ សិស្សនិងមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តសមស្រប (ក្រសួងអប់រំ ២០១៦)។ សាលារៀនជាមជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលពលរដ្ឋឱ្យមានសមត្ថភាព និងគុណធម៌ដល់គ្រូ និងសិស្ស ដើម្បីរួមចំណែកអភិវឌ្ឍសហគមន៍ក៏ដូចជាប្រទេសឱ្យរីកចម្រើនតាមរយៈ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់បម្រើការបង្រៀនរៀនសមស្រប មានវិធីសាស្ត្រគរុកោសល្យ បរិស្ថានស្អាត និងការគ្រប់គ្រងការដឹកនាំល្អសម្រាប់ធានាដល់ដំណើរការប្រព្រឹត្តទៅដោយប្រសិទ្ធភាពនិងនិរន្តភាព (បាន គនហេង ២០១៩)។សាលារៀនឬសាលាបង្រៀនមន្ទីរសម្រាប់បង្រៀនវិជ្ជារោងរៀន(វចនានុក្រមខ្មែរ ១៩៦៧)។ ស្តង់ដាសម្រាប់កំណត់គុណភាព និងបរិមាណរបស់វត្ថុ ឬសមត្ថភាពរបស់មនុស្ស ទៅតាមមុខរបរឬអាជីពផ្សេងៗគ្នា (ក្រសួងអប់រំ ២០១៦)។ ស្តង់ដាសំដៅលើក្បួនខ្នាតគំរូមានលក្ខណៈសមស្រប ដែលអ្នកប្រើភាគច្រើនអាចទទួលយកបាន (គណៈរដ្ឋមន្ត្រី ២០១៩)។ ស្តង់ដាជាហេដ្ឋារចនាសម្ព័ន្ធ និងសេវាធានាឱ្យមានគុណភាព សមធម៌ និងបរិយាបន្ននៅក្នុងសាលារៀន (ក្រសួងអប់រំ ២០១៨)។ស្តង់ដាគឺម៉ែត្រសម្រាប់វាស់(បណ្ឌិត ស៊ន សេងហុក ២០១៩ )។ចំណែកស្តង់ដាសាលាបឋមសិក្សាជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាបឋមសិក្សា ផ្តោតទៅលើបរិមាណនៃការចូលរៀន ការសិក្សាគុណភាពនៃលទ្ធផលសិក្សារបស់សិស្ស ការងារដឹកនាំគ្រប់គ្រងរបស់នាយក ការបង្រៀនរបស់គ្រូ ការរៀនសូត្ររបស់សិស្ស ការចូលរួមរបស់កុមារ មាតាបិតា សហគមន៍ អ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន ( ក្រសួងអប់រំ ២០១៧)។

## ២.៣-ទ្រឹស្តីពាក់ព័ន្ធ

នៅក្នុងការសិក្សាស្រាវជ្រាវអំពីប្រធានបទ «ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា» មានទ្រឹស្តីពាក់ព័ន្ធមួយចំនួនដូចជា ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ស្តង់ដានាយកសាលារៀន ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ក្រមសីលធម៌វិជ្ជាជីវៈនាយកសាលា ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ បំណិនវិជ្ជាជីវៈ ស្វ័យភាពនិងគោលដៅសាលារៀន ស្វ័យវាយតម្លៃសាលារៀន យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា មូលនិធិដំណើរការសាលារៀន ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ កម្មវិធីសាលាកុមារមេត្រី និយាមការប្រើប្រាស់បុគ្គលិកអប់រំ ស្តង់ដាសាលាបឋមសិក្សា និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

### *២.៣.១-ការគ្រប់គ្រងសាលារៀនសតវត្សទី២១*

ការគ្រប់គ្រងសាលារៀន ជាផ្នែកមួយនៃកំណែទម្រង់វិស័យអប់រំឆ្នាំ២០១៨-២០២៣ របស់

ក្រសួងអប់រំ គឺការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត និងពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ព្រមទាំងការយកចិត្តទុកដាក់លើគ្រូបង្រៀន។ ការគ្រប់គ្រងសាលារៀនជាការធ្វើវិមជ្ឈការនៃសិទ្ធិអំណាច ពីរដ្ឋាភិបាលទៅដល់កម្រិតសាលារៀន។ ការទទួលខុសត្រូវនិងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងដំណើរការសាលារៀនត្រូវបានផ្ទេរទៅដល់ភ្នាក់ងារនៅមូលដ្ឋាន(នាយកសាលា)។ ក្រសួងអប់រំក៏បានដាក់ចេញនូវគោលនយោបាយស្តីពីគ្រូបង្រៀន និងផែនការសកម្មភាពគ្រង់យុទ្ធសាស្ត្រទី៨ គឺការពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន។ នៅក្នុងយុគសម័យឌីជីថលនេះ នាយកសាលាមានតួនាទីក្នុងការគ្រប់គ្រងសាលា ដោយពង្រឹងគុណភាពអប់រំតាមរយៈកម្មវិធីសិក្សាសមស្របតាមសេដ្ឋកិច្ចសង្គម និង បរិបទអរិយធម៌របស់ប្រទេស បរិបទបច្ចេកវិទ្យានិងសកលភាវូបនីយកម្ម ជាពិសេសការអភិវឌ្ឍគុណវុឌ្ឍិនាយកឱ្យបានសមស្រប។ សាលាមានឧបករណ៍ និងសម្ភារគ្រប់គ្រាន់។ ការវាយតម្លៃការសិក្សាប្រកបដោយប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ ហើយបរិស្ថានសាលាល្អ។

សេចក្តីណែនាំស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលលេខ២៧ អយក សណន ចុះថ្ងៃទី២៨ មិថុនា ឆ្នាំ២០១៦ បង្ហាញចំណុចមួយចំនួន ដែលនាយកត្រូវទទួលរ៉ាប់រងនូវការងារជាច្រើន និងភារកិច្ចចាំបាច់មួយចំនួន ក្នុងការដឹកនាំនិងគ្រប់គ្រងសាលារៀន ឱ្យមានដំណើរការជានិរន្តតាមរយៈនាយកសាលា ត្រូវពង្រឹងការងារកសាងផែនការផ្អែកលើឯកសារនិងវិធីសាស្ត្រ (ការគ្រប់គ្រងរដ្ឋបាល បំណិនវិជ្ជាជីវៈ និងការគ្រប់គ្រងហិរញ្ញវត្ថុជាដើម)។ ការងារឆ្លើយតបបញ្ហាប្រឈមដូចជាសិស្សរៀនត្រួតថ្នាក់ បោះបង់ការសិក្សា លទ្ធផលតេស្ត ការរៀបចំដំណើរការរៀននិងបង្រៀនឱ្យមានប្រសិទ្ធភាព។ ការវាយតម្លៃគ្រូបង្រៀនផ្អែកលើសមត្ថភាព បទពិសោធន៍ និងលទ្ធផលសិក្សារបស់សិស្ស (ពិន្ទុប្រចាំខែ ឆមាស និងប្រចាំឆ្នាំ)។ នាយកត្រូវប្រកាន់ភ្ជាប់គោលការណ៍អភិបាលកិច្ចល្អមានតម្លាភាព គណនេយ្យភាព និង ការចូលរួមដោយប្រើប្រាស់ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ សម្ភាររូបវន្តនិងដីធ្លី។

## ២.៣.២-ស្វ័យភាពនិងគោលដៅរបស់សាលារៀន

នៅក្នុងការគ្រប់គ្រងសាលារៀនសាធារណៈមួយ នាយកត្រូវមានស្វ័យភាពនិងគោលដៅមួយច្បាស់លាស់សម្រាប់ដំណើរការសាលារៀន។ ស្វ័យភាពសាលារៀនគឺស្ថិតនៅក្នុងប្រព័ន្ធនៃការអប់រំដែលត្រូវបានធ្វើវិមជ្ឈការរួមមានសិទ្ធិអំណាច និងការទទួលខុសត្រូវដើម្បីធ្វើការសម្រេចចិត្តទាក់ទងនឹងការបែងចែកធនធាន ជាលក្ខណៈកណ្តាលនៅក្នុងក្របខណ្ឌនៃស្តង់ដា និងគណនេយ្យភាពនៃគោលនយោបាយជាគោលដៅដែលត្រូវបានកំណត់(បណ្ឌិត ថៅ សារ៉ាត់ហ៊ុំ២០១៩)។ ស្វ័យភាពរបស់នាយកសាលាគឺមានប្រតិទិនប្រជុំពិនិត្យតាមដានប្រចាំខែ តេស្តវង្វាយតម្លៃសមត្ថភាពសិក្សាសិស្ស

ការបង្រៀនសិស្សខ្សោយ ការប្រជុំនិងការបំប៉នបច្ចេកទេស ការធ្វើអធិការកិច្ចរបស់នាយក និងអប់រំស្រុក ការរៀបចំផែនការកែលម្អសាលារៀន និងការបិទផ្សាយ ការបំប៉ននាយក ការធ្វើស្វ័យវាយតម្លៃសាលារៀន ការរកមូលនិធិ និងការគ្រប់គ្រងហិរញ្ញវត្ថុ ការបិទផ្សាយលទ្ធផលសិក្សាចំណូលនិងចំណាយ ការអនុវត្តផែនការ ការគ្រប់គ្រងទិន្នន័យនិងការរាយការណ៍។ ចំណែកគោលដៅនៃការគ្រប់គ្រងសាលារៀនវិញគឺត្រូវមានស្វ័យភាពគណនេយ្យភាព ការវាយតម្លៃ (ការធ្វើតេស្តនិងប្រឡង) សុវត្ថិភាពសិស្ស បរិស្ថានក្នុងថ្នាក់និងសាលារៀន បច្ចេកទេសវិធីសាស្រ្តបង្រៀន សុខភាពអនាម័យសិស្ស ការងារជួសជុលសាងសង់ ការចូលរួមរបស់មាតាបិតា និង សហគមន៍ក្នុងគណៈកម្មការគ្រប់គ្រងសាលារៀន (បឋមសិក្សាបន្ទាយឈើ ២០១៨)។

## ២.៤-គោលដៅនិងសមាសភាពទាំង៥នៃការអប់រំ

*ក.គោលដៅអប់រំជាតិ*

ក្រសួងអប់រំបានកំណត់គោលដៅសម្រាប់ការអប់រំ គឺធ្វើឱ្យសិស្សក្លាយជាមនុស្សពេញលេញរីកចម្រើនលូតលាស់គ្រប់ផ្នែក ដោយមានតុល្យភាពរាងវៃ ប្រាជ្ញាស្មារតីសញ្ចេតនា និងរូបកាយ។ គោលដៅនេះកសាងបានពលរដ្ឋថ្លៃថ្នូរឱ្យមានចំណេះដឹង បំណិន និងឥរិយាបថ។ ចំណេះដឹងគឺពលរដ្ឋល្អមានការយល់ដឹងទូលំទូលាយ។ បំណិន (ចំណេះធ្វើ) ពលករជំនាញនិងឥរិយាបថជាពលរដ្ឋថ្លៃថ្នូរមានសីលធម៌និងគុណធម៌។ មិនតែប៉ុណ្ណោះ ការអប់រំនាំឱ្យសិស្សក្លាយជាពលរដ្ឋសាកលជាធាតុសំខាន់មួយនៅក្នុងជំនាញសតវត្សទី២១ ស្របទៅនឹងស្តង់ដាបឋមសិក្សាមាន៥យ៉ាង គឺស្អាតរបៀប សុខភាព ទៀងពេល និងសមាធិ (ក្រសួងអប់រំ ២០១៧)។

*ខ.បញ្ញត្តម្ភឬសមាសភាពទាំង៥នៃការអប់រំ*

សាលារៀនសុទ្ធមានគោលនយោបាយ ទស្សនវិស័យច្បាស់លាស់ ការចូលរួមគាំទ្រពីសហគមន៍ ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុល្អប្រកបដោយតម្លាភាព មានបរិស្ថាន ប្រកបដោយសុវត្ថិភាពសោភ័ណភាពជាទីពេញចិត្ត មានអត្រាឡើងថ្នាក់ខ្ពស់ អត្រាបោះបង់ការសិក្សាទាប ប្រមូលកុមារអាយុ៦-១១ឆ្នាំឱ្យចុះឈ្មោះចូលរៀន (ក្រសួងអប់រំ ២០១៥)។ រីឯការអប់រំត្រូវមានសមាសភាព៥យ៉ាងដូចជា អប់រំសីលធម៌ អប់រំបញ្ញា អប់រំកាយនិងកីឡា អប់រំពលកម្ម និងអប់រំសោភ័ណ។ ដោយឡែកសសរស្តម្ភទាំង៥នៃការអប់រំថ្នាក់បឋមសិក្សារួមមាន វិន័យ អនាម័យ បៃតង គុណភាព និងសុខដុម (បឋមសិក្សាមុខនាគ ២០១៩)។

## ២.៥-ការបំប៉នសមត្ថភាពគណៈគ្រប់គ្រងសាលារៀន

ការគ្រប់គ្រងសាលារៀន ឬការគ្រប់គ្រងអាស្រ័យតាមសាលារៀន ត្រូវបានក្រសួងអប់រំរៀបចំបើកវគ្គបំប៉នជូននាយកសាលាបឋមសិក្សា និងមធ្យមសិក្សា ក្នុងការពង្រឹងភាពជាអ្នកដឹកនាំនៃគ្រឹះស្ថានសិក្សា។ ការគ្រប់គ្រងសាលារៀននេះ ក្រសួងបានផ្តោតការយកចិត្តទុកដាក់ចំពោះនាយកថ្មី

និងចាស់ ដោយឱ្យឆ្លងកាត់វគ្គបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំ និងតាមបណ្តារាជធានី ខេត្ត។ យ៉ាងណាមិញ ការបណ្តុះបណ្តាលនេះមាន ការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត។

**-ការបណ្តុះបណ្តាលដំបូង** (Pre Service) វិទ្យាស្ថានជាតិអប់រំបានបណ្តុះបណ្តាលវគ្គនាយកសាលាបាន២ជំនាន់ចំនួន៣១នាក់ (ស្រី១នាក់) ត្រឹមឆ្នាំ២០១៩។ គោលបំណងដើម្បីអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំដែលចង់ក្លាយ ជានាយកឬនាយករងឱ្យស្របតាមស្តង់ដានាយកសាលារៀន (ក្រសួងអប់រំ ២០១៨)។

**-ការបណ្តុះបណ្តាលបន្ត** (In Service) គឺនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ ជាមួយនាយកដ្ឋានបឋមសិក្សា មធ្យមសិក្សានិងវិទ្យាស្ថានជាតិអប់រំ បានរួមសហការគ្នាបើកវគ្គបំប៉នទៅលើការគ្រប់គ្រងសាលារៀនដល់នាយក នាយករង នាយិកា នាយិការង ដើម្បីបានជាមូលដ្ឋានគ្រឹះនៅក្នុងការអនុវត្តការងារក្នុងអង្គភាពឱ្យទទួលបានប្រសិទ្ធភាពកាន់តែប្រសើរឡើង។ ម្យ៉ាងទៀត នាយកដ្ឋានពាក់ព័ន្ធបានបោះពុម្ពសៀវភៅបន្ថែមទាក់ទងការងារនាយកមានដូចជា សៀវភៅការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ បំណិនវិជ្ជាជីវៈនិងសៀវភៅជំនួយស្មារតីការគ្រប់គ្រងសាលាជាដើម។ ថ្មីៗនេះទៀតសោតក្រសួងអប់រំសហការជាមួយវិទ្យាស្ថានជាតិអប់រំនៃសឹង្ហបុរី និង មូលនិធិថេម៉ាសេកអន្តរជាតិបានរៀបចំការបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំសាលារៀនដល់នាយក នាយករង ឱ្យមានសក្តានុពលក្នុងការដឹកនាំ និងគ្រប់គ្រងដំណើរការអប់រំថែមទៀត។

## ២.៦-រចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៧ ស្តីពីគោលនយោបាយ និងនីតិវិធីគ្រប់គ្រងសាលារៀនសម្រាប់បឋមសិក្សាបង្ហាញពីរចនាសម្ព័ន្ធគ្រប់គ្រងសាលារៀនឬអង្គការលេខរបស់សាលារៀនរួមមាន៩ផ្នែកធំៗដូចជា៖

*ក.ក្រុមប្រឹក្សាភិបាល/គណៈកម្មការអភិវឌ្ឍសាលារៀន* រួមមាន ប្រធាន អនុប្រធាន លេខាធិការ បេឡា និងសមាជិក។ ប្រធាន អនុប្រធាន និងបេឡា នឹងត្រូវបោះឆ្នោតជ្រើសតាំងក្នុងរយៈពេល២ឆ្នាំម្តងដោយសមាជិកក្រុមប្រឹក្សាភិបាលរបស់សាលារៀន។ ចំណែកសមាជិកក្រុមប្រឹក្សាភិបាលនឹងត្រូវជ្រើសតាំងតាមរយៈការបោះឆ្នោតដោយក្រុមប្រឹក្សាកុមារ គ្រូបង្រៀន នាយកសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន ប្រធានក្រុម ប្រធានភូមិ និងក្រុមប្រឹក្សាឃុំ។

*ខ.គណៈកម្មការគ្រប់គ្រងសាលារៀន* មាន៥ទៅ៨នាក់រួមមាន ប្រធានកិត្តិយស ទីប្រឹក្សា ប្រធាន អនុប្រធាននិងសមាជិក។

*គ.គណៈគ្រប់គ្រងសាលារៀន* រួមមាន នាយក១នាក់ នាយករង២នាក់ ប្រធានក្រុមបច្ចេកទេសតាមកម្រិតថ្នាក់៦នាក់និងបណ្ណារក្ស១នាក់។

*ឃ.ក្រុមប្រឹក្សាកុមារ* មាន២កម្រិតគឺ៖

-កម្រិតថ្នាក់រៀន(គណៈកម្មាធិការសាខា) មាន ប្រធាន១នាក់ អនុប្រធាន២នាក់ និងសមាជិក៦នាក់ សម្រាប់សិស្សថ្នាក់ទី៤ ទី៥ ទី៦។ ចំណែកគ្រូប្រចាំថ្នាក់ជាទីប្រឹក្សា។

-កម្រិតសាលារៀន (គណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារ)មាន ប្រធាន១នាក់ អនុប្រធាន២នាក់ និងសមាជិកយ៉ាងតិចចំនួន៨នាក់។ ការងារស្នូលរបស់សមាជិកទាំង៨មាន វិន័យ និងចលនាកុមារបីល្អ ការសិក្សា និងបណ្ណាល័យ សង្គ្រោះ និងជួយសង្គម រដ្ឋបាលនិងហិរញ្ញវត្ថុ ផ្សព្វផ្សាយ សិល្បៈ កីឡានិងវប្បធម៌ សុខភាព អនាម័យ បរិស្ថាន បំណិនជីវិតនិងក្លឹប (ក្រុមធនធានវ័យក្មេង)។

## *២.៦.១-បំណែងចែកតួនាទីនិងភារកិច្ចបុគ្គលិកអប់រំ*

### *ក.តួនាទីនិងភារកិច្ចនាយកសាលា*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំបង្ហាញអំពីតួនាទីនិងភារកិច្ចនាយកសាលាមានដូចខាងក្រោម៖

-ជាអាជ្ញាធរអប់រំ: ដឹកនាំគ្រប់សកម្មភាព និងធានាបាននូវប្រសិទ្ធភាព តាមគោលដៅអប់រំដែលបានគ្រោងទុក និងទទួលខុសត្រូវទាំងស្រុងចំពោះមុខសាលារៀន។

-ជាមន្ត្រីរដ្ឋបាល: ជាអ្នកណែនាំអនុវត្តរដ្ឋបាលសិក្សាទាំងអស់ ដែលធានាធ្វើឱ្យសម្រេចគោលនយោបាយអប់រំ ការចាត់ចែងសកម្មភាព និងបែងចែកភារកិច្ចឱ្យបុគ្គលិក ប្រកបដោយប្រសិទ្ធភាព ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

-ជាទីប្រឹក្សាគរុកោសល្យ: ណែនាំគរុកោសល្យដល់គ្រូបង្រៀន អំពីល្បិចវិធីបង្រៀន និងគន្លឹះល្អៗការបង្រៀនព្រមទាំងស្វ័យសិក្សា និងអភិវឌ្ឍសម្បទាចិត្តគរុកោសល្យ ដោយខ្លួនឯងឥតឈប់ឈរ។

-ជាអធិការអចិន្ត្រៃយ៍: រៀបចំផែនការធ្វើអធិការកិច្ចច្បាស់លាស់ រួចផ្សព្វផ្សាយដល់គ្រូបង្រៀននិងមានសិទ្ធិត្រួតពិនិត្យកែលម្អសកម្មភាពអប់រំ ជាពិសេសសកម្មភាពបង្រៀន និងរៀន។

-ជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍: មានទំនាក់ទំនងល្អជាមួយសហគមន៍ អាជ្ញាធរដែនដី និងស្ថាប័ននានា ដើម្បីជាគុណប្រយោជន៍ដល់បុគ្គលិក គ្រូបង្រៀន និងអង្គភាពរបស់ខ្លួន។

ក្រៅពីតួនាទីខាងលើ នាយកសាលានៅមានភារកិច្ចចំនួន៣ទៀតដូចជា៖

**-ការងាររដ្ឋបាល:** កសាងចក្ខុវិស័យ បេសកកម្ម និងផែនការសកម្មភាព ដើម្បីអភិវឌ្ឍអង្គភាព។ ការកសាងរចនាសម្ព័ន្ធគ្រប់គ្រងនិងវិភាគមុខងារ ការដឹកនាំប្រជុំអង្គភាពរបស់សាលារៀន និងផ្សព្វផ្សាយលិខិតគតិយុត្ត។ ការបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ ឱ្យអនុវត្តការងារតាមតួនាទី និងភារកិច្ចព្រមទាំងការងារមួយចំនួនទៀត។ ទាក់ទងការងារនេះ នាយកត្រូវកសាងផែនការ ការងារប្រចាំថ្ងៃ ប្រចាំឆមាសនិងឆ្នាំ។ បែងចែកភារកិច្ចដល់បុគ្គលិកក្រោមឱវាទ រៀបចំបរិស្ថាន សោភ័ណភាពសាលា អនាម័យនិងសណ្តាប់ធ្នាប់។ រៀបចំនិងដឹកនាំការប្រជុំប្រចាំខែ ឆមាស ឆ្នាំ។ រៀបចំឱ្យមានការ

បណ្តុះបណ្តាលនៅនឹងកន្លែង ឬក្រៅសាលា។ នាយកដើរតួនាទីជាអាជ្ញាកណ្តាលក្នុងការផ្សះផ្សារទំនាស់ក្នុងសាលានិងគ្រប់គ្រងមូលដ្ឋានសម្ភារ។

**-ការងារបច្ចេកទេសគរុកោសល្យ:** ការគ្រប់គ្រងសកម្មភាពបង្រៀន និងរៀន ការធ្វើកាលវិភាគបំណែងចែកកម្មវិធីសិក្សា អធិការកិច្ចគ្រូបង្រៀន ដឹកនាំការប្រជុំបច្ចេកទេស ប្រជុំគរុកោសល្យ ការប្រជុំថ្នាក់កម្រងនិងផ្សព្វផ្សាយសារាចរណែនាំនានា វាយតម្លៃលទ្ធផលសិក្សាជាដើម។នាយកត្រូវរក្សាឱ្យបានខ្ជាប់ខ្ជួន នូវតួនាទីជាទីប្រឹក្សាគរុកោសល្យ។ ជាអ្នកត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សាគ្រប់ថ្នាក់ ចូលរួមបំប៉នគ្រូបង្រៀនតាមរយៈ ការទស្សនកិច្ចសិក្សាថ្នាក់រៀនសហការជាមួយគ្រូដើម្បីពង្រឹងគុណភាពបង្រៀននិងរៀន។ ជំរុញការប្រជុំបច្ចេកទេស មានរបៀបវារៈច្បាស់លាស់លើកទឹកចិត្តគ្រូឱ្យស្រាវជ្រាវវិធីសាស្រ្តបង្រៀនថ្មីៗ និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប់ជាប្រចាំ។

**-ការងារទំនាក់ទំនង:** ការងារទំនាក់ទំនងខាងក្នុងជាមួយបុគ្គលិក គ្រូបង្រៀនស្ថិតនៅក្នុងអង្គភាព។ រីឯការងារខាងក្រៅជួបមាតាបិតាសិស្ស សហគមន៍ អាជ្ញាធរដែនដី សប្បុរសជនជាតិ និងអន្តរជាតិស្ថាប័ននានា។ បណ្ឌិត នូវ វីរ៉ា លើកឡើងថា ក្រៅពីតួនាទី និងភារកិច្ចខាងលើ នាយកត្រូវបំពេញការងារប្រចាំថ្ងៃទៀតដូចជាការពិនិត្យមើលបរិស្ថាន ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និយ័តភាពការងារ និងត្រួតពិនិត្យវាយតម្លៃ ការផ្តល់សេវាការគ្រប់គ្រងទិន្នន័យ ស្ថិតិបុគ្គលិក ថ្នាក់រៀន និងថវិកា។

***ខ.ភារកិច្ចរបស់នាយករង***

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំបង្ហាញអំពីភារកិច្ចនាយករងមានដូចខាងក្រោម៖

ភារកិច្ចរបស់នាយករងសាលា គឺធ្វើឡើងតាមរយៈការបែងចែកការងាររបស់នាយកសាលា។ នាយករងទទួលបន្ទុកការងាររដ្ឋបាល លិខិតស្នាម និងរក្សាទុកលិខិត។ ការងារបរិស្ថាន សោភ័ណភាពនិងអនាម័យ រក្សាសណ្តាប់ធ្នាប់និងវិន័យក្នុងសាលា ធ្វើរបាយការណ៍ព្រមទាំងចូលរួមសកម្មភាពផ្សេងៗក្នុងសាលានិងសង្គម។ នាយករងទទួលបន្ទុកការងារបច្ចេកទេស គរុកោសល្យនិងរៀបចំប្រជុំក្រុមបច្ចេកទេស និងពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូ និងចុះវាយតម្លៃគ្រូ រៀបចំសិស្សតាមថ្នាក់រៀន ប្រជុំកម្រងជាដើម។ ការងារកុមារ កីឡានិងសិល្បៈ ក្រុមប្រឹក្សាកុមារ សាខាកុមារតាមថ្នាក់ និងចលនាបីល្អនិងចូលរួមដោះស្រាយបញ្ហាផ្សេងៗក្នុងសាលាថែមទៀតផង។

***គ.ភារកិច្ចជាសិក្ខាបនធារី***

តាមឯកសារប្រើប្រាស់ផ្ទៃក្នុងរបស់វិទ្យាល័យហ៊ុនសែនស្វាយធំនៅឆ្នាំ២០១៦ បានបង្ហាញអំពីភារកិច្ចសិក្ខាបនធារីមានដូចខាងក្រោម៖

សិក្ខាបនធារីឬគ្រូបង្រៀនមានភារកិច្ចបង្រៀននិងអប់រំ។ ទាក់ទងការងារបង្រៀនមានដូចជា៖

**-ការងាររដ្ឋបាល ៖** មានសៀវភៅកិច្ចតែងការ សៀវភៅសេវាប្រចាំថ្ងៃ សៀវភៅកត់ត្រាប្រជុំបច្ចេក

ទេស ប្រជុំទូទៅ សៀវភៅសម្រង់ពិន្ទុ និងសៀវភៅសម្រង់អវត្តមាន)។ ក្រៅពីការងារទាំងនេះត្រូវត្រួតពិនិត្យអវត្តមានអនាម័យក្នុងនិងក្រៅថ្នាក់ជាប្រចាំក្នុងម៉ោងបង្រៀន។ ការចុះហត្ថលេខានិងដាក់ពិន្ទុមូលវិចារណ៍ក្នុងសៀវភៅតាមដានការសិក្សា និងសៀវភៅសិក្ខាគារិករបស់សិស្ស។

**-ការងារបង្រៀននិងរៀន៖** មានផែនការបង្រៀនច្បាស់លាស់ (វត្ថុបំណង ជម្រើសខ្លឹមសារ សម្ភារឧបទេស លំដាប់សកម្មភាពគ្រូនិងសិស្ស)។ ការគោរពពេលវេលានិងវិន័យសាលា អនុវត្តវិធីសាស្ត្របង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល និងយកចិត្តទុកដាក់ចំពោះសិស្សខ្សោយ និងសិស្សក្រីក្រ។ ការគ្រប់គ្រងសៀវភៅសិក្សាគោលរបស់សិស្ស។ ការវាយតម្លៃការសិក្សារបស់សិស្សតាមរយៈ ការធ្វើសំណួរសរសេរប្រចាំខែ និងឆមាស។

**-ការងារនិងសកម្មភាពផ្សេងៗ៖**ចូលរួមប្រជុំថ្ងៃព្រហស្បតិ៍និងថ្នាក់កម្រងបានទៀងទាត់។ ចូលរួមក្នុងសាលាសកម្មភាពក្នុងនិងក្រៅសាលា។ ការជួយអប់រំសីលធម៌ផ្សេងៗ ការប្រឆាំងគ្រឿងញៀន ច្បាប់ចរាចរណ៍និងបញ្ហាអសកម្មផ្សេងទៀត។

*ឃ.គ្រូបន្ទុកថ្នាក់*

តាមឯកសារប្រើប្រាស់ផ្ទៃក្នុងរបស់វិទ្យាល័យហ៊ុនសែនស្វាយធំនៅឆ្នាំ២០១៦ បានបង្ហាញអំពីភារកិច្ចគ្រូបន្ទុកថ្នាក់មានដូចខាងក្រោម៖

គ្រូទទួលបន្ទុកថ្នាក់ មានភារកិច្ចបន្ថែមពីលើការបង្រៀន។ ភារកិច្ចទាំងនោះរួមមានគ្រប់គ្រងសិស្សក្នុងថ្នាក់ (ជ្រើសរើសប្រធានថ្នាក់ និងអនុប្រធានថ្នាក់)។ រៀបចំបញ្ជីហៅឈ្មោះសិស្ស ប្រវត្តិរូបសិស្ស បញ្ជីអវត្តមានសិស្ស បញ្ជីពិន្ទុសិស្ស។ ការរៀបចំឱ្យមានសៀវភៅតាមដានការសិក្សានិងតារាងផ្សេងៗក្នុងថ្នាក់រៀន។ ការតុបតែងថ្នាក់មានបាវចនា ទង់ជាតិ ព្រះឆាយាលក្ខណ៍ អង្គការលេខ ពាក្យស្លោក ផ្ទាំងគំនូរអប់រំ ផែនទីនិងការដាក់តាំងស្នាដៃសិស្ស។ ការដឹកនាំសិស្សធ្វើពលកម្មសម្អាតថ្នាក់ ទីធ្លា កែលម្អបរិស្ថាន ថែទាំទ្រព្យសម្បត្តិសាលា និង ធ្វើទំនាក់ទំនងជាមួយមាតាបិតាសិស្សក្នុងករណីសិស្សគេចសាលា វិន័យសីលធម៌សិស្សមិនល្អ។

*ង.ភារកិច្ចជាប្រធានក្រុមបច្ចេកទេស*

តាមឯកសារប្រើប្រាស់ផ្ទៃក្នុងរបស់វិទ្យាល័យហ៊ុនសែនស្វាយធំនៅឆ្នាំ២០១៦ បានបង្ហាញអំពីភារកិច្ចជាប្រធានក្រុមបច្ចេកទេសមានដូចខាងក្រោម៖

ភារកិច្ចជាប្រធានក្រុមបច្ចេកទេសមានការងារច្រើន ដែលត្រូវបំពេញដូចជា ជំរុញការងារក្រុមបច្ចេកទេសនិងរៀបចំកម្មវិធីសិក្សានៅសាលា និងថ្នាក់កម្រង។ ការដឹកនាំសមាជិកក្រុមប្រជុំពិភាក្សារិះរកវិធីសាស្ត្រសម្រាប់ដោះស្រាយបញ្ហាដែលបានជួបនៅក្នុងពេលបង្រៀន និងមួយខែម្តង។ ពង្រឹងការងារអធិការកិច្ច ត្រួតពិនិត្យការងាររដ្ឋបាលគ្រូ និងការងារបង្រៀននិងរៀន។ តាមដានការប្រើប្រាស់សម្ភារឧបទេស និងការអនុវត្តកម្មវិធីសិស្សមជ្ឈមណ្ឌល ព្រមទាំងការងារមួយចំនួនទៀត។

### ២.៦.២-ការគ្រប់គ្រងសាលារៀនរបស់នាយកសាលា

ការគ្រប់គ្រងសាលារៀនរបស់នាយកគ្រឹះស្ថានសិក្សាសាធារណៈ មានភាពចាំបាច់ក្នុងការគ្រប់គ្រងនិងដឹកនាំសាលារៀនឱ្យមានការអភិវឌ្ឍ ដោយទទួលស្គាល់ពីក្រសួងអប់រំ និងស្ថាប័នពាក់ព័ន្ធនានាក្នុងមូលដ្ឋាន។ នៅក្នុងការគ្រប់គ្រងសាលារៀនរួមមាន កិច្ចការជាច្រើនដែលត្រូវធ្វើដូចជាការរៀបចំរចនាសម្ព័ន្ធនិងបំណែងចែកភារកិច្ច ការអនុវត្តផែនការអភិវឌ្ឍសាលារៀន ការគ្រប់គ្រងធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ការរៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកឱ្យបានសមស្រប។ ការរៀបចំបរិស្ថានសាលាល្អ អនាម័យស្អាត ឯកសណ្ឋានសិស្សគ្រូ ការប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាក្នុងដំណើរការគ្រប់គ្រងសាលារៀន និងធានាបាននូវសុវត្ថិភាពគ្រូបង្រៀននិងសិស្ស (ក្រសួងអប់រំ ២០១៦)។ ជាមួយគ្នានេះ គណៈគ្រប់គ្រងសាលា ត្រូវទទួលបន្ទុកការងារលើការគ្រប់គ្រងផែនការស្ថិតិ សម្ភារៈ បរិស្ថានសិក្សា កីឡា បុគ្គលិក រដ្ឋបាល បច្ចេកទេស ការសិក្សា វិន័យសិស្ស និងក្រុមប្រឹក្សាកុមារជាដើម។

នាយកសាលាផ្តោតការងារដឹកនាំនិងគ្រប់គ្រងសាលារៀន៥ចំណុចធំៗដូចតទៅ៖

*ក.ការងាររដ្ឋបាល*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំបង្ហាញអំពីការងាររដ្ឋបាលមានដូចខាងក្រោម៖

*ក.១-ការគ្រប់គ្រងការងាររដ្ឋបាល*

នៅក្នុងការគ្រប់គ្រងសាលារៀនមួយ នាយកមានភារកិច្ចចាំបាច់ ក្នុងការគ្រប់គ្រងការងាររដ្ឋបាលដែលសម្រាប់ដំណើរការសាលារៀនជាមួយបុគ្គលិក សហគមន៍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។ ការងារទាំងនោះរួមមាន៖

-ការកសាងចក្ខុវិស័យ បេសកកម្ម គោលដៅ គោលបំណង ផែនការអភិវឌ្ឍសាលាផែនការកែលម្អសាលា ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការថវិកា និងផែនការសកម្មភាពការងាររបស់សាលារៀន ។

-រចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និង ក្រុមប្រឹក្សាកុមាររៀបចំរដ្ឋបាលសាលារៀនមាន គណៈកម្មការគ្រប់គ្រងសាលារៀន ទីចាត់ការ កម្រងស្ថិតិសិស្សនិងថ្នាក់ ដ្យាក្រាមស្ថិតិសិស្សគ្រូ លទ្ធផលប្រឡង តារាងព័ត៌មានបុគ្គលិកអប់រំ របាយការណ៍ផ្សេងៗ។

-បំណែងចែកតួនាទីនិងភារកិច្ចបុគ្គលិកអប់រំ

-តារាងស្ថិតិផែនទីខ្នងផ្ទះ

-ក្រុមប្រឹក្សានិងគណៈកម្មការនានាក្នុងសាលា

-កម្មវិធីការងារប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាសនិងប្រចាំឆ្នាំ

-ការរៀបចំផ្សព្វផ្សាយនិងបំផុសឱ្យអាណាព្យាបាលនាំកូនមករៀន

-ការប្រជុំការងាររបស់សាលារៀននិងផ្សព្វផ្សាយលិខិតគតិយុត្ត
-ធានានិយ័តភាពក្នុងនិងការសិក្សានិងវត្តមានរបស់គ្រូបង្រៀន
-ចេញលិខិតបញ្ជាក់ការសិក្សានិងប័ណ្ណសម្គាល់ខ្លួនសិស្ស
-រៀបចំទីចាត់ការរក្សាសណ្ដាប់ធ្នាប់និងវិន័យក្នុងសាលារៀន
-ពិនិត្យនិងសម្រេចលើការរៀបចំបទបញ្ជាផ្ទៃក្នុងសាលារៀន
-ពិនិត្យនិងសម្រេចជ្រើសរើសសិស្សទទួលបានអាហារូបករណ៍
-ពិនិត្យនិងសម្រេចលើការរៀបចំផ្ទេរនិងចូលរបស់សិស្ស
-ធ្វើការវាយតម្លៃបុគ្គលិកនិងដំលើងថ្នាក់ប្រចាំឆ្នាំ
-ណែនាំដាស់តឿនដល់បុគ្គលិកដែលអសកម្មការងារ
-រៀបចំបញ្ជីសារពើភ័ណ្ឌ និង ការប្រើប្រាស់ថវិកាក្នុងសាលារៀនសហការជាមួយគណៈកម្មការគ្រប់គ្រងសាលារកថវិកា។
-អនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចបញ្ជីការគណនេយ្យចំពោះថវិកាសាលារៀន
-រៀបចំបរិស្ថានឱ្យមានអនាម័យនិងសោភ័ណភាពក្នុងសាលារៀន
-ធ្វើជាអាជ្ញាកណ្ដាលផ្សះផ្សារទំនាស់ផ្សេងៗដែលកើតមានឡើងនៅក្នុងសាលារៀន
-បំពេញភារកិច្ចចាំបាច់តាមការចាត់តាំងរបស់ថ្នាក់លើជាដើម។

ក្រៅពីភារកិច្ចខាងលើនេះ នាយកសាលាត្រូវបំពេញការងារបន្ថែមទៀតដូចជា៖

*ក.១.១-ក្រុមប្រឹក្សាផ្សេងៗ*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១២ ស្ដីពីខ្លឹមសារសង្ខេបសម្រាប់ជំនួយគណៈគ្រប់គ្រងសាលារៀន (មត្តេយ្យ បឋម មធ្យមសិក្សា)បង្ហាញអំពីក្រុមប្រឹក្សាផ្សេងៗមានដូចខាងក្រោម៖

-ក្រុមប្រឹក្សាអប់រំ៖ ជួយនាយកសាលាសម្រាប់ធ្វើឱ្យការអប់រំទទួលបានលទ្ធផលល្អ ការប្រជុំនៅដើមឆ្នាំសិក្សា ដំណាច់ឆមាសទី១ ដំណាច់ឆ្នាំសិក្សានិងក្នុងករណីចាំបាច់។
-ក្រុមប្រឹក្សាគ្រូបង្រៀន៖ ជួយនាយកសាលាក្នុងការថែរក្សាដំណើរការរបស់សាលារៀន។
-ក្រុមប្រឹក្សាបច្ចេកទេសនិងក្រុមបច្ចេកទេស៖ ជួយនាយកសាលាឱ្យការបង្រៀននិងរៀនប្រព្រឹត្តទៅបានល្អ និងមានប្រសិទ្ធភាព។
-ក្រុមប្រឹក្សាប្រឡងប្រណាំង៖ លើកកម្ពស់សមត្ថភាពច្នៃប្រឌិត។
-ក្រុមប្រឹក្សាវិន័យបុគ្គលិក៖ ជួយដោះស្រាយបញ្ហាមិនប្រក្រតី អសកម្ម និងប្រជុំសម្រេចលើការងារមួយចំនួនរបស់បុគ្គលិក។
-ក្រុមប្រឹក្សាកុមារ៖ បង្កើតឡើងដើម្បីអភិវឌ្ឍកុមារឱ្យក្លាយជាកុមារបីល្អ (កូនល្អ សិស្សល្អ មិត្តល្អ)។

*ក.១.២-គណៈកម្មការនានា*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១២ ស្តីពីខ្លឹមសារសង្ខេបសម្រាប់ជំនួយគណៈគ្រប់គ្រងសាលារៀន(មត្តេយ្យ បឋម មធ្យមសិក្សា)បង្ហាញអំពីគណៈកម្មការនានាមានដូចខាងក្រោម៖

-គណៈកម្មការទ្រទ្រង់សាលា (គណៈកម្មការគ្រប់គ្រងសាលារៀន)៖ ជួយសម្រួលលក្ខខណ្ឌចាំបាច់ដើម្បីដំណើរការរបស់សាលារៀន ជួយដោះស្រាយបាតុភាពអវិជ្ជមាននៅក្នុងសាលារៀន។

-គណៈកម្មការអប់រំកាយកីឡា និងសិល្បៈសិក្សា៖ ធ្វើឱ្យមានការរីកចម្រើននូវសមត្ថភាព ការអប់រំកាយទាំងអស់គ្នាសម្រាប់ក្នុងសាលា។

-គណៈកម្មការអនាម័យបរិស្ថាន៖ ធ្វើឱ្យសាលារៀនមានអនាម័យស្អាតជានិច្ច មានបរិស្ថានគួរជាទីមនោរម្យ។

-គណៈកម្មការតម្រង់ទិសវិជ្ជាជីវៈ៖ បណ្តុះបំណិនជីវិត ឧបនិស្ស័យ បុរេវិជ្ជាជីវៈតម្រង់វិជ្ជាជីវៈសិស្ស។

-គណៈកម្មការវាយតម្លៃការងារបុគ្គលិក៖ មានភារកិច្ចប្រជុំវាយតម្លៃលើការងារបុគ្គលិកក្នុងអង្គភាព។

*ក.២-ការគ្រប់គ្រងសៀវភៅនិងបញ្ជីផ្សេងៗទៀត*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១២ ស្តីពីខ្លឹមសារសង្ខេបសម្រាប់ជំនួយគណៈគ្រប់គ្រងសាលារៀន(មត្តេយ្យ បឋម មធ្យមសិក្សា)បង្ហាញអំពីការគ្រប់គ្រងសៀវភៅនិងបញ្ជីផ្សេងៗទៀតមានដូចខាងក្រោម៖

-សៀវភៅនិងបញ្ជីក្នុងទីចាត់ការ៖ បញ្ជីអត្តលេខ សៀវភៅសិក្ខាគារិក សំណុំរឿងសិស្ស និងបុគ្គលិក សៀវភៅស្រង់អវត្តមាន ផែនការប្រចាំសាលារៀន បញ្ជីសារពើភ័ណ្ឌ សៀវភៅក្រាំងមាស សៀវភៅប្រវត្តិសាលា សៀវភៅគ្រូប្រចាំសប្តាហ៍ សៀវភៅចំណូល ចំណាយ កម្មវិធីផែនការប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានានា វិញ្ញាបនបត្របញ្ជាក់ការសិក្សា លិខិតបញ្ជាក់ការសិក្សា កម្មវិធីសិក្សា កាលវិភាគ សៀវភៅសិក្សាសិស្សគ្រូ លក្ខន្តិកៈសាលារៀនចំណោះទូទៅ បទបញ្ជាផ្ទៃក្នុង បញ្ជីសម្ភារឧបទេស ផែនទីខ្នងផ្ទះ ឯកសារស្រាវជ្រាវគរុកោសល្យនានា និងសៀវភៅអនុសាសន៍។

*ក.៣-សៀវភៅនិងបញ្ជីក្នុងថ្នាក់រៀន៖* សៀវភៅសម្រង់វត្តមានសិស្ស សម្រង់ពិន្ទុ តារាងទាំងប្រាំបួន សៀវភៅបញ្ជីវត្តមាន សៀវភៅកិច្ចតែងការបង្រៀន សៀវភៅតាមដានការសិក្សា និងសៀវភៅសិក្ខាគារិករបស់សិស្ស។ ដោយឡែកសិស្សថ្នាក់ទី៣ឡើងទៅ ទើបមានសៀវភៅសិក្ខាគារិក។

*ក.៤-ការគ្រប់គ្រងឯកសារផ្សេងៗក្នុងសាលា*

ឯកសារសំខាន់ៗនៅក្នុងសាលារួមមាន ផែនទី សៀវភៅ បញ្ជី លិខិតបទដ្ឋាននានា កាសែត ខ្សែអាត់ ទស្សនាវដ្តី ឧបករណ៍អេឡិចត្រូនិច ប័ណ្ណផ្សេងៗ នៅក្នុងអង្គភាពសាលាឬទទួលពីអង្គភាពឬស្ថាប័នផ្សេងៗទៀត។ នៅក្នុងការគ្រប់គ្រងឯកសារ និងសម្ភារៈប្រើប្រាស់ចាំបាច់ក្នុងសាលារួមមាន

លិខិតចូល លិខិតចេញនិងការប្រើប្រាស់ត្រានៅក្នុងសាលា (ក្រសួងអប់រំ ២០១២)។

*ក.៥-បរិស្ថាននិងសុខភាពអនាម័យក្នុងសាលារៀន*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៧ ស្តីពីបណ្ណព័ត៌មានសាលារៀនមានដូចខាងក្រោម៖

បរិស្ថានជាបញ្ហាចម្បងនៅក្នុងសាលារៀន។ កាលណាសាលាមានបរិស្ថានល្អ អនាម័យស្អាត នាំឱ្យសិស្ស មានចំណង់ចំណូលចិត្តចង់រៀន ហើយធានាបាននូវសុខសុវត្ថិភាពដល់សិស្សនិងគ្រូ។ សាលារៀនគ្មានគ្រោះថ្នាក់ គ្មានអំពើហឹង្សា គ្មានការគំរាមកំហែង មានវិធានការណ៍ទប់ស្កាត់បាតុភាពមិនប្រក្រតី។ម៉្យាងទៀត បរិស្ថានមានរបងសាលា ខ្លោងទ្វារ ដងទង់ជាតិ ខ្ទស ទីធ្លាលេងកំសាន្ត ដើមឈើយកម្លប់ សួនច្បារ ទីធ្លា ធុងសំរាម កន្លែងលក់នំចំណី អនាម័យ និងគុណភាពអាហារឃ្លាំង និងសម្ភារៈផ្ទះបាយ កម្មវិធីអាហារពេលព្រឹក មានប្រអប់សង្គ្រោះបឋម និងថ្នាំព្រូនសិស្ស។ សាលាមានបង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃ មានទឹកនិងសាប៊ូលាងដៃ ច្រាស អំបោស ប្រដាប់ដងទឹក កម្មវិធីដុសសម្អាតធ្មេញ ការលាងសម្អាតបរិក្ខារនិងការលាងដៃជាប្រចាំ។ តាមស្តង់ដាជាតិបានបែងចែកបង្គន់អនាម័យជា៣ផ្នែកគឺបង្គន់ប្រុស បង្គន់ស្រីនិងបង្គន់កុមារពិការ។ សិស្សប្រុស ១០០នាក់ត្រូវការបង្គន់២ និងបង្គន់នោមចំនួន៣។ ចំណែកសិស្សស្រី១០០នាក់ត្រូវការបង្គន់ចំនួន៣។

*ខ.ការងារបច្ចេកទេស*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំបង្ហាញអំពីការងារបច្ចេកទេសមានដូចខាងក្រោម៖

*ខ.១-ការគ្រប់គ្រងការងារបច្ចេកទេសសាលារៀន*

ការងារបច្ចេកទេស ជាការគ្រប់គ្រងសកម្មភាពបង្រៀននិងរៀន ក្នុងនោះនាយកសាលាត្រូវប្រកាន់ភ្ជាប់នូវតួនាទីជាទីប្រឹក្សាគរុកោសល្យ។ ការងារនេះមានដូចខាងក្រោម៖

-ការរៀបចំកាលវិភាគនិងបែងចែកកម្មវិធីសិក្សាសម្រាប់ការបង្រៀននិងរៀន

-ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់ សាលាកុមារមេត្រី

-ដឹកនាំការប្រជុំបច្ចេកទេស ប្រជុំគរុកោសល្យ ថ្នាក់កម្រងនិងផ្សព្វផ្សាយសារាចរណែនាំនានា

-ពិនិត្យដំណើរការ បន្ទប់ពិសោធន៍ កុំព្យូទ័រ បណ្ណាល័យ រោងជាង សិល្បៈកីឡា បំណិនជីវិត

-អធិការកិច្ចវាយតម្លៃប្រជុំក្រុមបច្ចេកទេសនិងពិនិត្យកិច្ចតែងការបង្រៀនរបស់គ្រូ

-ពិនិត្យនិងរៀបចំកសាងសម្ភារឧបទេសតាមមុខវិជ្ជានិងការអភិវឌ្ឍបណ្ណាល័យ

-ផ្គត់ផ្គង់សៀវភៅសិក្សាគោល ឯកសារនិងសម្ភារៈផ្សេងៗ

-វាយតម្លៃលទ្ធផលសិក្សាជាដំណាក់និងបញ្ចប់

-សហការជាមួយគ្រូបង្រៀនទាំងអស់ដើម្បីពង្រឹងគុណភាពបង្រៀននិងរៀន

-ទំនាក់ទំនង និងចូលរួមការងារជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បុណ្យជាតិផ្សេងៗ កម្មវិធីសុខុមាលភាពសង្គម និងមនុស្សធម៌ជាដើម ។

*ខ.២-កម្មវិធីសិក្សា*

កម្មវិធីសិក្សាសម្រាប់ថ្នាក់បឋមសិក្សានៅកម្ពុជា ក្រោយឆ្នាំ១៩៧៩ មកដល់សព្វថ្ងៃនេះមានការប្រែប្រួលផ្តើមពី៤កម្រិតមក៦កម្រិតថ្នាក់។ រីឯកម្មវិធីសិក្សានៅសាលាបឋមសិក្សា ត្រូវរៀន៦ថ្ងៃក្នុងមួយសប្តាហ៍និងមួយម៉ោងសិក្សារយៈពេល៤០នាទី មានមុខវិជ្ជា និងម៉ោងសិក្សាដូចខាងក្រោម៖

| ល.រ | មុខវិជ្ជា | ថ្នាក់ | | | | | |
|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 | 6 |
| 1 | ភាសាខ្មែរ | 11 | 11 | 11 | 9 | 9 | 9 |
| 2 | គណិតវិទ្យា | 7 | 7 | 7 | 6 | 6 | 6 |
| 3 | វិទ្យាសាស្ត្រ | 3 | 3 | 3 | 3 | 3 | 3 |
| 4 | កុំព្យូទ័រ | 0 | 0 | 0 | 1 | 1 | 1 |
| 5 | សិក្សាសង្គម | 3 | 3 | 3 | 3 | 3 | 3 |
| 6 | អប់រំសិល្បៈ | 1 | 1 | 1 | 1 | 1 | 1 |
| 7 | អប់រំកាយនិងកីឡា | 2 | 2 | 2 | 2 | 2 | 2 |
| 8 | អប់រំសុខភាព | 1 | 1 | 1 | 1 | 1 | 1 |
| 9 | ភាសាបរទេស | 2 | 2 | 2 | 2 | 2 | 2 |
| 10 | បំណិនជីវិតតាមមូលដ្ឋាន | 0 | 0 | 0 | 2 | 2 | 2 |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | 30 | 30 | 30 | 30 | 30 | 30 |

(ប្រភព៖ ក្រសួងអប់រំ ២០១៥)

គេសង្កេតឃើញថាពីឆ្នាំ១៩៧៩-១៩៨៦ កម្មវិធីសិក្សានៅកម្រិតបឋមសិក្សាមាន៤ថ្នាក់ (ថ្នាក់ទី១ដល់ទី៤)។ ឆ្នាំ១៩៨៧-១៩៩៦មាន៥ថ្នាក់(ថ្នាក់ទី១ដល់ទី៥)។ ចាប់ពីឆ្នាំ១៩៩៧ ដល់បច្ចុប្បន្នមាន៦ថ្នាក់(ថ្នាក់ទី១ដល់ទី៦)។ ចំពោះមុខវិជ្ជាសិក្សាសង្គមមានប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ អប់រំសិល្បៈ បច្ចេកវិទ្យានិងភាសាបរទេស (បារាំង/អង់គ្លេស) សម្រាប់ថ្នាក់ទី៥ប៉ុណ្ណោះ។ ចាប់ពីឆ្នាំ២០១១ ដល់២០១៥ការបង្រៀនភាសាបរទេសចាប់ពីថ្នាក់ទី៥ឡើងទៅ។ នៅឆ្នាំ២០១៦ ក្រសួងអប់រំបានធ្វើការកែទម្រង់កម្មវិធីសិក្សាថ្មីដោយអភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងសម្ភារឧបទេស។ ការសិក្សានៅកម្រិតបឋមសិក្សា៦ឆ្នាំ (ថ្នាក់ទី១ដល់ទី៦) ម៉ោងសិក្សាមួយឆ្នាំ១០៥០ម៉ោង និងរៀន៣០

ម៉ោងក្នុងមួយសប្តាហ៍ ហើយរៀនភាសាបរទេស និងកុំព្យូទ័រចាប់ពីថ្នាក់ទី៤ឡើង។

(ប្រភព៖ បណ្ឌិត សៀង សុវណ្ណា ២០១៩)

ទាក់ទងការងាររៀន បង្រៀន និង ការអនុវត្តកម្មវិធីសិក្សាគោល នៅកម្រិតបឋមសិក្សាមានការបែងចែកការបង្រៀនជាពីរបែប គឺការបង្រៀនភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣។ ចំណែកការបង្រៀនតាមបែបស្រាវជ្រាវសំដៅលើថ្នាក់ទី៤ ទី៥និងទី៦ (ក្រសួងអប់រំ ២០១៧)។ យ៉ាងណាមិញកម្មវិធីសិក្សាមុខវិជ្ជាលម្អិតសម្រាប់មួយឆ្នាំសិក្សាក្នុងសាលាបឋមរួមមាន រៀនអាន សរសេរតាមអាន តែងសេចក្តី វិទ្យាសាស្ត្រអនុវត្ត គណិតវិទ្យា អក្សរផ្ចង់ សីលធម៌ ពលរដ្ឋវិជ្ជា ភូមិវិទ្យា ប្រវត្តិវិទ្យា គំនូរ មេសូត្រ ចំរៀង របាំ អប់រំបំណិនជីវិត និងភាសាបរទេស។ នៅក្នុងចំណោមមុខវិជ្ជាទាំងនេះ កម្រិតថ្នាក់ខ្លះមិនបានរៀនគ្រប់មុខវិជ្ជាទេ។

***ខ.៣-ការងារអធិការកិច្ច***

តាមឯកសារផ្ទៃក្នុងរបស់វិទ្យាល័យហ៊ុនសែនស្វាយធំនៅឆ្នាំ២០១៧ ស្តីពីផែនការអធិការកិច្ច បង្ហាញអំពីវាយតម្លៃការបង្រៀននិងរដ្ឋបាលរបស់គ្រូមានដូចខាងក្រោម៖

ការងារអធិការកិច្ចជាការងារអធិការកិច្ចផ្ទៃក្នុងរបស់សាលារៀន។ នាយករង ត្រូវរៀបចំផែនការប្រចាំខែ ត្រីមាស ឆមាសនិងប្រចាំឆ្នាំឱ្យបានច្បាស់លាស់ ដើម្បីជួយគ្រូនិងសិស្ស។ នៅក្នុងពេល ពេលចុះអធិការកិច្ចតាមថ្នាក់ គឺតម្រូវឱ្យគ្រូដែលអធិការចុះពិនិត្យ ភ្ជាប់មកជាមួយនូវសៀវភៅកិច្ចតែងការបង្រៀន សៀវភៅសេវា សៀវភៅប្រជុំក្រុមបច្ចេកទេស និងសៀវភៅពិន្ទុ ពិសេសឱ្យសិស្សយកសៀវភៅអត្តបទប្រចាំថ្នាក់មកផង។ ពេលចុះអធិការកិច្ចថ្នាក់រៀនគឺអធិការអចិន្ត្រៃយ៍និងប្រធានក្រុមបច្ចេកទេសត្រូវពិនិត្យទៅលើចំណុចសំខាន់ធំៗ២មានដូចជា៖

+វាយតម្លៃការងាររដ្ឋបាល: ការគោរពពេលវេលា ការរៀបចំថ្នាក់ (តារាងទាំង៩ អនាម័យថ្នាក់ ការរៀបចំតុ កៅអី វិន័យសិស្ស និងអវត្តមានសិស្ស)។

-រដ្ឋបាលថ្នាក់: សៀវភៅសម្រង់វត្តមាន សៀវភៅសម្រង់ពិន្ទុ និងសៀវភៅសម្រង់អត្តបទថ្នាក់។

-រដ្ឋបាលគ្រូ: សៀវភៅកិច្ចតែងការបង្រៀន សៀវភៅសេវា សៀវភៅតាមដានការសិក្សារបស់សិស្ស សៀវភៅទំនាក់ទំនងមាតាបិតាសិស្ស សៀវភៅបំណែងចែកកម្មវិធីសិក្សាជាដើម។

-សម្ភារឧបទេស។

-ការអនុវត្តកម្មវិធីសិក្សា: ខ្លឹមសារមេរៀន គោលវិធីសិស្សមជ្ឈមណ្ឌល។

-វាយតម្លៃការបង្រៀន: ការកំណត់វត្ថុបំណងមេរៀន ខ្លឹមសារមេរៀន កំណត់រយៈពេល សម្ភារបង្រៀន លំដាប់សកម្មភាពគ្រូនិងសិស្ស។

+ដំណើរការបង្រៀន: ការរំលឹកមេរៀនចាស់ ការបង្ហាញពីវត្ថុបំណងមេរៀន ការសម្រេចវត្ថុបំណង សកម្មភាពគ្រូ សកម្មភាពសិស្ស ការបំផុសគំនិតសិស្ស បម្រើបម្រាស់ និងការបញ្ចប់មេរៀន។ ការ

ផ្សព្វផ្សាយដល់គ្រូបង្រៀន អំពីផែនការចុះអធិការកិច្ចថ្នាក់រៀន។ សង្កេតការបង្រៀនរបស់គ្រូនិងការរៀនរបស់សិស្សតាមផែនការ ដើម្បីជួយការស្វែងយល់ពីការបង្រៀន និងបញ្ហានានាដែលទាក់ទងនឹងការរៀន និងរកដំណោះស្រាយទៅលើបញ្ហាដែលកើតមានឡើង។ ការផ្តល់ព័ត៌មានត្រឡប់ជូនគ្រូដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាត ព្រមទាំងផ្តល់អនុសាសន៍ បន្ទាប់ពីការសង្កេតការបង្រៀននូវព័ត៌មានជាក់លាក់អំពីឥរិយាបថរបស់គ្រូបង្រៀនដើម្បីជួយពួកគាត់។

*ខ.៤-សេវាបង្រៀនប្រចាំសប្តាហ៍*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៨ ស្តីពីនិយាមការប្រើប្រាស់បុគ្គលិកអប់រំអំពីសេវាបង្រៀនប្រចាំសប្តាហ៍នៅក្នុងសាលារៀនមានដូចខាងក្រោម៖

នាយកសាលាជាអ្នករៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកនៅក្នុងសាលារៀន។ ជាទូទៅ គ្រូបង្រៀននៅសាលាបឋមសិក្សាត្រូវបង្រៀន២៥ម៉ោង ក្នុងមួយសប្តាហ៍និងចំនួនម៉ោងដែលត្រូវបំពេញគាំទ្រដល់ការបង្រៀនចំនួន១៥ម៉ោងទៀត។ សិក្ខាបនធារី ត្រូវទទួលបន្ទុកបង្រៀនតាមកាលវិភាគទៅតាមកម្រិតថ្នាក់នីមួយៗ (ថ្នាក់ទី១ដល់ទី៦)។ គ្រូបង្រៀនត្រូវទទួលបន្ទុកនិងជាប្រធានក្រុមបច្ចេកទេសនៅក្នុងសាលារៀនឬថ្នាក់កម្រង។ ចំពោះម៉ោងគាំទ្រគ្រូអាចធ្វើកិច្ចតែងការបង្រៀន កែលំហាត់សិស្ស បូកពិន្ទុសិស្ស ឬគ្រូមិនបង្រៀនធ្វើការនៅទីចាត់ការ បណ្ណាល័យ រោងជាង កសិកម្ម សិល្បៈជាបេឡា គណនេយ្យ គ្រូកីឡាជាដើម។

*ខ.៥-ការបង្រៀននិងរៀន*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៧ ស្តីពីវិធីសាស្ត្របង្រៀនមានដូចខាងក្រោម៖

ការបង្រៀននិងរៀនជាករណីយកិច្ចចាំបាច់មួយក្នុងដំណើរការសកម្មភាពរបស់សិស្ស និង គ្រូក្នុងថ្នាក់រៀន។ គ្រូត្រូវប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបរិះរក (IBL) វិធីសាស្ត្រចំរុះ និងចិត្តគរុកោសល្យក្នុងការបង្រៀន និងគ្រប់គ្រងថ្នាក់រៀន។ គ្រូបង្រៀនគ្រប់កម្រិតថ្នាក់ត្រូវអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលស្របតាមកម្មវិធីសិក្សា និងការណែនាំរបស់ក្រសួងអប់រំ។ ដោយឡែក ដើម្បីទទួលបាននូវប្រសិទ្ធភាពនៃការបង្រៀន និងរៀន គឺត្រូវអនុវត្តនូវចំណុចមួយចំនួន ទៅលើការងាររដ្ឋបាលថ្នាក់រៀន ការប្រើប្រាស់សំណួរ ការបង្កើតល្បែងសិក្សា ការប្រើប្រាស់ធនធានក្នុងថ្នាក់រៀនសំបូរបែប ការអភិវឌ្ឍអំណាន និងសំណេរ ការឆ្លុះបញ្ចាំង (ស្វ័យវាយតម្លៃ) ព្រមទាំងវង្វាយតម្លៃនិងកម្រងស្នាដៃសិស្ស (បឋមសិក្សាបន្ទាយឈើ ២០១៨)។

*ខ.៦-បណ្ណាល័យនិងសៀវភៅសិក្សាគោល*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៧ ស្តីពីបណ្ណព័ត៌មានសាលារៀនមានដូចខាងក្រោម៖

បណ្ណាល័យជាកន្លែងសម្រាប់ទុកដាក់សៀវភៅគោល និង ឯកសារផ្សេងៗក្នុងសាលារៀន។ តាមលក្ខណៈស្តង់ដាបណ្ណាល័យនៅបឋមសិក្សា សាលាមួយ ត្រូវមានសៀវភៅយ៉ាងតិចចំនួន៦០០ក្បាលស្មើនឹង៣០០ចំណងជើង។ រីឯបណ្ណារក្សជាអ្នកមើលការខុសត្រូវសៀវភៅ សម្ភារផ្សេងៗនិងធ្វើតារាងកាលវិភាគឱ្យសិស្សចូលអានសៀវភៅប្រចាំសប្តាហ៍។ សិស្សនៅតាមថ្នាក់នីមួយៗទទួលបានសៀវភៅសិក្សាគោលដូចគ្នា។ សិស្សមួយនាក់ត្រូវមានសៀវភៅសិក្សាគោលមួយឈុត។

-សិស្សថ្នាក់ទី១ដល់ទី៣ ត្រូវទទួលបានសៀវភៅ៣ក្បាលរួមមាន ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម។

-សិស្សថ្នាក់ទី៤ដល់ទី៦ ត្រូវទទួលបានសៀវភៅ៤ក្បាលរួមមាន ភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម និងវិទ្យាសាស្ត្រអនុវត្ត។ ដោយឡែក ចំពោះសៀវភៅភាសាបរទេសមិនមាននៅក្នុងបណ្ណាល័យទេ។

*ខ.៧-ឯកសារប្រតិបត្តិសម្រាប់សាលាបឋមសិក្សា*

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាចេញផ្សាយនៅឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលមានដូចខាងក្រោម៖

នៅក្នុងដំណើរការសាលាបឋមសិក្សា មានការប្រើប្រាស់នូវឯកសារមួយចំនួន សម្រាប់បម្រើឱ្យការងារសាលារៀន។ ឯកសារទាំងនោះរួមមាន ការគ្រប់គ្រងថវិកាសាលារៀន ការរៀបចំផែនការអភិវឌ្ឍសាលារៀន ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ស្ថិតិអប់រំសាលារៀន ការស្វ័យវាយតម្លៃសាលារៀន ការងារអធិការកិច្ចសាលារៀនផ្តោតលើបច្ចេកទេសបង្រៀននិងរៀន ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលសិក្សានៅសាលារៀន ការសរសេរគម្រោង លំនាំបង្រៀនតាមបែបស្រាវជ្រាវ(កម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន សិក្សាសង្គមនិងវិទ្យាសាស្ត្រថ្នាក់ទី៤ ទី៥ និងទី៦ លំនាំបង្រៀនមេរៀនភាសាខ្មែរថ្នាក់ទី១-៣។

*គ.ការងារបុគ្គលិក*

*គ.១-ការគ្រប់គ្រងបុគ្គលិកក្នុងសាលា*

ការគ្រប់គ្រងបុគ្គលិកក្នុងសាលា ជាភារកិច្ចរបស់នាយកសាលា។ ដើម្បីឱ្យការគ្រប់គ្រងបុគ្គលិកមានប្រសិទ្ធភាពធានាបាននូវតម្លាភាព និងនិយ័តភាពការងារ ទាមទារឱ្យមានការសហការជាមួយនាយករងនិងគ្រូបង្រៀន។ បុគ្គលិកអប់រំនៅក្នុងសាលារៀនមានដូចជា៖

-នាយកសាលាទទួលបន្ទុកក្តាប់រួម

-នាយករងទទួលបន្ទុកការងាររដ្ឋបាល

-នាយករងទទួលបន្ទុកការងារបច្ចេកទេសគរុកោសល្យ

-នាយករងទទួលបន្ទុកការងារយុវជន កីឡានិងសិល្បៈ

-លេខាធិការមានភារកិច្ច ជាសេនាធិការផ្ទាល់ឱ្យនាយក និងនាយករងរបស់សាលារៀនតាមបំណែង

ចែកដែលនាយកសាលាបានប្រគល់ជូន។

-បណ្ណារក្សជាអ្នកសម្របសម្រួលក្នុងការទំនាក់ទំនងរវាងសៀវភៅ និងកុមារ តាមរយៈការផ្តល់ភាពសប្បាយរីករាយដល់កុមារ។

-បេឡាធិការទទួលរក្សាទុកថវិការបស់សាលារៀនឱ្យមានសុវត្ថិភាព។

-គណនេយ្យរៀបចំលិខិតស្នាមដែលពាក់ព័ន្ធនឹងចំណូល ចំណាយរបស់សាលារៀន។

-មន្ត្រីទទួលបន្ទុកយុវជន និងកុមារទទួលខុសត្រូវលើការងារគ្រប់គ្រងកុមារក្នុងសាលារៀន។ រៀបចំបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងនិងសកម្មភាពការងារ (ក្រុមប្រឹក្សាកុមារ ការងារមិត្តអប់រំមិត្ត ចលនាបីល្អ គ្រូបង្រៀនក្របខណ្ឌនិងគ្រូបង្រៀនជាប់កិច្ចសន្យា បង្រៀនសិស្សានុសិស្សពីថ្នាក់ទីមួយ ដល់ថ្នាក់ទីប្រាំមួយតាមការចាត់តាំងរបស់នាយកសាលា (ក្រសួងអប់រំ ២០១៦)។

-គ្រូទទួលបន្ទុកថ្នាក់មានភារកិច្ចជាសិក្ខាបនធារីគ្រប់មុខវិជ្ជាផង និងជាគ្រូទទួលបន្ទុកផង។

ដោយឡែក គ្រូបង្រៀនក្របខណ្ឌជាមន្ត្រីរាជការ ឬនាយកសាលា នាយករងអាចបង្រៀនពីរថ្នាក់ពីរពេលនិងថ្នាក់គួបពេលសាលារៀនមានសិស្សច្រើន ហើយខ្វះបន្ទប់រៀនឬគ្រូបង្រៀន។ មិនតែប៉ុណ្ណោះ នាយកសាលា ត្រូវធ្វើផែនការកសាងសមត្ថភាពគ្រូបង្រៀន ដោយរៀបចំកម្មវិធីបំប៉នការបញ្ជូនបុគ្គលិកអប់រំឱ្យទៅចូលរួមក្នុងវគ្គបំប៉ន ឬសិក្ខាសាលានានា។

***គ.២-ការគ្រប់គ្រងសំណុំឯកសារបុគ្គលិក***

នៅក្នុងគ្រប់គ្រងសាលារៀន ទាមទារឱ្យនាយកសាលា ត្រូវគ្រប់គ្រងស្ថិតិបុគ្គលិកឱ្យបានល្អទាំងចាស់និងថ្មី។ ការរៀបចំទុកដាក់ឯកសារតាមអក្ខរក្រម នៅក្នុងសឺមីរបស់បុគ្គលិកម្នាក់ៗមានដូចជាជីវប្រវត្តិសង្ខេប សលាកបត្រឯកត្តជន សញ្ញាបត្រផ្សេងៗ លិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម លិខិតចូលកាន់ភារកិច្ច ឯកសារតែងតាំង (បម្រុងនិងតាំងស៊ប់) ឯកសារផ្លាស់ប្តូរក្របខណ្ឌ ឯកសារផ្លាស់ប្តូរឋានន្តរស័ក្តិ ឯកសារផ្លាស់ប្តូរការដំឡើងថ្នាក់ លិខិតបង្គាប់ការ ឬដីកា ឬប្រកាសតែងតាំងឋានៈ ព្រឹត្តបត្រវាយតម្លៃ លិខិតកែលម្អឬស្តីបន្ទោស ឯកសារលើកសរសើរជូនរង្វាន់ សលាកបត្រមន្ត្រីរាជការស៊ីវិល អត្តលេខមន្ត្រីរាជការ ពាក្យសុំច្បាប់ជាដើម (ក្រសួងអប់រំ ២០១៦)។

***គ.៣-និយាមក្នុងការប្រើបុគ្គលិកអប់រំ***

ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ:

| ល.រ | គ្រឹះស្ថានសិក្សា | សាលាតូច | សាលាមធ្យម | សាលាធំ |
|---|---|---|---|---|
| 1 | បឋមសិក្សា | តិចជាងឬស្មើ២០ថ្នាក់ | ចាប់ពី២១ដល់៤០ថ្នាក់ | ចាប់ពី៤១ថ្នាក់ឡើង |

***គ.៣.១-ការកំណត់ម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ***

| ល.រ | គ្រឹះស្ថានសិក្សាសាធារណៈ | ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ក្នុងមួយសប្តាហ៍ | ចំនួនម៉ោងដែលត្រូវបំពេញគាំទ្រដល់ការបង្រៀនឱ្យគ្រប់ |
|---|---|---|---|

| | | | |
|---|---|---|---|
| | | | ៤០ម៉ោងក្នុងមួយសប្ដាហ៍ |
| 1 | បឋមសិក្សា | ២៥ម៉ោង | ១៥ម៉ោង |

*គ.៣.២-និយាមប្រើបុគ្គលិកបង្រៀន*

| ល.រ | គ្រឹះស្ថានសិក្សាសាធារណៈ | និយាមថ្នាក់ គ្រូបង្រៀន | ផលធៀបសិស្សថ្នាក់ |
|---|---|---|---|
| 1 | បឋមសិក្សា | ១/១.១៥ | ទី១-៣ស្មើ៣៥-៤៥នាក់<br>ទី៤-៦ស្មើ៤០-៥០នាក់ |

*គ.៣.៣-និយាមប្រើបុគ្គលិកអប់រំទីចាត់ការនិងបង្រៀននៅបឋមសិក្សា*

| ល.រ | តួនាទី/ភារកិច្ច | សាលាតូច តិចជាងឬស្មើ២០ថ្នាក់ | | | សាលាមធ្យម ចាប់ពី២១ដល់៤០ថ្នាក់ | | សាលាធំ ចាប់ពី៤១ថ្នាក់ឡើង | |
|---|---|---|---|---|---|---|---|---|
| | | ៦ | ៧ដល់១០ | ១១ដល់២០ | ២១ដល់៣០ | ៣១ដល់៤០ | ៤១ដល់៦០ | ៦១ដល់៨០ |
| ១ | នាយក | 1 | 1 | 1 | 1 | 1 | 1 | 1 |
| ២ | នាយករង | 0 | 1 | 1 | 1 | 2 | 2 | 3 |
| ៣ | លេខាធិការ | 0 | 1 | 1 | 1 | 1 | 1 | 2 |
| ៤ | បណ្ណារក្ស | 1 | 1 | 1 | 2 | 2 | 3 | 3 |
| ៥ | គ្រូពេទ្យជាង | 0 | 0 | 1 | 1 | 1 | 1 | 1 |
| ៦ | បុគ្គលិកឬឆ្មាំ | 0 | 0 | 0 | 0 | 0 | 1 | 1 |
| | សរុប | 2 | 4 | 5 | 6 | 7 | 9 | 11 |

(ប្រភព៖ ក្រសួងអប់រំ ២០១៨)

*ឃ.ការងារហិរញ្ញវត្ថុ*

ការគ្រប់គ្រងហិរញ្ញវត្ថុនៅសាលារៀន ជាភារកិច្ចរបស់នាយកសាលារួមគ្នាជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន ធ្វើឱ្យមានដំណើរការសាលារៀន។ ក្រសួងអប់រំបានទម្លាក់ថវិកាទាំងថេរ និងអថេរដល់អង្គភាពសាលាសម្រាប់ប្រើប្រាស់ជាប្រយោជន៍ ក្នុងការអភិវឌ្ឍសាលា ព្រមទាំងសកម្មភាពផ្សេងៗក្នុងសាលារៀន។ ថវិកាសម្រាប់ដំណើរការសាលារៀន ក្នុងគម្រោងថវិកាកម្មវិធីរបស់ក្រសួងអប់រំតាំងពីឆ្នាំ២០១៣ រហូតមកដល់សព្វថ្ងៃនេះ។

*ឃ.១-ថវិកាសម្រាប់ចំណាយក្នុងសាលារៀន* (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៣)

យោងតាមប្រកាសអន្តរក្រសួង ស្តីពីគោលការណ៍ចំណាយ សម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំឆ្នាំ២០១៣លើកឡើងថា សាលាបឋមសិក្សាមាន៦ថ្នាក់ឡើង ផ្តល់ថវិកាចំនួនមួយលានរៀលក្នុងមួយសាលា និងប្រាំបួនពាន់រៀលក្នុងសិស្សម្នាក់ ក្នុងមួយឆ្នាំសិក្សា។ ថវិកាទាំងនេះ

សម្រាប់យកមកចំណាយសម្ភារមូលដ្ឋាន ការជួសជុលតូច (សង្ហារឹម បរិក្ខារ បណ្ណាល័យ និងអេឡិចត្រូនិច)។ ការទិញសៀវភៅអានដាក់ក្នុងបណ្ណាល័យ ការកែលម្អបរិស្ថាននិងថ្នាក់រៀន បំណិនជីវិត(កីឡា សិល្បៈ រោងជាង គេហវិជ្ជា កសិកម្ម)។ ការចំណាយទឹកស្អាត និងអនាម័យ ថ្លៃអគ្គិសនី ការរៀបចំឯកសារនិងធ្វើតេស្តចុងឆ្នាំសិក្សាសម្រាប់ថ្នាក់ទី៣ និងទី៦ ចលនាបីល្អ (សិស្សល្អ មិត្តល្អ កូនល្អ)របស់ក្រុមប្រឹក្សាកុមារនិងចំណាយផ្សេងៗ។

*ឃ.២-ថវិកាសម្រាប់ពង្រឹងគុណភាពរៀននិងបង្រៀន* (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៩)

សាលារៀន ផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍ នៅតាមកម្រងឬសាលារៀននៅតាមសប្តាហ៍ទី៤នៃខែនីមួយៗចំនួន៧ពេល ក្នុងមួយឆ្នាំសិក្សា។ សាលាផ្តល់រង្វាន់លើកទឹកចិត្តដល់សិស្សពូកែប្រចាំឆ្នាំ២ម៉ឺនរៀលក្នុងមួយថ្នាក់ក្នុងមួយឆ្នាំសិក្សា។ ម៉្យាងទៀត សាលាបានផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំនៅតាមកម្រងសាលារៀន (ដើមឆ្នាំ កណ្តាលឆ្នាំ និងចុងឆ្នាំ) ចំនួន១១ពេលក្នុងមួយឆ្នាំសិក្សា។ សាលាផ្តល់ប្រាក់ឧបត្ថម្ភជូនគ្រូបង្រៀន ដែលបានបង្រៀនម៉ោងបន្ថែមសម្រាប់ជួយសិស្សនៅថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំសិក្សាចំនួន១ម៉ឺន២ពាន់រៀល ក្នុងមួយពេលក្នុងមួយនាក់ដោយគិតទាំងអ្នកគ្រប់គ្រង បណ្ណារក្ស រោងជាង និងលេខាធិការ។ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការអនុវត្តថវិកា សម្រាប់ដំណើរការសាលារៀនសាធារណៈឆ្នាំ២០១៥ ការចំណាយត្រូវពឹងផ្អែកលើមូលដ្ឋាននៃប្រភេទសាលារៀន ចំនួនសិស្ស ចំនួនថ្នាក់ និងទីតាំងនៃសាលារៀន ដែលអាចជាតំបន់ធម្មតាឬតំបន់ដាច់ស្រយាល និង ឬតំបន់ជួបការលំបាក។

មកដល់ឆ្នាំ២០១៩នេះ មូលនិធិដំណើរការសាលារៀនបានកើនឡើងជាលំដាប់។ សាលាបឋមសិក្សាថវិកាថេរបាន៥លាន៣សែន៥ម៉ឺនរៀល ក្នុងមួយសាលាក្នុងមួយឆ្នាំសិក្សា និងថវិកាអថេរបាន១ម៉ឺន ៦ពាន់ មួយរយហាសិបរៀល ក្នុងសិស្សមួយនាក់ នៅក្នុងមួយឆ្នាំសិក្សា (តំបន់ធម្មតា)។ក្រៅពីថវិកាខាងលើ គឺមានថវិកាប្រជុំបច្ចេកទេស ថ្ងៃព្រហស្បតិ៍របស់សាលាបឋមសិក្សា និងថវិកាប្រជុំនៅតាមកម្រងសាលារៀនរបស់សាលាបឋមសិក្សាទៀតផង។ ក្រៅពីនេះសាលាអាចរកប្រភពថវិកាផ្សេងៗក្នុងការទ្រទ្រង់ឱ្យមានដំណើរការជាប់ជាប្រចាំក្នុងឆ្នាំសិក្សានិមួយៗ។ ការប្រើប្រាស់មូលនិធិកែលម្អសាលារៀន សម្រាប់គាំទ្រសកម្មភាពដូចជា ការប្រើប្រាស់សម្ភារបរិក្ខារ និងបរិយាកាសថ្នាក់រៀន (សម្ភារបង្រៀននិងរៀន) សកម្មភាពបង្រៀននិងជួយពង្រឹងសមត្ថភាពរបស់គ្រូ ការជួយកុមារងាយរងគ្រោះ សិស្សរៀនយឺត និងសិស្សមុខសញ្ញាបោះបង់ការសិក្សា (ក្រសួងអប់រំ ២០១៨)។

*ង.ការចូលរួមរបស់សហាគមន៍*

សាលារៀន និងសហាគមន៍ជាកោសិការបស់សង្គមជាតិ។ ជានិច្ចកាល សាលារៀននិងសហាគមន៍មានទំនាក់ទំនងគ្នាទៅវិញទៅមក។ នៅក្នុងចំណុចទី៦ នៃស្តង់ដានាយកសាលារៀន និង

ចំណុចទី៥ នៃក្របខណ្ឌសមត្ថភាពនាយកសាលាអាស៊ានបានលើកឡើង អំពីការផ្សារភ្ជាប់សាលារៀននិងសហគមន៍។ សហគមន៍មានតួនាទីសំខាន់ក្នុងដំណើរការអភិវឌ្ឍសាលា។ ក្រៅពីមូលនិធិដំណើរការសាលារៀនរបស់ក្រសួងអប់រំ គឺសាលារៀនត្រូវរកប្រភពថវិកាជំនួយបន្ថែមក្នុងការទ្រទ្រង់សាលារៀនដែលក្នុងនោះអាចមាន SIG និងថវិកាសប្បុរសជន អង្គការដៃគូ សហគមន៍នៅមូលដ្ឋានមិនតែប៉ុណ្ណោះ នាយកសាលាត្រូវស្វះស្វែងរកថវិកាផ្សេងទៀតតាមរយៈ ការផ្ញើកង់ ម៉ូតូ និងកន្លែងលក់ដូរក្នុងសាលា ការជួលទីតាំងក្នុងនិងក្រៅរបងសាលាដល់អាជីវករលក់ដូរ អ្នកបញ្ញើរថយន្ត ម៉ូតូជាដើម។ នាយកសាលាអាចផ្តើមធ្វើបុណ្យផ្កាសាមគ្គី ឥណទានសាលារៀន សមាគមមាតាបិតាសិស្ស ថវិកាអាជីវករសាលារៀន ថវិកាដឹកជញ្ជូនសិស្ស និងថវិកាសំណល់ (អេតចាយ) និងបង្កើតទិវាអប់រំសិល្បៈតន្ត្រីសិស្សប្រចាំឆ្នាំជាដើម។ ការជួយរបស់សហគមន៍បានរួមចំណែកក្នុងការលើកកម្ពស់គុណភាពបង្រៀន រៀន លទ្ធផលសិក្សារបស់សិស្ស និងការចូលរួមរៀបចំផែនការ ការស្វែងរកធនធាននិងតាមដានសកម្មភាពសាលារៀន (ក្រសួងអប់រំ ២០១៧)។

## ២.៧-ស្ថានភាពសាលាបឋមសិក្សានៅកម្ពុជា

ផ្អែកតាមស្ថិតិ និង សូចនាករអប់រំសាធារណៈឆ្នាំ២០១៨-២០១៩ របស់ក្រសួងអប់រំ ឱ្យដឹងថាសាលាបឋមសិក្សាទូទាំងប្រទេសមានចំនួន ៧២២៨សាលា (សាលាជួបការលំបាក៥៥សាលា) ចំនួនថ្នាក់រៀន៦២២០៨បន្ទប់ ហើយចំនួនថ្នាក់រៀនក្នុងវត្ត ៣៥០បន្ទប់ និងមានចំនួនសិស្សរៀន ២០២៤២៥៧នាក់ (ស្រី៩៧៨៨០០នាក់)។ ចំណែកសិស្សរៀនត្រួតថ្នាក់ចំនួន១២៦៨៣១នាក់ (ស្រី ៥៥៩៥២នាក់)មានបុគ្គលិកបង្រៀនចំនួន៤៥៨៣៦នាក់ (ស្រី២៦១២០នាក់) និងបុគ្គលិកមិនបង្រៀនចំនួន១១៩៧៥នាក់(ស្រី៣៥៣៣នាក់) ដែលសរុបទាំងអស់ចំនួន៥៧៨១១នាក់ (ស្រី២៩៦៥៣នាក់)។

***ក.សាលាបឋមសិក្សានៅខេត្តសៀមរាប*** (ក្រសួងអប់រំ ២០១៨)

ឆ្នាំសិក្សា២០១៨-២០១៩ ខេត្តសៀមរាបមានសាលាបឋមសិក្សាចំនួន៥០៣សាលា (សាលាជួបការលំបាក១សាលា)មានថ្នាក់រៀន៤៥២៧ បន្ទប់រៀន៣១៨០ និងថ្នាក់រៀនក្នុងវត្ត២០មានសិស្ស ១៦៤៦៥២នាក់ (ស្រី៧៩៤១៥នាក់)។ សិស្សរៀនត្រួតថ្នាក់១១៩៧៧នាក់ (ស្រី៤២០៣នាក់) មានបុគ្គលិកបង្រៀន៣១១១នាក់(ស្រី២១៦១នាក់) និងបុគ្គលិកមិនបង្រៀន១០០៨នាក់ (ស្រី៣៦៤នាក់) ដែលសរុបមានបុគ្គលិកអប់រំ៤១១៩នាក់ (ស្រី២៥២៥នាក់)។

***ខ.ស្តង់ដាសាលាបឋមសិក្សា*** (ក្រសួងអប់រំ ២០១៧)

| ស្តង់ដាទី១៖ វត្ថុបំណងគោលនយោបាយរបស់សាលារៀន | | |
|---|---|---|
| **ល.រ** | **សូចនាករ** | **កម្រិតផ្ទៀងផ្ទាត់សូចនាករ** |
| 1 | ការចូលរៀន ឡើងថ្នាក់ និងបោះបង់ | -អត្រាពិតចូលរៀនថ្មី១០០% |

| | | |
|---|---|---|
| | | -អត្រាពិតនៃការសិក្សា១០០%<br>-អត្រាឡើងថ្នាក់៩៧%<br>-អត្រាបោះបង់ការសិក្សា១% |
| 2 | លទ្ធផលតេស្តមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យាថ្នាក់ទី១ដល់ទី៦ | -ភាគរយជាប់តេស្តភាសាខ្មែរឆមាសទីមួយ៩៧%<br>-ភាគរយជាប់តេស្តភាសាគណិតវិទ្យាឆមាសទីពីរ៩៧%<br>-ភាគរយជាប់តេស្តភាសាខ្មែរដំណាច់ឆ្នាំ ៩៨%<br>-ភាគរយជាប់តេស្តគណិតវិទ្យាដំណាច់ឆ្នាំ៩៨% |
| 3 | លទ្ធផលតេស្តសមត្ថភាពអានភាសាខ្មែរនិងលេខនព្វន្តថ្នាក់ទី៣និងទី៦ | -ភាគរយសិស្សថ្នាក់ទី៣អានភាសាខ្មែរបានពី៤៥ទៅ៦០ពាក្យក្នុងមួយនាទី ៩៥%<br>-ភាគរយសិស្សថ្នាក់ទី៦ អានភាសាខ្មែរបានពី១០០ទៅ១២០ពាក្យក្នុងមួយនាទី ៩៥%<br>-ភាគរយសិស្សថ្នាក់ទី៣និងទី៦ ចេះគណនាលេខនព្វន្ត ៩៥% |
| 4 | លទ្ធផលវាយតម្លៃសូចនាករធៀបនឹងសូចនាករស្តង់ដា | -មានពិន្ទុសម្រេចស្តង់ដា នៃប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល |
| ស្តង់ដាទី២៖ បំណែងចែកកម្មវិធីនិងការបង្រៀន រៀន | | |
| 1 | បំណែងចែកកម្មវិធីបង្រៀន | -មានបំណែងចែកកម្មវិធីបង្រៀនទៅតាមមុខវិជ្ជានិងគ្រប់កម្រិតថ្នាក់<br>-មានកម្មវិធីសិក្សាបានធ្វើបច្ចុប្បន្នភាព<br>-ភាគរយថ្នាក់អនុវត្តកម្មវិធីសិក្សាចប់គ្រប់មុខវិជ្ជា ១០០% |
| 2 | កិច្ចតែងការបង្រៀន | -មានកិច្ចតែងការបង្រៀនគ្រប់មុខវិជ្ជានិងគ្រប់កម្រិតថ្នាក់និងបានធ្វើបច្ចុប្បន្នភាព |
| 3 | តេស្តល្បឿនអំណានភាសាខ្មែរថ្នាក់ទី៣និងទី៦ | -ភាគរយសិស្សថ្នាក់ទី៣ អានភាសាខ្មែរបានលើសពី៤៥ពាក្យក្នុងមួយនាទី ៩៥%<br>-ភាគរយសិស្សថ្នាក់ទី៦អានភាសាខ្មែរបានលើសពី១០០ពាក្យក្នុងមួយនាទី ៩៥% |
| 4 | តេស្តសរសេរតាមអានថ្នាក់ទី៣និងទី៦ | -ភាគរយសិស្សថ្នាក់ទី៣ដល់ទី៦ មានលទ្ធផលតេស្តសរសេរតាមអានពី៦ទៅ៨ពិន្ទុ ៧០%<br>-ភាគរយសិស្សថ្នាក់ទី៣ដល់ទី៦ មានលទ្ធផលតេស្ត |

| | | |
|---|---|---|
| | | សរសេរតាមអានលើសពី៨ពិន្ទុ ៣០% |
| 5 | តេស្តសំណេរតែងសេចក្តីថ្នាក់ទី៣ដល់ទី៦ | -ភាគរយសិស្សថ្នាក់ទី៣ដល់ទី៦ មានលទ្ធផលតេស្តសំណេរតែងសេចក្តីពី៦ទៅ៨ពិន្ទុ៧០%<br>-ភាគរយសិស្សថ្នាក់ទី៣ដល់ទី៦ មានលទ្ធផលតេស្តសំណេរតែងសេចក្តីលើសពី៨ពិន្ទុ៣០% |
| 6 | តេស្តគណិតវិទ្យាគ្រប់កម្រិតថ្នាក់ | -ភាគរយសិស្ស មានលទ្ធផលតេស្តគណិតវិទ្យាពី៦ទៅ៨ពិន្ទុ៧០%<br>-ភាគរយសិស្សមានលទ្ធផលតេស្តគណិតវិទ្យាលើសពី៨ពិន្ទុ៣០% |
| 7 | លទ្ធផលប្រឡងឆមាសលើគ្រប់មុខវិជ្ជាគោល | -ភាគរយសិស្សជាប់មធ្យមភាគ ភាសាខ្មែរឆមាសទីមួយ ៩០%<br>-ភាគរយសិស្សជាប់មធ្យមភាគគណិតវិទ្យាឆមាសទីមួយ ៩០%<br>-ភាគរយសិស្សជាប់មធ្យមភាគវិទ្យាសាស្រ្តឆមាសទីមួយ ៩០%<br>-ភាគរយសិស្សជាប់មធ្យមភាគសង្គមឆមាសទីមួយ៩០%<br>-ភាគរយសិស្សជាប់មធ្យមភាគភាសាខ្មែរ ឆមាសទីពីរ ៩៨%<br>-ភាគរយសិស្សជាប់មធ្យមភាគគណិតវិទ្យា ឆមាសទីពីរ ៩៨%<br>-ភាគរយសិស្សជាប់មធ្យមភាគវិទ្យាសាស្រ្ត ឆមាសទីពីរ ៩៨%<br>-ភាគរយសិស្សជាប់មធ្យមភាគសង្គមឆមាសទីពីរ ៩៨% |
| 8 | តេស្តឡើងថ្នាក់សម្រាប់សិស្សធ្លាក់មធ្យមភាគ | -ភាគរយសិស្សតេស្តភាសាខ្មែរជាប់៩៨%<br>-ភាគរយសិស្សតេស្តគណិតវិទ្យាជាប់៩៨% |
| 9 | ការជួបជាមួយមាតាបិតាសិស្សនិងសិស្សប្រចាំត្រីមាស | -ភាគរយមាតាបិតាសិស្សរៀនយឺតបានជួបក្នុងត្រីមាសទីមួយ៩០%<br>-ភាគរយមាតាបិតាសិស្សរៀនយឺតបានជួបក្នុងត្រីមាសទីពីរ៩០%<br>-ភាគរយមាតាបិតាសិស្សរៀនយឺតបានជួបក្នុងត្រីមាសទី |

| | | |
|---|---|---|
| | | បី៩០%<br>ភាគរយសិស្សរៀនយឺតបានជួបក្នុងត្រីមាសទីមួយ៩០%<br>-ភាគរយសិស្សរៀនយឺតបានជួបក្នុងត្រីមាសទីពីរ៩០%<br>-ភាគរយសិស្សរៀនយឺតបានជួបក្នុងត្រីមាសទីបី៩០% |
| 10 | ចំនួនម៉ោងសិក្សាបានបង្រៀនតាមកាលវិភាគ | -ចំនួនម៉ោងបានបង្រៀនក្នុងត្រីមាសទីមួយ ៣៦០ម៉ោង<br>-ចំនួនម៉ោងបានបង្រៀនក្នុងត្រីមាសទីពីរ ៤២០ម៉ោង<br>-ចំនួនម៉ោងបានបង្រៀនក្នុងត្រីមាសទីបី ៣៦០ម៉ោង |
| 11 | វត្តមានសិស្ស | -ភាគរយវត្តមានសិស្សឆមាសទីមួយ៩៥%<br>-ភាគរយវត្តមានសិស្សឆមាសទីពីរ៩៥% |
| 12 | កិច្ចការផ្ទះដាក់ឱ្យសិស្សនិងមានការកែពីគ្រូ | -ភាគរយកិច្ចការផ្ទះជាលំហាត់ ដាក់ឱ្យសិស្សក្នុងត្រីមាសទីមួយ៩០% (នៃចំនួនមេរៀនដែលបានបង្រៀន)<br>-ភាគរយកិច្ចការផ្ទះជាលំហាត់បានកែ និងផ្តល់យោបល់ពីគ្រូក្នុងត្រីមាសទីមួយ១០០%<br>-ចំនួនកិច្ចការផ្ទះ ជាគម្រោងដាក់ឱ្យសិស្សក្នុងត្រីមាសទីមួយ៣គម្រោង<br>-ភាគរយកិច្ចការផ្ទះជាគម្រោងបានកែ និងផ្តល់យោបល់ពីគ្រូក្នុងត្រីមាសទីមួយ១០០%<br>-ភាគរយកិច្ចការផ្ទះជាលំហាត់ត្រូវកែ និងផ្តល់យោបល់ពីគ្រូក្នុងត្រីមាសទីពីរ៩០%<br>-ចំនួនកិច្ចការផ្ទះជាគម្រោងត្រូវកែនិងផ្តល់យោបល់ពីគ្រូក្នុងត្រីមាសទី២១០០%<br>-ចំនួនកិច្ចការផ្ទះ ជាគម្រោងដាក់ឱ្យសិស្សក្នុងត្រីមាសទីពីរ៣គម្រោង<br>-ភាគរយកិច្ចការផ្ទះជាគម្រោងត្រូវកែនិងផ្តល់យោបល់ពីគ្រូក្នុងត្រីមាសទីពីរ១០០% |
| 13 | ការប្រើប្រាស់សៀវភៅតាមដានការសិក្សានិងសៀវភៅទំនាក់ទំនងមាតាបិតាសិស្ស | -ភាគរយសៀវភៅតាមដានការសិក្សា ប្រើប្រាស់ទៀងទាត់១០០%<br>-ភាគរយសៀវភៅទំនាក់ទំនងទូរស័ព្ទ ទៅមាតាបិតាសិស្សបានប្រើប្រាស់ទៀងទាត់១០០%<br>ភាគរយព័ត៌មានត្រឡប់បានប្រើប្រាស់ទៀងទាត់១០០% |

| | | |
|---|---|---|
| 14 | ការសិក្សាស្រាវជ្រាវមេរៀនដោយក្រុមបច្ចេកទេស | -ចំនួនមេរៀនមុខវិជ្ជាគោលបានសិក្សាស្រាវជ្រាវ |
| 15 | កម្មវិធីណែនាំគ្រូចេញថ្មីនិងគ្រូកិច្ចសន្យា | -គ្រូចេញថ្មី និងគ្រូកិច្ចសន្យាទាំងអស់ បានទទួលការណែនាំផ្នែកបច្ចេកទេស និងផ្នែករដ្ឋបាលមុនពេលកាន់ថ្នាក់ |
| 16 | រដ្ឋបាលថ្នាក់ | -ភាគរយគ្រូ មានឯកសារលទ្ធផលសិក្សាសិស្សពីឆ្នាំមុនគ្រប់គ្រាន់១០០%<br>-ភាគរយគ្រូ មានឯកសាររដ្ឋបាលថ្នាក់គ្រប់គ្រាន់ក្នុងឆមាសទីមួយនិងទីពីរ ១០០%<br>-មានបញ្ជីតាមដានវត្តមានគ្រូ និងវត្តមានសិស្ស (ទាំងចេញ-ចូល) |
| 17 | សកម្មភាពអប់រំកាយនិងកីឡា | -មានសកម្មភាពអប់រំកាយនិងកីឡាគ្រប់ម៉ោងកំណត់ក្នុងត្រីមាសគ្រប់ថ្នាក់ |
| 18 | សកម្មភាពអប់រំសុខភាព | -មានការអប់រំបង្ការគ្រោះមហន្តរាយ(ទឹកជំនន់ ខ្យល់ព្យុះរន្ទះ ការប្រែប្រួលអាកាសធាតុ)<br>-មានការបំប៉នគ្រូទទួលបន្ទុកសុខភាពសិក្សា ស្តីពីវិធីសាស្រ្តសង្គ្រោះបឋម និងផ្តល់ប្រអប់សង្គ្រោះបឋម<br>-មានការអប់រំអនាម័យអាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារនិងជំងឺឆ្លងនិងមិនឆ្លង<br>-មានសៀវភៅតាមដានសុខភាពសិស្ស<br>-មានសកម្មភាពអប់រំសុខភាពគ្រប់ម៉ោង កំណត់ក្នុងត្រីមាសគ្រប់ថ្នាក់ |
| 19 | សកម្មភាពអប់រំបំណិនជីវិតមូលដ្ឋាន | -ភាគរយសិស្សមានជំនាញផ្នែកគេហកិច្ច៥០%<br>-ភាគរយសិស្សមានជំនាញផ្នែករោងជាង៥០%<br>-ភាគរយសិស្សមានជំនាញផ្នែកកសិកម្ម៥០%<br>-ភាគរយសិស្សមានជំនាញផ្នែកសិល្បៈ៥០%<br>-ភាគរយសិស្សមានជំនាញផ្នែកគំនូរ៥០%<br>-ភាគរយសិស្សមានជំនាញផ្នែកចម្លាក់៥០% |
| ស្តង់ដាទី៣៖ ការងារមាតាបិតាសិស្សនិងសហគមន៍ | | |
| 1 | ការជួបជុំពិគ្រោះយោបល់រវាងមាតាបិតា | -គ្រូទាំងអស់បានប្រជុំជាមួយមាតាបិតាសិស្ស និងសិស្ស |

| | | |
|---|---|---|
| | សិស្ស គ្រូបង្រៀន និងសិស្ស | ឱ្យបានយ៉ាងតិចម្តងក្នុងមួយត្រីមាស (កំណត់ហេតុ) |
| 2 | ការបង្កើត និងដំណើរការរបស់គណៈកម្មការគ្រប់គ្រងសាលារៀន | -បានបង្កើតតាមសេចក្តីណែនាំលេខ៣០ អយក សណន<br>-មានដំណើរការតួនាទី ភារកិច្ច ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ៣០ អយក សណន<br>-បានប្រជុំទៀងទាត់តាមកំណត់ |
| 3 | មាតាបិតា អាណាព្យាបាលសិស្ស សន្យាជួយសិស្សដែលមករៀនមិនទៀងទាត់និងមិនទាន់ពេល | -ភាគរយមាតាបិតា/ អាណាព្យាបាលសិស្ស ដែលមករៀនមិនទៀងទាត់ និងមិនទាន់ពេលបានសន្យា១០០%<br>-ភាគរយសិស្សមករៀនមិនទាន់ពេល ចុះថយនៅសល់យ៉ាងតិចត្រឹម៥% |
| 4 | មាតាបិតាអាណាព្យាបាលសន្យាជួយតាមដានការសិក្សារបស់កូន | -ភាគរយមាតាបិតា/ អាណាព្យាបាលសិស្ស ជួយជំរុញនិងតាមដានកូនធ្វើកិច្ចការផ្ទះ និងគម្រោង១០០%<br>-រាល់កិច្ចការផ្ទះគម្រោងរបស់សិស្ស មានការចុះហត្ថលេខាដោយមាតាបិតា/ អាណាព្យាបាល (ពិនិត្យកិច្ចការសិស្ស) |
| 5 | អាជ្ញាធរមូលដ្ឋាន មានការចូលរួមកិច្ចការសាលារៀន | -អាជ្ញាធរមូលដ្ឋាន បានចូលរួមរៀបចំផែនការអភិវឌ្ឍសាលារៀន។<br>-អាជ្ញាធរមូលដ្ឋាន បានសហការក្នុងការរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខនៅជុំវិញសាលារៀន។ |
| ស្តង់ដាទី៤៖ សិស្សនិងសេវាជួយសិស្ស | | |
| 1 | សិស្សប្រើបណ្ណាល័យ | -ចំនួនដងសិស្សប្រើបណ្ណាល័យ ជាមធ្យមក្នុងត្រីមាស ៣០ដង<br>-ភាគរយអនុវត្តកម្មវិធីកាលវិភាគ សម្រាប់សិស្សទទួលចូលអាន១០០% |
| 2 | សិស្សប្រើប្រាស់បន្ទប់ពិសោធន៍ | -ភាគរយសិស្សរៀនពិសោធន៍តាមកាលវិភាគ១០០%<br>-ភាគរយអនុវត្តកម្មវិធីកាលវិភាគ សម្រាប់មេរៀនពិសោធន៍១០០% |
| 3 | សិស្សប្រើប្រាស់បន្ទប់រៀនភាសាបរទេស | -ភាគរយសិស្សរៀនភាសាបរទេសកាលវិភាគ១០០%<br>-ភាគរយអនុវត្តកម្មវិធីការរៀនភាសាបរទេស១០០%<br>-ចំនួនសិស្សមានជំនាញភាសាបរទេសកើនឡើង |

| | | |
|---|---|---|
| 4 | សិស្សប្រើប្រាស់បន្ទប់រៀនកុំព្យូទ័រ | -ភាគរយសិស្សរៀនកុំព្យូទ័រតាមកាលវិភាគ១០០%<br>-ភាគរយអនុវត្តកម្មវិធីកាលវិភាគរៀនកុំព្យូទ័រ១០០%<br>-ចំនួនសិស្សមានជំនាញកុំព្យូទ័រកើនឡើង |
| 5 | ថ្នាក់ដែលមានក្រុមសិស្សជួយគ្នា និងសាលាមានក្រុមប្រឹក្សាកុមារនិងទីប្រឹក្សាកុមារី | -មានក្រុមសិស្សជួយសិស្សតាមថ្នាក់មានដំណើរការ<br>-មានក្លឹបសិក្សា<br>-មានក្រុមប្រឹក្សាកុមារមានដំណើរការ<br>-មានគ្រូជួយប្រឹក្សាសម្រាប់កុមារីដំណើរការតាមកម្មវិធីនិងតាមកាលវិភាគ |
| 6 | ការគាំទ្រសិស្សខ្សោយគំហើញនិងសិស្សខ្សោយស្តាប់ | -សិស្សខ្សោយគំហើញនិងខ្សោយស្តាប់ទាំងអស់ត្រូវបានយកចិត្តទុកដាក់និងគាំទ្រជាចាំបាច់ដែលមានអន្តរាគមន៍ផ្ទាល់ពីសាលាឬសាលាបានសុំពីអ្នកពាក់ព័ន្ធ។ |
| 7 | លទ្ធផលសិក្សារបស់សិស្សខ្សោយគំហើញនិងខ្សោយស្តាប់ | -ភាគរយសិស្សខ្សោយគំហើញសម្រេចលទ្ធផលសិក្សាបានល្អលើសពី៦០%<br>-ភាគរយសិស្សខ្សោយស្តាប់សម្រេចលទ្ធផលសិក្សាល្អលើសពី៦០% |
| 8 | សិស្សទទួលបានអាហារពេលព្រឹក/ថ្ងៃត្រង់ | -ភាគរយចម្អិនអាហារពេលព្រឹក/ ថ្ងៃត្រង់នៅថ្ងៃសិក្សា១០០%<br>-ភាគរយសិស្សហូបអាហារព្រឹក/ថ្ងៃត្រង់ លើស៩០%<br>-ការរៀបចំអាហារពេលព្រឹក/ថ្ងៃត្រង់មានអនាម័យសុវត្ថិភាពនិងសារជាតិគាំទ្រ<br>-ការរៀបចំអាហារពេលព្រឹក/ ថ្ងៃត្រង់មិនប៉ះពាល់ម៉ោងសិក្សា |
| 9 | សិស្សទទួលបានអាហារូបករណ៍ | -ភាគរយសិស្សអាហារូបករណ៍ បានមករៀនទៀងទាត់និងចប់ភូមិសិក្សាលើសពី៩០% |
| 10 | ការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា | -មានដំណើរការ គណៈកម្មការទទួលបន្ទុកសុខភាពសិក្សាតាមសាលារៀន<br>-មានដំណើរការបន្ទប់សុខភាពនិងការប្រើប្រាស់សម្ភារបរិក្ខារពេទ្យ(តាមលទ្ធភាព)ដែលបានលើកក្នុងផែនការសាលារៀន<br>-មានការប្រើប្រាស់កន្លែងលាងដៃតាមមាត្រដ្ឋាន (ទឹក |

| | | |
|---|---|---|
| | | សាប៊ូ...)<br>-មានការផ្តល់ថ្នាំទម្លាក់ព្រូន ក្នុងមួយឆ្នាំពីរដងឬមួយដងយ៉ាងតិច។<br>-កុមារា និងកុមារី ប្រើប្រាស់បង្គន់អនាម័យដាច់ដោយឡែក កុមារពិការមានជម្រាលចូលប្រើប្រាស់បង្គន់<br>-មានការប្រើប្រាស់ប្រព័ន្ធទឹកស្អាត ទឹកផឹក<br>-មានការអប់រំសុខភាពមាត់ធ្មេញ អប់រំបង្ការជំងឺឆ្លងនិងជំងមិនឆ្លង |
| 11 | ទស្សនកិច្ចសិក្សារបស់គ្រូ | -មានទស្សនកិច្ចសិក្សា សម្រាប់ផ្លាស់ប្តូរបទពិសោធន៍របស់គ្រូ |
| 12 | ទស្សនកិច្ចសិក្សាសម្រាប់សិស្ស | -មានទស្សនកិច្ចសិក្សាសម្រាប់សិស្ស |
| ស្តង់ដាទី៥៖ ការដឹកនាំនិងគ្រប់គ្រង | | |
| 1 | ការគ្រប់គ្រងនិងរដ្ឋបាលសាលារៀន | -មានដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន<br>-មានរៀបចំរចនាសម្ព័ន្ធរដ្ឋបាលសាលារៀនត្រឹមត្រូវ<br>-មានគណៈកម្មការនិងក្រុមប្រឹក្សានានារបស់សាលា<br>-មានអនុវត្តផែនទីខ្នងផ្ទះ មានស្ថិតិដែលបានធ្វើបច្ចុប្បន្នភាពជាប្រចាំ<br>-មានទំនាក់ទំនងជាមួយសហការី សហគមន៍ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធនានា |
| 2 | ផែនការអភិវឌ្ឍសាលារៀននិងការអនុវត្ត | -មានផែនការអភិវឌ្ឍសាលារៀន (ចក្ខុវិស័យ បេសកកម្ម វត្ថុគោលបំណងនយោបាយ គោលដៅ និងសកម្មភាពច្បាស់លាស់) រយៈពេលខ្លី ឬមធ្យម ឬវែង<br>-មានផែនការប្រតិបត្តិប្រចាំឆ្នាំ<br>-មានរបាយការណ៍វឌ្ឍនភាព<br>-មានយន្តការប្រមូលកុមារចូលរៀន<br>-មានការវាយតម្លៃការអនុវត្តផែនការប្រតិបត្តិឆ្នាំ<br>-មានស្វ័យវាយតម្លៃសាលារៀនធៀបនឹងស្តង់ដា (ជាប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល) |
| 3 | ការងារអធិការកិច្ចថ្នាក់រៀន | -មានផែនការ និងចុះអធិការកិច្ចរៀងរាល់ខែ និងត្រីមាស<br>-មានប្រើប្រាស់ឧបករណ៍អធិការកិច្ច |

| | | |
|---|---|---|
| | | -មានរៀបចំរបាយការណ៍អធិការកិច្ច<br>-ថ្នាក់រៀននីមួយៗមានសៀវភៅអនុសាសន៍ |
| 4 | ការប្រជុំរបស់សាលារៀន | -មានការប្រជុំបច្ចេកទេសទៀងទាត់<br>-មានការប្រជុំគរុកោសល្យ<br>-មានការប្រជុំផ្សេងៗ<br>-មានរបៀបវារៈ និងកំណត់ហេតុប្រជុំ |
| 5 | ការវាយតម្លៃប្រចាំឆ្នាំលើការអនុវត្តការងាររបស់គ្រូបង្រៀន | -ភាគរយគ្រូអនុវត្តការងារបានល្អយ៉ាងតិច៩០%<br>-មានស្វ័យវាយតម្លៃក្នុងការបំពេញការងារ<br>-មានការវាយតម្លៃតាមប្រព័ន្ធវាយតម្លៃ ការបំពេញការងាររបស់បុគ្គលិកអប់រំ<br>-មានកម្រងភារកិច្ចច្បាស់លាស់ |
| 6 | ការទប់ស្កាត់បាតុភាពមិនប្រក្រតី | -មានការផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុង<br>-មានវិធានការទប់ស្កាត់ភាពមិនប្រក្រតី<br>-មានការអនុវត្ត ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនពេញលេញ<br>-ភាគរយការអនុវត្ត ការផ្សព្វផ្សាយលិខិតបទដ្ឋាននានា ១០០% |
| 7 | ប្រសិទ្ធភាពនៃការអនុវត្តសាលាកុមារមេត្រី | -ជាសាលាកុមារមេត្រី<br>-មានការអនុវត្តសមាសភាពទាំងប្រាំមួយ ក្នុងសាលាកុមារមេត្រី១០០% |
| ស្តង់ដាទី៦៖ ធនធានមនុស្សនិងរចនាសម្ព័ន្ធគ្រប់គ្រង | | |
| 1 | គណៈគ្រប់គ្រងសាលារៀន | -មានគណៈគ្រប់គ្រងសាលារៀនស្របតាមនិយាម<br>-នាយកសាលា មានចំណេះដឹងទាបបំផុតត្រឹមបរិញ្ញាបត្រឬសមមូល<br>-នាយកសាលាមានចំណេះដឹងភាសាបរទេស និងIT<br>-មានភាពជាអ្នកដឹកនាំក្នុងការដឹកនាំ និងគ្រប់គ្រង<br>-នាយកឬគណៈគ្រប់គ្រងសាលារៀន មានការតែងតាំងជាផ្លូវការ<br>-នាយកសាលាបានឆ្លងកាត់វគ្គបណ្តុះបណ្តាល<br>-មានសមត្ថភាពដឹកនាំអនុវត្តកម្មវិធីសិក្សា |

| | | |
|---|---|---|
| | | -មានការបង្កើតបរិស្ថានសិក្សា តាមគោលវិធីសិស្សមជ្ឈមណ្ឌល<br>-មានកត់ត្រា និងតាមដានលទ្ធផលសិក្សាតាមផែនការ |
| 2 | គុណវុឌ្ឍិគ្រូ | -មានការឆ្លងកាត់វគ្គបណ្តុះបណ្តាល និង វិក្រឹតការគ្រូ<br>-មានការស្រាវជ្រាវបង្កើតថ្មី និងចងក្រងជាឯកសារឬសៀវភៅ<br>-មានគុណវុឌ្ឍិស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន |
| 3 | ការប្រើប្រាស់ធនធានមនុស្ស | -មានការប្រើប្រាស់បុគ្គលិក តាមសេចក្តីណែនាំស្តីពីនិយាមបុគ្គលិកអប់រំ (ផលធៀបគ្រូថ្នាក់ សិស្សគ្រូ សិស្ស សិស្សនិងសិស្សបន្ទប់)<br>-មានការប្រើប្រាស់គ្រូបង្រៀនគ្រប់ជំនាញ បណ្ណារក្សរោងជាង កុំព្យូទ័រ ពិសោធន៍ កសិកម្ម គំនូរ ចម្លាក់និងសូនរូប សិល្បៈ តូរ្យតន្ត្រី និងកីឡា ស្របតាមនិយាមណែនាំរបស់ក្រសួង។ |
| ស្តង់ដាទី៧៖ កម្មវិធីសិក្សានិងសម្ភារបង្រៀននិងរៀន | | |
| 1 | កម្មវិធីសិក្សាមុខវិជ្ជាគោល | -ភាគរយថ្នាក់ប្រើប្រាស់កម្មវិធីសិក្សា ស្របតាមស្តង់ដាកម្មវិធីសិក្សាដែលបានកំណត់១០០% |
| 2 | ស្ថានភាពសៀវភៅសិក្សាគោល | -ភាគរយសិស្ស មានសៀវភៅប្រើប្រាស់គោលគ្រប់គ្រាន់ ១០០% |
| 3 | ស្ថានភាពសៀវភៅគ្រូ | -ភាគរយគ្រូមានសៀវភៅប្រើប្រាស់គ្រប់គ្រាន់១០០% |
| 4 | សម្ភារឧបទេស | -ភាគរយគ្រូមានសម្ភារឧបទេសគ្រប់គ្រាន់ ឆ្លើយតបទៅនឹងខ្លឹមសារមេរៀននីមួយៗគ្រប់មុខវិជ្ជា១០០% |
| 5 | បណ្ណាល័យ | -មានសម្ភារៈបរិក្ខារ និងសៀវភៅឯកសារអំណានស្តង់ដា<br>-មានផែនការបង្កើតឬពង្រីកបណ្ណាល័យ |
| 6 | បន្ទប់រៀនភាសាបរទេស | -មានសម្ភារៈគ្រប់គ្រាន់សម្រាប់គ្រូនិងសិស្ស<br>-មានកម្មវិធីរៀនភាសាបរទេស<br>-មានផែនការបង្កើតឬពង្រីកបន្ទប់រៀនភាសាបរទេស |
| 7 | បន្ទប់ពិសោធន៍ | -មានសម្ភារៈពិសោធន៍គ្រប់គ្រាន់<br>-មានកម្មវិធីរៀនពិសោធន៍ |

| | | |
|---|---|---|
| | | -មានផែនការបង្កើតឬពង្រីកបន្ទប់ពិសោធន៍ |
| 8 | បន្ទប់រោងជាង | -មានសម្ភារៈរោងជាងគ្រប់គ្រាន់<br>-មានកម្មវិធីរៀនជំនាញរោងជាង<br>-មានផែនការបង្កើតឬពង្រីកបន្ទប់រោងជាង |
| 9 | បន្ទប់រៀនកសិកម្ម | -មានសម្ភារៈគ្រប់គ្រាន់និងសួនសម្រាប់អនុវត្ត<br>-មានកម្មវិធីរៀនជំនាញកសិកម្ម<br>-មានផែនការបង្កើតឬពង្រីកបន្ទប់រៀនកសិកម្ម |
| 10 | បន្ទប់រៀនសិល្បៈនិងតូរ្យតន្ត្រី | -មានឧបករណ៍តូរ្យតន្ត្រីគ្រប់គ្រាន់សម្រាប់គ្រូ និងសិស្ស<br>-មានម្មវិធីរៀនជំនាញខាងសិល្បៈ និងតូរ្យតន្ត្រី<br>-មានផែនការបង្កើតឬពង្រីកបន្ទប់រៀន សិល្បៈ តូរ្យតន្ត្រី |
| 11 | បន្ទប់រៀនគំនូរចម្លាក់និងសូនរូប | -មានសម្ភារៈគ្រប់គ្រាន់សម្រាប់គ្រូនិងសិស្ស<br>-មានកម្មវិធីរៀនជំនាញគំនូរចម្លាក់ និងសូនរូប<br>-មានផែនការបង្កើតឬពង្រីកបន្ទប់រៀនគំនូរចម្លាក់សូនរូប |
| 12 | បន្ទប់រៀនគេហកិច្ច | -មានសម្ភារៈគ្រប់គ្រាន់(ដេរប៉ាកនិងដាំស្ល)<br>-មានកម្មវិធីរៀនជំនាញគេហកិច្ច<br>-មានផែនការបង្កើតឬពង្រីកបន្ទប់គេហកិច្ច |
| 13 | បន្ទប់រៀនកុំព្យូទ័រ | -មានកុំព្យូទ័រនិងសម្ភារៈគ្រប់គ្រាន់<br>-មានកម្មវិធីរៀនជំនាញកុំព្យូទ័រ<br>-មានផែនការបង្កើតឬពង្រីកបន្ទប់រៀនកុំព្យូទ័រ |
| 14 | បន្ទប់កីឡានិងសកម្មភាព | -មានទីកន្លែងហាត់កីឡា<br>-មានកម្មវិធីហ្វឹកហាត់កីឡា<br>-មានផែនការបង្កើត ឬពង្រីកទីលានសម្រាប់ហាត់កីឡា<br>-មានបន្ទប់ដាក់សម្ភារៈកីឡា និងកន្លែងសិស្សផ្លាស់ប្តូរសំលៀកបំពាក់ |
| ស្តង់ដាទី៨៖ ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន | | |
| 1 | អគារសិក្សានិងបន្ទប់រៀន | -មានអគារសិក្សា តាមនិយាមគរុកោសល្យតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួង។<br>-មានបន្ទប់សិក្សា ធៀបនឹងចំនួនសិស្សស្របតាមនិយាមគរុកោសល្យរបស់ក្រសួង។ |

| | | |
|---|---|---|
| | | -មានបន្ទប់ទីចាត់ការ សាលប្រជុំ សាលគ្រូបង្រៀនបន្ទប់ធនធានបន្ទប់ថែទាំសុខភាពបង្គន់អនាម័យបុរស និងស្ត្រីតាមនិយាមប្រើឬតាមសមាមាត្រចំនួនសិស្ស<br>-អគារនិងបន្ទប់ទាំងអស់មានជម្រាលសម្រាប់សិស្សពិការ<br>-មានបំពាក់សម្ភារៈបរិក្ខារអគ្គិសនីនៅលើអគារ និងបន្ទប់សិក្សា |
| 2 | អគារស្នាក់នៅសម្រាប់បុគ្គលិក និងអន្តេវាសិកដ្ឋានសិស្ស | -មានអគារស្នាក់នៅសម្រាប់បុគ្គលិកសិក្សា ដែលមានលំនៅក្រៅមូលដ្ឋាន។<br>-មានអន្តេវាសិកដ្ឋានសម្រាប់សិស្សប្រុស និងស្រី តាមតម្រូវការសាលារៀនមានសិស្សមកពីឆ្ងាយ។<br>-មានបន្ទប់ទឹក និងបង្គន់អនាម័យគ្រប់គ្រាន់។ |
| 3 | សម្ភារៈបរិក្ខារនិងការផ្គត់ផ្គង់ | -បន្ទប់ទីចាត់ការ ត្រូវមានគ្រឿងសង្ហារឹមនិងបរិក្ខារបច្ចេកទេសកុំព្យូទ័រ ព្រីនធ័រ ទូដាក់ឯកសារ និងទូដែក<br>-មានផ្គត់ផ្គង់សម្ភារៈបរិក្ខារសមស្រប សម្រាប់សាលប្រជុំបន្ទប់ធនធាន បណ្ណាល័យបន្ទប់រៀនភាសាបរទេសបន្ទប់រៀនកុំព្យូទ័របន្ទប់ពិសោធន៍បន្ទប់រោងជាងបន្ទប់រៀនគំនូរចម្លាក់និងសូនរូបបន្ទប់រៀនសិល្បៈនិងតូរ្យតន្ត្រី បន្ទប់ថែទាំសុខភាពប្រអប់សង្គ្រោះបឋមបង្គន់អនាម័យ(សម្រាប់បុរសនិងសម្រាប់ស្ត្រី)និងកន្លែងលាងសម្អាតដៃ<br>-មានផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់<br>-មានផ្គត់ផ្គង់បណ្តាញអគ្គិសនី |
| 4 | បរិស្ថានសាលារៀន | -មានរបង និងទ្វារសាលារៀនគត់មត់ ស្លាកខ្លោងទ្វារ ទីធ្លាសាលាសួនច្បារ ដង់ទង់ជាតិ សួនជីវៈចម្រុះ ទីលានកីឡា សួនកុមារ មណ្ឌលវប្បធម៌ប្រពៃណី រោងបាយធុងសំរាម និងឡដុតសំរាម។<br>-មានកន្លែងចតយានជំនិះគ្រប់ប្រភេទ និងមានសណ្តាប់ធ្នាប់<br>-មានផ្លូវដើរពីអគារមួយទៅអគារមួយទៀត<br>-មានដើមឈើជាម្លប់<br>-បើមានកន្លែងលក់ចំណីអាហារ ត្រូវមានអនាម័យ និងសុវត្ថិភាព |

| ស្តង់ដាទី៩៖ ការគ្រប់គ្រងហិរញ្ញវត្ថុ | | |
|---|---|---|
| 1 | ការគ្រោងនិងការទទួលថវិកា | -ការគ្រោងថវិការបស់សាលារៀន ផ្អែកលើតម្រូវការមូលដ្ឋានជាក់ស្តែងពិសេសផ្តោតលើការពង្រឹងគុណភាពអប់រំ<br>-មានការចូលរួមសម្រេចចិត្ត និងទទួលព័ត៌មានពីគ្រប់អ្នកពាក់ព័ន្ធ<br>-សាលារៀនទទួលបានថវិកាគ្រប់គ្រាន់ ទាន់ពេលវេលា<br>-មានការប្រើប្រាស់ប្រព័ន្ធធនាគារ |
| 2 | ការចំណាយថវិកាប្រចាំឆ្នាំ | -មានការចូលរួមពីគណៈកម្មការគ្រប់គ្រងថវិកា សម្រេចចិត្តប្រើប្រាស់ថវិកាតាមការណែនាំ<br>-មានកិច្ចបញ្ជិការគណនេយ្យ និងសម្ភារៈនិងតារាងតម្លាភាព។<br>-មានការត្រួតពិនិត្យផ្ទៃក្នុងសាលារៀន លើការប្រើប្រាស់ថវិកា<br>-មានការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ កិច្ចបញ្ជិកាគណនេយ្យ |

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១-ដំណើរការនៃការស្រាវជ្រាវ

យោងតាមលិខិតឧទ្ទេសនាមលេខ: ៩៦៣៣ អយក.ឧទន ចុះថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជននិងកីឡា ស្តីពីការចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវតាមសាកលវិទ្យាល័យ និងរាជធានី ខេត្តនានា ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករាឆ្នាំ២០២០ នៅតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ និង ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ របស់វិទ្យាស្ថានជាតិអប់រំ។ អ្នកសិក្សាបានរៀបចំរួចរាល់ ដើម្បីយកលិខិតឧទ្ទេសនាមទៅឱ្យមន្ទីរអប់រំខេត្តនិងសាលារៀនគោលដៅ ព្រមទាំងភ្ជាប់ជាមួយនូវកម្រងសំណួរ និងសំណួរសម្ភាសពេលចុះប្រមូលទិន្នន័យ យកមកធ្វើការវិភាគទិន្នន័យសម្រាប់សរសេរក្នុងនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

### *៣.១.១-វិធីសាស្ត្រប្រមូលទិន្នន័យ*

នៅក្នុងការចុះប្រមូលទិន្នន័យនៅសាលាក្នុងខេត្តសៀមរាប គឺអ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកបុគ្គលិកអប់រំក្នុងសាលារៀន ជាគោលដៅសម្រាប់ធ្វើការសម្ភាសនិងបំពេញកម្រងសំណួរ។ អ្នកចូលរួមទាំងនោះរួមមាន នាយក នាយករង លេខាធិការ គ្រូបង្រៀនថ្នាក់ទី១ដល់ទី៦ ព្រមទាំងសហគមន៍ជុំវិញសាលា ដោយឱ្យពួកគាត់ផ្តល់ព័ត៌មានត្រឡប់មកវិញ ជុំវិញការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា។

## ៣.២-ឧបករណ៍និងការប្រមូលទិន្នន័យ

### *៣.២.១-ឧបករណ៍*

នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ ចាំបាច់ត្រូវប្រើប្រាស់កម្រងសំណួរធ្វើជាឧបករណ៍សម្រាប់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងភាគីពាក់ព័ន្ធ ក្នុងការប្រមូលទិន្នន័យយកមកវិភាគរកលទ្ធផល។ កម្រងសំណួរនេះបានពិនិត្យ និងកែលម្អដោយសាស្ត្រាចារ្យដឹកនាំ ដើម្បីរកឱ្យឃើញពីការអនុវត្តការងារ និងបញ្ហាប្រឈមនានាទាក់ទងការគ្រប់គ្រងសាលារៀន។

នៅក្នុងកម្រងសំណួរនេះមាន៥ផ្នែកសំខាន់ៗគឺ៖

-ផ្នែកទី១៖ និយាយអំពីព័ត៌មានទូទៅ ភេទ អាយុ កម្រិតវប្បធម៌ តួនាទី ឯកទេស បទពិសោធន៍ការងារនិងក្របខណ្ឌរបស់នាយក និងគ្រូបង្រៀន។ ចំពោះកម្រងសំណួរសម្រាប់សម្ភាសនាយករួមមានស្ថិតិបុគ្គលិក ស្ថិតិសិស្សនិងថ្នាក់រៀន អគារសិក្សានិងបន្ទប់រៀន។

-ផ្នែកទី២៖ និយាយពីសូចនាករទាំង៩នៃស្តង់ដាសាលាបឋមសិក្សា។

-ផ្នែកទី៣៖ និយាយពីការគ្រប់គ្រងសាលារៀនរបស់នាយកសាលា ។

-ផ្នែកទី៤៖ ការឆ្លើយសំណួរទាក់ទងកម្រិតការគ្រប់គ្រងនិងដឹកនាំរបស់នាយកព្រមទាំងបញ្ហាប្រឈម

នៅក្នុងសាលារៀន។

-ផ្នែកទី៥៖ យោបល់និងសំណូមពរផ្សេងៗ។

*៣.២.២.ការប្រមូលទិន្នន័យ*

ការប្រមូលទិន្នន័យធ្វើឡើងមាន២បែប៖

-ទិន្នន័យបែបទីមួយ: ការផ្ទៀងផ្ទាត់ឯកសារតារាងPRIរបស់សាលារៀននៅការិយាល័យផែនការ និង គ្រប់គ្រងជំនួយនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប និងឯកសារពាក់ព័ន្ធដទៃទៀត មុននឹង ចុះទៅប្រមូលទិន្នន័យផ្ទាល់នៅសាលារៀន។

-ទិន្នន័យបែបទីពីរ: ការចុះទៅអនុវត្តដោយផ្ទាល់នៅក្នុងការប្រមូលទិន្នន័យចំពោះនាយក នាយករង លេខាធិការ គ្រូបង្រៀន និងសហគមន៍។

## ៣.៣-វិធីសាស្ត្រវិភាគទិន្នន័យ

នៅក្នុងការវិភាគទិន្នន័យនេះ គឺអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រ បែបបរិមាណ វិស័យនិងគុណវិស័យ។ វិធីសាស្ត្រនេះ មានការចូលរួមក្នុងការសម្ភាស និងបំពេញសម្ភាសសំណួរ ពីសំណាក់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងភាគីពាក់ព័ន្ធ។ ទាក់ទងទិន្នន័យតាមបែប បរិមាណវិស័យគឺប្រមូលតាមរយៈការបំពេញកម្រងសំណួរបិទនិងការប្រមូលស្ថិតិតាមសាលា។ ការ វិភាគទិន្នន័យបែបបរិមាណវិស័យ គឺវិភាគតាមក្រាប និងតារាងដោយប្រើកម្មវិធីExcel។ បរិមាណ វិស័យជាលេខ ចំនួននិងភាគរយ។ ចំណែកទិន្នន័យតាមគុណវិស័យវិញ ប្រមូលតាមរយៈការបំពេញ កម្រងសំណួរបើក និងស្ថិតិរបស់សាលា។ វិភាគទិន្នន័យបែបគុណវិស័យ តាមរយៈការចាត់ថ្នាក់ជា ក្រុមនិងដាក់ចំណងជើងដោយផ្អែកលើទស្សនៈ និងអត្ថន័យនៃប្រយោគ ដែលមានលក្ខណៈប្រហាក់ ប្រហែលរួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ។

# ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

ការសិក្សាស្រាវជ្រាវប្រធានបទ «ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា» ករណីសិក្សាខេត្តសៀមរាប គឺជាការសិក្សាដោយបានជ្រើសរើសយកសាលាបឋមសិក្សាចំនួន១៤ ក្នុងចំណោមសាលាបឋមសិក្សាទាំងអស់ ក្នុងក្រុងសៀមរាបមានចំនួន៥៣សាលា និង៨កម្រងយកមកសរសេរជានិក្ខេបបទដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ។

## ៤.១-សាលាបឋមសិក្សាទី១

នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាទី១មាន គ្រូសរុប១២៩នាក់ (ស្រី៩៩នាក់) សិស្សសរុប៦៣២១នាក់(ស្រី៣១០៤នាក់) មានបន្ទប់ចំនួន១១៦ បង្រៀន២វេន។ សាលាមានអគារ១៤ខ្នង ៦៦បន្ទប់ និងបន្ទប់រៀន៥៨ថ្នាក់ ហើយបន្ទប់ប្រើប្រាស់សរុបចំនួន៦៦។ សាលារៀនមានគណៈគ្រប់គ្រងសាលារៀន២នាក់ បុគ្គលិកទីចាត់ការ២នាក់ (ស្រី២នាក់) បណ្ណារក្ស២នាក់ គ្រូបង្រៀនសុទ្ធសាធ១១៦នាក់ (ស្រី៩៤នាក់) និងបុគ្គលិកផ្សេងៗ៧នាក់ (ស្រី៣នាក់)។ ចំណែកគ្រូបង្រៀនថ្នាក់ទី១ដល់ទី៦មានចំនួន១០២នាក់ (ស្រី៨០នាក់)។

***ក.ព័ត៌មានអំពីបុគ្គលិកអប់រំ***

គណៈគ្រប់គ្រងសាលាព្រមទាំងលោកគ្រូ អ្នកគ្រូ ក្នុងសាលាបឋមសិក្សាទី១ បានចូលរួមឆ្លើយសំណួរ និងបំពេញកម្រងសំណួរអំពី ការអនុវត្តគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ។ ការបំពេញកម្រងសំណួរនេះរួមមាន គណៈគ្រប់គ្រងសាលារៀន២នាក់ គ្រូបង្រៀន៣៩នាក់ (ស្រី៣៥នាក់) និងសហគមន៍៤នាក់ (ស្រី៤នាក់)។

លទ្ធផលទទួលបានតាមផ្នែកនីមួយៗមានដូចខាងក្រោម៖

| លរ | ភេទ | អាយុ | កម្រិតវប្បធម៌ | តួនាទី | បទពិសោធន៍ | ក្របខណ្ឌ |
|---|---|---|---|---|---|---|
| ១ | -៤១នាក់ (ស្រី៣៥) | -តិចជាង៣០ឆ្នាំ:៣នាក់(ស្រី៣)<br>-ចន្លោះ៣០-៤០ឆ្នាំ: ១៨នាក់(ស្រី១៥)<br>-ចន្លោះ៤០-៥០ឆ្នាំ: ១៧នាក់(ស្រី១៥)<br>-លើសពី៥០ឆ្នាំ:៣នាក់(ស្រី២) | -ទុតិយភូមិ:៩នាក់ (ស្រី៩)<br>-បរិញ្ញាបត្រ:២៤នាក់ (ស្រី២៤)<br>-បរិញ្ញាបត្រជាន់ខ្ពស់ ៨នាក់(ស្រី២) | -នាយក១<br>-នាយករង១<br>-ប្រធានក្រុមបច្ចេកទេស ៣នាក់(ស្រី៣)<br>-គ្រូបង្រៀន ៣៦នាក់(ស្រី៣២) | -តិចជាង៥ឆ្នាំ: ៣នាក់(ស្រី៣)<br>-ចន្លោះ៥-១០ឆ្នាំ:២នាក់(ស្រី២)<br>-លើសពី១០ឆ្នាំ:៣៦នាក់ (ស្រី៣០) | -បឋមសិក្សា: ៣៤នាក់(ស្រី៣០)<br>-បឋមភូមិ:៧នាក់ (ស្រី៥) |

តាមរយៈការបំពេញកម្រងសំណួរបានឱ្យដឹងថា សាលាបឋមសិក្សាទី១មានបុគ្គលិកអប់រំសរុប ៤១នាក់(ស្រី៣៥នាក់)។ បុគ្គលិកទាំងនោះអាយុតិចជាង៣០ឆ្នាំមាន៣នាក់ (ស្រី៣នាក់) អាយុ៣០-៤០ឆ្នាំ១៨នាក់ (ស្រី១៥នាក់) អាយុ៤០-៥០ឆ្នាំ១៧នាក់(ស្រី១៥នាក់)និងលើសពី៥០ឆ្នាំ៣នាក់ (ស្រី២នាក់)។ទាក់ទងកម្រិតវប្បធម៌ទុតិយភូមិ៩នាក់ (ស្រី៩នាក់) បរិញ្ញាបត្រ២៤នាក់ (ស្រី២៤នាក់) និងបរិញ្ញាបត្រជាន់ខ្ពស់៨នាក់ (ស្រី២នាក់)។ សាលារៀនមាននាយក២នាក់ (ស្រី០នាក់) ប្រធានក្រុមបច្ចេកទេស៣នាក់ (ស្រី៣នាក់) និងគ្រូបង្រៀន៣៦នាក់ (ស្រី៣២នាក់)។ នៅក្នុងចំណោមបុគ្គលិកអប់រំឃើញថា គ្រូបង្រៀនមានបទពិសោធន៍តិចជាង៥ឆ្នាំ៣នាក់ (ស្រី៣នាក់) ចន្លោះ៥-១០ឆ្នាំ២នាក់ (ស្រី២នាក់) និងលើសពី១០ឆ្នាំ៣៦នាក់ (ស្រី៣០នាក់)។ គ្រូបង្រៀនមានក្របខណ្ឌជាគ្រូបឋមសិក្សា ៣៤នាក់(ស្រី៣០នាក់) គ្រូបឋមភូមិ៧នាក់ (ស្រី៥នាក់) ។

*ក.១-សាលាបឋមសិក្សាទី១អនុវត្តកម្រិតស្តង់ដា*

| លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ |
|---|---|---|---|---|---|---|---|---|
| ១ | ស្តង់ដាទី១ | ២៥% | ៤ | ស្តង់ដាទី៤ | ១៥% | ៧ | ស្តង់ដាទី៧ | ១៥% |
| ២ | ស្តង់ដាទី២ | ៣៥% | ៥ | ស្តង់ដាទី៥ | ២០% | ៨ | ស្តង់ដាទី៨ | ១៥% |
| ៣ | ស្តង់ដាទី៣ | ៣០% | ៦ | ស្តង់ដាទី៦ | ២០% | ៩ | ស្តង់ដាទី៩ | ២៥% |

***ក.២-បញ្ហាប្រឈម៖*** សាលាបឋមសិក្សាទី១០ មានជួបបញ្ហាប្រឈមមួយចំនួនដូចជា ការដឹកនាំនិងគ្រប់គ្រង សិស្សមករៀនមិនទៀងទាត់ អគារនិងបន្ទប់រៀនតូច បន្ទប់ទឹកតូចចង្អៀត ខ្វះសម្ភារឧបទេសដូចជា មេរៀនវិទ្យាសាស្ត្រនិងសិក្សាសង្គម ឪពុកម្តាយមិនសូវយកចិត្តទុកដាក់ក្នុងការសិក្សារបស់កូនកិច្ចការនៅផ្ទះនិងសាលារៀន សិស្សថ្នាក់ទីមួយពិបាកនិយាយគ្នាមិនងាយបាន (ទាក់ទងនឹងស្តង់ដាទី២អនុវត្តបាន១០% ស្តង់ដាទី៤បាន៨% ស្តង់ដាទី៥បាន១២% ស្តង់ដាទី៦បាន១០% ស្តង់ដាទី៧បាន៨% និងស្តង់ដាទី៨បាន៦%)។

*ក.៣-បញ្ហាប្រឈមសាលាបឋមសិក្សាទី១០ទាក់ទងកម្រិតស្តង់ដា*

-ស្តង់ដាទី២៖ ឪពុកម្តាយមិនសូវយកចិត្តទុកដាក់នៅក្នុងការសិក្សារបស់កូន (គ្រូដាក់កិច្ចការនៅផ្ទះនិងសាលា)។

-ស្តង់ដាទី៤៖ សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ ទស្សនកិច្ចសិក្សា។

-ស្តង់ដាទី៥៖ ការដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀន។

-ស្តង់ដាទី៦៖ ការប្រើប្រាស់ធនធានមនុស្សមិនបានសមស្របតាមនិយាមរបស់ក្រសួងអប់រំ។

-ស្តង់ដាទី៧៖ ខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន ឯកសារអំណានស្តង់ដា។ ក្រៅពីនេះ ខ្វះបន្ទប់ពិសោធន៍ បន្ទប់រោងជាង បន្ទប់សិល្បៈ តូរ្យតន្ត្រី គំនូរចម្លាក់និងសូនរូបជាដើម។

-ស្តង់ដាទី៨៖ ខ្វះអគារសិក្សានិងបន្ទប់រៀន សម្ភារៈបរិក្ខារ អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស។

ដូច្នេះ សាលាបឋមសិក្សាទី១០អនុវត្តកម្រិតស្តង់ដាក្រសួងបានស្តង់ដាទី១ ទី២ ទី៣និងទី៩តិចតួចហើយអនុវត្តមិនបាន១០០% ពីព្រោះស្តង់ដាទី១សិស្សឡើងថ្នាក់មិនសូវបានច្រើនហើយលទ្ធផលតេស្តមធ្យម។ ស្តង់ដាទី២ សាលាខ្វះសៀវភៅសិក្សាគោលសម្ភារឧបទេសនិងសម្ភារបង្រៀន។ ស្តង់ដាទី៣ឪពុកម្តាយមិនសូវយកចិត្តទុកដាក់ការសិក្សារបស់កូន។ ស្តង់ដាទី៩សាលាខ្វះថវិកា។

*ក.៤-ទស្សនៈគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀននិងសហគមន៍*

-គណៈគ្រប់គ្រងសាលារៀន២នាក់ស្មើ១០០%បានឆ្លើយថា ខ្វះអគារសិក្សានិងបន្ទប់រៀន ការគ្រប់គ្រងនិងដឹកនាំមិនទាន់បានល្អ អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស បន្ទប់រោងជាង បន្ទប់តូរ្យតន្ត្រី គំនូរចម្លាក់ និងសូនរូបជាដើម។ មូលហេតុ សាលាមិនមានជំនួយក្នុងការសាងសង់អគារនិងធនធានមនុស្ស។

-គ្រូបង្រៀន១៣នាក់ក្នុងចំណោម១៥នាក់ស្មើ៨៦%បានឆ្លើយថា ខ្វះសៀវភៅគ្រូ សម្ភារឧបទេស និងវិន័យនៃការរៀនចុះថយ។ មូលហេតុក្រសួងមិនបោះពុម្ពសៀវភៅគ្រូ និងសម្ភារឧបទេសគ្រប់គ្រាន់។

-សហគមន៍៥នាក់ស្មើ១០០%បានឆ្លើយថា សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ និងទស្សនកិច្ចសិក្សា។ មូលហេតុការចំណាយជាបន្ទុករបស់ឪពុកម្តាយ។

*ខ.ការធៀបនឹងស្តង់ដាសាលាបឋមសិក្សា*

តាមរយៈការបំពេញកម្រងសំណួរ និងសំណួរសម្ភាសអំពីការគ្រប់គ្រងសាលារៀនទី១០ធៀបនឹងស្តង់ដាសាលាបឋមសិក្សាបានបង្ហាញឱ្យឃើញពីលទ្ធផលដូចតទៅ៖

| លរ | ស្តង់ដាបឋមសិក្សា | តិចតួចណាស់ | តិចតួច | មធ្យម | ច្រើន | ច្រើនណាស់ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ១ | វត្ថុបំណងគោលនយោបាយសាលា | ២ | ០ | ៤ | ១១ | ០ |
| ២ | បំណែងចែកកម្មវិធីនិងការបង្រៀន | ០ | ០ | ៦ | ១១ | ០ |
| ៣ | ការងារមាតាបិតាសិស្សសហគមន៍ | ០ | ០ | ១៣ | ៣ | ១ |
| ៤ | សិស្សនិងសេវាជួយសិស្ស | ០ | ៩ | ៦ | ២ | ០ |
| ៥ | ការដឹកនាំនិងគ្រប់គ្រង | ០ | ០ | ៥ | ១២ | ០ |
| ៦ | ធនធានមនុស្សនិងរចនាសម្ព័ន្ធគ្រប់គ្រង | ០ | ០ | ៦ | ១១ | ០ |
| ៧ | កម្មវិធីសិក្សា សម្ភារបង្រៀន រៀន | ០ | ៧ | ៨ | ២ | ០ |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថានសាលា | ០ | ៦ | ៥ | ៦ | ០ |
| ៩ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ០ | ០ | ៩ | ៨ | ០ |

***គ.ក្រាបស្តង់ដាសាលាបឋមសិក្សាធៀបនឹងសាលាបឋមសិក្សាទី១០***




(រូបភាពទី១០៖ ក្រាបសាលាបឋមសិក្សាទី១០អនុវត្តកម្រិតស្តង់ដាបាន១០%)

## ៤.១១-សាលាបឋមសិក្សាទី១១

នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាទី១១មាន គ្រូសរុប២៥នាក់(ស្រី២២នាក់) សិស្សសរុប១០១១នាក់ (ស្រី៤៨៨នាក់) មានបន្ទប់ចំនួន២៥ បង្រៀន២វេន។ សាលាមានអគារ៦ខ្នង ១៩បន្ទប់និងបន្ទប់រៀន១៥ថ្នាក់ហើយបន្ទប់ប្រើប្រាស់សរុបចំនួន១៩។ សាលារៀនមានគណៈគ្រប់គ្រងសាលា១នាក់ (ស្រី១នាក់) បុគ្គលិកទីចាត់ការ៦នាក់ (ស្រី៥នាក់) បណ្ណារក្ស២នាក់(ស្រី២នាក់) គ្រូបង្រៀនសុទ្ធសាធ២៥នាក់ (ស្រី២២នាក់) ។ ចំណែកគ្រូបង្រៀនថ្នាក់ទី១ដល់ទី៦មានចំនួន ១៧នាក់ (ស្រី១៤នាក់)។

***ក.ព័ត៌មានអំពីបុគ្គលិកអប់រំ***

គណៈគ្រប់គ្រងសាលាព្រមទាំងលោកគ្រូ អ្នកគ្រូក្នុងសាលាបឋមសិក្សាទី១១ បានចូលរួម

ឆ្លើយសំណួរ និងបំពេញកម្រងសំណួរអំពីការអនុវត្តគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ។ ការបំពេញកម្រងសំណួរនេះរួមមាន គណៈគ្រប់គ្រងសាលារៀន១នាក់(ស្រី១នាក់) គ្រូបង្រៀន២៥នាក់ (ស្រី២១នាក់) និងសហគមន៍៨នាក់ (ស្រី៦នាក់)។

លទ្ធផលទទួលបានតាមផ្នែកនីមួយៗមានដូចខាងក្រោម៖

| លរ | ភេទ | អាយុ | កម្រិតវប្បធម៌ | តួនាទី | បទពិសោធន៍ | ក្របខណ្ឌ |
|---|---|---|---|---|---|---|
| ១ | -២៥នាក់ (ស្រី២២) | -តិចជាង៣០ឆ្នាំ:៣ នាក់(ស្រី៣)<br>-ចន្លោះ៣០-៤០ឆ្នាំ: ១១នាក់(ស្រី១១)<br>-ចន្លោះ៤០-៥០ឆ្នាំ: ១១នាក់(ស្រី៨)<br>-លើសពី៥០ឆ្នាំ: នាក់(ស្រី) | -ទុតិយភូមិ២២ នាក់(ស្រី២២)<br>-បរិញ្ញាបត្រ:២ នាក់(ស្រី១)<br>-បរិញ្ញាបត្រ ជាន់ខ្ពស់:១ នាក់(ស្រី១) | -នាយិកា១<br>-នាយករង<br>-ប្រធានក្រុមបច្ចេកទេស ៣នាក់(ស្រី ២)<br>-គ្រូបង្រៀន ២១នាក់(ស្រី ១៩) | -តិចជាង៥ឆ្នាំ:២ នាក់(ស្រី២)<br>-ចន្លោះ៥-១០ឆ្នាំ: ៤នាក់(ស្រី៣)<br>-លើសពី១០ឆ្នាំ: ១៩នាក់(ស្រី១៧) | -បឋមសិក្សា: ២១នាក់(ស្រី១៨)<br>-បឋមភូមិ:៤នាក់ (ស្រី៤) |

តាមរយៈការបំពេញកម្រងសំណួរឱ្យដឹងថា សាលាបឋមសិក្សាទី១១ មានបុគ្គលិកអប់រំសរុប២៥នាក់(ស្រី២២នាក់)។ បុគ្គលិកទាំងនោះអាយុតិចជាង៣០ឆ្នាំមាន៣នាក់ (ស្រី៣នាក់) អាយុ៣០-៤០ឆ្នាំ១១នាក់ (ស្រី១១នាក់) អាយុ៤០-៥០ឆ្នាំ១១នាក់(ស្រី០៨នាក់) និងលើសពី៥០ឆ្នាំ០នាក់ (ស្រី០នាក់)។ទាក់ទងកម្រិតវប្បធម៌ទុតិយភូមិ២២នាក់(ស្រី២២នាក់) បរិញ្ញាបត្រ២នាក់ (ស្រី១នាក់) និងបរិញ្ញាបត្រជាន់ខ្ពស់១នាក់ (ស្រី១នាក់)។ សាលារៀនមាននាយក២នាក់ (ស្រី១នាក់) ប្រធានក្រុមបច្ចេកទេស៣នាក់ (ស្រី២នាក់) និងគ្រូបង្រៀន២១នាក់ (ស្រី១៩នាក់)។ នៅក្នុងចំណោមបុគ្គលិកអប់រំឃើញថា គ្រូបង្រៀនមានបទពិសោធន៍តិចជាង៥ឆ្នាំ២នាក់ (ស្រី២នាក់) ចន្លោះ៥-១០ឆ្នាំ៤នាក់ (ស្រី៣នាក់) និងលើសពី១០ឆ្នាំ១៩នាក់ (ស្រី១៧នាក់)។ គ្រូបង្រៀនមានក្របខណ្ឌជាគ្រូបឋមសិក្សា ២១នាក់ (ស្រី១៨នាក់) គ្រូបឋមភូមិ៤នាក់ (ស្រី៤នាក់) ។

***ក.១-សាលាបឋមសិក្សាទី១១អនុវត្តកម្រិតស្តង់ដា***

| លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ |
|---|---|---|---|---|---|---|---|---|
| ១ | ស្តង់ដាទី១ | ១៤% | ៤ | ស្តង់ដាទី៤ | ១៦% | ៧ | ស្តង់ដាទី៧ | ១២% |
| ២ | ស្តង់ដាទី២ | ១៨% | ៥ | ស្តង់ដាទី៥ | ២០% | ៨ | ស្តង់ដាទី៨ | ១៤% |
| ៣ | ស្តង់ដាទី៣ | ២០% | ៦ | ស្តង់ដាទី៦ | ១៨% | ៩ | ស្តង់ដាទី៩ | ១៦% |

***ក.២-បញ្ហាប្រឈម៖*** នៅក្នុងសាលាបឋមសិក្សាទី១១ មានជួបបញ្ហាប្រឈមមួយចំនួនដូចជាវិធីសាស្ត្របង្រៀនថ្មី (IBL) បទពិសោធន៍ការបង្រៀនថ្នាក់ទី៥ ការកំណត់ម៉ោងបង្រៀនមិនបានត្រឹមត្រូវតាមកម្មវិធីសិក្សា ពិបាកក្នុងការណែនាំនិងគ្រប់គ្រងសិស្ស សិស្សច្រើនពេកក្នុងថ្នាក់ សម្ភារខ្លះពិបាករក វិធី

សាស្រ្តថ្នាក់ទី១និងទី២សិស្សចាប់អត់បាន ការប្រើកម្មវិធីអានសរសេរ គ្រូប្រើប្រាស់សកម្មភាពច្រើន សំឡេងខ្លាំងតែសិស្សពុំសូវអនុវត្តតាមសកម្មភាព ខ្វះសម្ភារបង្រៀន វិធីសាស្រ្តច្រើនពិបាកចាប់យក ខ្វះសម្ភារពិសោធន៍ គ្មានសៀវភៅគ្រូជាជំនួយ ខ្វះសៀវភៅសិក្សាគោល ការដឹកនាំសិស្ស វិធីសាស្រ្តបង្រៀន គោលវិធីសិស្សមជ្ឈមណ្ឌល អគារទ្រុឌទ្រោម ខ្វះសម្ភារបច្ចេកវិទ្យា គ្រប់គ្រងសំរាមមិនបាន (សាលាអត់មានរបង)។ (ទាក់ទងស្តង់ដាទី២អនុវត្តបាន៥% ស្តង់ដាទី៤បាន១៦% ស្តង់ដាទី៦បាន១៨% ស្តង់ដាទី៧បាន១២% និងស្តង់ដាទី៨បាន១៥%)។

*ក.៣-បញ្ហាប្រឈមសាលាបឋមសិក្សាទី១១ទាក់ទងកម្រិតស្តង់ដា*

-ស្តង់ដាទី២៖ ការកំណត់ម៉ោងបង្រៀនមិនបានត្រឹមត្រូវ ការណែនាំនិងគ្រប់គ្រងសិស្សពិបាក ព្រោះក្នុងថ្នាក់សិស្សច្រើន។

-ស្តង់ដាទី៤៖ សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ ទស្សនកិច្ចសិក្សា។

-ស្តង់ដាទី៦៖ ការប្រើប្រាស់ធនធានមនុស្សមិនបានសមស្របតាមនិយាមរបស់ក្រសួងអប់រំ។

-ស្តង់ដាទី៧៖ ខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន ឯកសារអំណានស្តង់ដា។ ក្រៅពីនេះ ខ្វះបន្ទប់ពិសោធន៍ បន្ទប់រោងជាង បន្ទប់សិល្បៈ តូរ្យតន្រ្តី គំនូរចម្លាក់និងសូនរូបជាដើម។

-ស្តង់ដាទី៨៖ ខ្វះអគារសិក្សានិងបន្ទប់រៀន សម្ភារៈបរិក្ខារ អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស។

ដូច្នេះ សាលាបឋមសិក្សាទី១១ អនុវត្តកម្រិតស្តង់ដាក្រសួងបានស្តង់ដាទី១ ទី៣ ទី៥ និងទី៩ តិចតួចហើយអនុវត្តមិនបាន១០០% ពីព្រោះស្តង់ដាទី១លទ្ធផលតេស្តសិស្សនៅមានកម្រិត។ស្តង់ដាទី៣សិស្សមិនសូវបានចូលរួមការងារក្រុម។ ស្តង់ដាទី៥ ការប្រជុំក្រុមបច្ចេកទេសគ្រូចូលរួមមិនគ្រប់គ្នា និងស្តង់ដាទី៩ខ្វះថវិកាក្នុងការអភិវឌ្ឍសាលារៀន។

*ក.៤-ទស្សនៈគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀននិងសហគមន៍*

-គណៈគ្រប់គ្រងសាលារៀន១នាក់ស្មើ១០០%បានឆ្លើយថា អគារទ្រុឌទ្រោម ខ្វះសម្ភារបច្ចេកវិទ្យា បញ្ហាសំរាមនិងគ្មានរបងសាលាអគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស បន្ទប់រោងជាង បន្ទប់តូរ្យតន្រ្តី គំនូរ ចម្លាក់ និងសូនរូបជាដើម។មូលហេតុសាលាមិនមានថវិកាសាងសង់ ធនធានមនុស្សមានកម្រិត

-គ្រូបង្រៀន២០នាក់ក្នុងចំណោម២៥នាក់ស្មើ៨០%បានឆ្លើយថា ខ្វះសៀវភៅគ្រូ សម្ភារឧបទេស សៀវភៅសិក្សាគោល សម្ភារពិសោធន៍ វិធីសាស្រ្តបង្រៀនថ្មី (IBL) និងការគ្រប់គ្រងសិស្សក្នុងថ្នាក់។ មូលហេតុក្រសួងមិនបានបោះពុម្ពសៀវភៅគ្រូនិងសម្ភារឧបទេសគ្រប់គ្រាន់។

-សហគមន៍៦នាក់ក្នុងចំណោម៨នាក់ស្មើ៧៥%បានឆ្លើយថា សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ និងទស្សនកិច្ចសិក្សា។មូលហេតុការចំណាយរបស់សិស្សជាបន្ទុករបស់មាតាបិតាសិស្ស។

***ខ.ការធៀបនឹងស្តង់ដាសាលាបឋមសិក្សា***

តាមរយៈការបំពេញកម្រងសំណួរ និង សំណួរសម្ភាសអំពី ការគ្រប់គ្រងសាលារៀនទី១១ ធៀបនឹងស្តង់ដាសាលាបឋមសិក្សាបានបង្ហាញឱ្យឃើញពីលទ្ធផលដូចតទៅ៖

| លរ | ស្តង់ដាបឋមសិក្សា | តិចតួចណាស់ | តិចតួច | មធ្យម | ច្រើន | ច្រើនណាស់ |
|---|---|---|---|---|---|---|
| ១ | វត្ថុបំណងគោលនយោបាយសាលា | 0 | 0 | ១១ | ១៤ | 0 |
| ២ | បំណែងចែកកម្មវិធីនិងការបង្រៀន | 0 | ១ | ៥ | ១៩ | 0 |
| ៣ | ការងារមាតាបិតាសិស្សសហគមន៍ | 0 | ១ | ២០ | ៤ | 0 |
| ៤ | សិស្សនិងសេវាជួយសិស្ស | 0 | ១៧ | ៨ | 0 | 0 |
| ៥ | ការដឹកនាំនិងគ្រប់គ្រង | 0 | ១ | ៤ | ២០ | 0 |
| ៦ | ធនធានមនុស្សនិងរចនាសម្ព័ន្ធគ្រប់គ្រង | 0 | 0 | ៧ | ១៨ | 0 |
| ៧ | កម្មវិធីសិក្សា សម្ភារបង្រៀន រៀន | 0 | ១១ | ១២ | ២ | 0 |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថានសាលា | 0 | ៦ | ១៥ | ៤ | 0 |
| ៩ | ការគ្រប់គ្រងហិរញ្ញវត្ថុ | 0 | ៤ | ៤ | ១៦ | ១ |

***គ.ក្រាបស្តង់ដាសាលាបឋមសិក្សាធៀបនឹងសាលាបឋមសិក្សាទី១១***




(រូបភាពទី១១៖ ក្រាបសាលាបឋមសិក្សាទី១១អនុវត្តកម្រិតស្តង់ដាបាន២០%)

## ៤.១២-សាលាបឋមសិក្សាទី១២

នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាទី១២មានគ្រូសរុប៣៣នាក់(ស្រី២៩នាក់)

សិស្សសរុប១១២០នាក់ (ស្រី៥១៥នាក់) មានបន្ទប់ចំនួន២២ បង្រៀន២វេន។ សាលាមានអគារ៣ខ្នង ២២បន្ទប់ និងបន្ទប់រៀន២២ថ្នាក់ ហើយបន្ទប់ប្រើប្រាស់សរុបចំនួន២២។ សាលារៀនមានគណៈគ្រប់គ្រងសាលា២នាក់ (ស្រី១នាក់) បុគ្គលិកទីចាត់ការ៣នាក់ (ស្រី១នាក់) បណ្ណារក្ស២នាក់(ស្រី២នាក់) គ្រូបង្រៀនសុទ្ធសាធ២៦នាក់ (ស្រី២៥នាក់)។ ចំណែកគ្រូបង្រៀនថ្នាក់ទី១ដល់ទី៦មានចំនួន ២៦នាក់ (ស្រី២៥នាក់)។

***ក.ព័ត៌មានអំពីបុគ្គលិកអប់រំ***

គណៈគ្រប់គ្រងសាលាព្រមទាំងលោកគ្រូ អ្នកគ្រូ ក្នុងសាលាបឋមសិក្សាទី១២ បានចូលរួមឆ្លើយសំណួរ និងបំពេញកម្រងសំណួរអំពីការអនុវត្តគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ។ ការបំពេញកម្រងសំណួរនេះរួមមាន គណៈគ្រប់គ្រងសាលារៀន២នាក់ (ស្រី១នាក់) គ្រូបង្រៀន១២នាក់ (ស្រី១១នាក់) និងសហគមន៍៨នាក់ (ស្រី៥នាក់)។

លទ្ធផលទទួលបានតាមផ្នែកនីមួយៗមានដូចខាងក្រោមៈ

| លរ | ភេទ | អាយុ | កម្រិតវប្បធម៌ | តួនាទី | បទពិសោធន៍ | ក្របខណ្ឌ |
|---|---|---|---|---|---|---|
| ១ | -១៤នាក់ (ស្រី១២) | -តិចជាង៣០ឆ្នាំ:១នាក់(ស្រី១) -ចន្លោះ៣០-៤០ឆ្នាំ: ៣នាក់(ស្រី៣) -ចន្លោះ៤០-៥០ឆ្នាំ: ១០នាក់(ស្រី៨) -លើសពី៥០ឆ្នាំ: នាក់(ស្រី) | -ទុតិយភូមិ១២នាក់(ស្រី១០) -បរិញ្ញាបត្រ:១នាក់(ស្រី១) -បរិញ្ញាបត្រជាន់ខ្ពស់១នាក់(ស្រី១) | -នាយិកា១ -នាយករង១ -ប្រធានក្រុមបច្ចេកទេស នាក់(ស្រី) -គ្រូបង្រៀន១២នាក់(ស្រី១១) | -តិចជាង៥ឆ្នាំ:២នាក់(ស្រី២) -ចន្លោះ៥-១០ឆ្នាំ:២នាក់(ស្រី២) -លើសពី១០ឆ្នាំ: ១០នាក់(ស្រី៨) | -បឋមសិក្សា: ១៤នាក់ (ស្រី១២) -បឋមភូមិ:០នាក់(ស្រី) |

តាមរយៈការបំពេញកម្រងសំណួរឱ្យដឹងថា សាលាបឋមសិក្សាទី១២ មានបុគ្គលិកអប់រំសរុប ១៤នាក់(ស្រី១២នាក់)។ បុគ្គលិកទាំងនោះអាយុតិចជាង៣០ឆ្នាំមាន១នាក់ (ស្រី១នាក់) អាយុ៣០-៤០ឆ្នាំ៣នាក់ (ស្រី៣នាក់) អាយុ៤០-៥០ឆ្នាំ១០នាក់ (ស្រី៨នាក់) និងលើសពី៥០ឆ្នាំ០នាក់ (ស្រី០នាក់)។ទាក់ទងកម្រិតវប្បធម៌ទុតិយភូមិ១២នាក់(ស្រី១០នាក់) បរិញ្ញាបត្រ១នាក់ (ស្រី១នាក់) និងបរិញ្ញាបត្រជាន់ខ្ពស់១នាក់ (ស្រី១នាក់)។ សាលារៀនមាននាយក២នាក់ (ស្រី១នាក់) ប្រធានក្រុមបច្ចេកទេស០នាក់ (ស្រី០នាក់) និងគ្រូបង្រៀន១២នាក់ (ស្រី១១នាក់)។ នៅក្នុងចំណោមបុគ្គលិកអប់រំឃើញថា គ្រូបង្រៀនមានបទពិសោធន៍តិចជាង៥ឆ្នាំ២នាក់ (ស្រី២នាក់) ចន្លោះ៥-១០ឆ្នាំ២នាក់ (ស្រី២នាក់) និងលើសពី១០ឆ្នាំ១០នាក់ (ស្រី០៨នាក់)។ គ្រូបង្រៀនមានក្របខណ្ឌជាគ្រូបឋមសិក្សា១៤នាក់ (ស្រី១២នាក់) គ្រូបឋមភូមិ០នាក់ (ស្រី០នាក់) ។

*ក.១-សាលាបឋមសិក្សាទី១២អនុវត្តកម្រិតស្តង់ដា*

| លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ |
|---|---|---|---|---|---|---|---|---|
| ១ | ស្តង់ដាទី១ | ៧% | ៤ | ស្តង់ដាទី៤ | ៨% | ៧ | ស្តង់ដាទី៧ | ៥% |
| ២ | ស្តង់ដាទី២ | ៧% | ៥ | ស្តង់ដាទី៥ | ៥% | ៨ | ស្តង់ដាទី៨ | ៦% |
| ៣ | ស្តង់ដាទី៣ | ៧% | ៦ | ស្តង់ដាទី៦ | ៧% | ៩ | ស្តង់ដាទី៩ | ៥% |

*ក.២-បញ្ហាប្រឈម៖* នៅក្នុងសាលាបឋមសិក្សាទី១២មានជួបបញ្ហាប្រឈមមួយចំនួនដូចជា ការគ្រប់គ្រងរដ្ឋបាលសាលារៀន(ផលវិបាកខ្លះៗលើតារាងស្ថិតិអគារសិក្សាប្រេះស្រាំ១ខ្នង២ជាន់) កំពុងពិភាក្សាជាមួយក្រសួងនិងមន្ទីរសាងសង់កែលម្អអគារ។ វិធីសាស្ត្របង្រៀនថ្មី សិស្សមួយចំនួនតូចពុំចេះស្រះនិងព្យញ្ជនៈ សិស្សពុំសូវយកចិត្តទុកដាក់រៀននៅផ្ទះបន្ថែម និងអាណាព្យាបាលសិស្សមួយចំនួនពុំសូវជួយជំរុញកូនឱ្យរៀនបន្ថែមនៅផ្ទះ(ទាក់ទងនឹងស្តង់ដាទី៣អនុវត្តបាន៧% ស្តង់ដាទី៤បាន៨% ស្តង់ដាទី៥បាន៥% ស្តង់ដាទី៦បាន៧% ស្តង់ដាទី៧បាន៥% និងស្តង់ដាទី៨បាន៦%)។

*ក.៣-បញ្ហាប្រឈមសាលាបឋមសិក្សាទី១២ទាក់ទងកម្រិតស្តង់ដា*

-ស្តង់ដាទី៣៖ សិស្សមួយចំនួនតូចមិនចេះស្រៈ ព្យញ្ជនៈ ហើយមិនសូវយកចិត្តទុកដាក់រៀននៅផ្ទះ។

-ស្តង់ដាទី៤៖ សិស្សមិនទទួលបានអាហារូបករណ៏ អាហារពេលព្រឹក/ថ្ងៃត្រង់ ទស្សនកិច្ចសិក្សា។

-ស្តង់ដាទី៥៖ ការដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀនគឺអគារសិក្សាប្រេះស្រាំមួយខ្នង២ជាន់។

-ស្តង់ដាទី៦៖ ការប្រើប្រាស់ធនធានមនុស្សមិនបានសមស្របតាមនិយាមរបស់ក្រសួងអប់រំ។

-ស្តង់ដាទី៧៖ ខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន ឯកសារអំណានស្តង់ដា។ ក្រៅពីនេះ ខ្វះបន្ទប់ពិសោធន៍ បន្ទប់រោងជាង បន្ទប់សិល្បៈ តូរ្យតន្ត្រី គំនូរចម្លាក់និងសូនរូបជាដើម។

-ស្តង់ដាទី៨៖ ខ្វះអគារសិក្សានិងបន្ទប់រៀន សម្ភារៈបរិក្ខារ អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស។

ដូច្នេះ សាលាបឋមសិក្សាទី១២អនុវត្តកម្រិតស្តង់ដាក្រសួងបានស្តង់ដាទី១ ទី២និងទី៩តិចតួចហើយអនុវត្តមិនបាន១០០% ពីព្រោះស្តង់ដាទី១លទ្ធផលតេស្តបានមធ្យមហើយការប្រមូលសិស្សចូលរៀនមិនបាន១០០%។ ស្តង់ដាទី២ សាលាខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេស និងសម្ភារបង្រៀន។ ស្តង់ដាទី៩ខ្វះថវិកាសម្រាប់ជួសជុលអគារឬដំណើរការសាលារៀន។

*ក.៤-ទស្សនៈគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀននិងសហគមន៍*

-គណៈគ្រប់គ្រងសាលារៀន២នាក់ស្មើ១០០%បានឆ្លើយថា ខ្វះអគារសិក្សានិងបន្ទប់រៀន បន្ទប់ពិសោធន៍ អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស បន្ទប់រោងជាង បន្ទប់តូរ្យតន្ត្រី គំនូរចម្លាក់ និងសូនរូបជាដើម។ មូលហេតុសាលាមិនមានថវិកាសម្រាប់សាងសង់និងធនធានមនុស្ស។

-គ្រូបង្រៀន១២នាក់ស្មើ១០០%បានឆ្លើយថា ខ្វះសៀវភៅគ្រូ វិធីសាស្ត្របង្រៀនថ្មី សិស្សខ្លះមិនយកចិត្តទុកដាក់រៀននិងខ្វះការជំរុញពីឪពុកម្តាយថែមទៀត។ មូលហេតុក្រសួងមិនបានបោះពុម្ពសៀវភៅ និងសម្ភារឧបទេសគ្រប់គ្រាន់។

-សហគមន៍៨នាក់ស្មើ១០០%បានឆ្លើយថា សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ និងទស្សនកិច្ចសិក្សា។ មូលហេតុការចំណាយជាបន្ទុករបស់ឪពុកម្តាយ។

*ខ.ការធៀបនឹងស្តង់ដាសាលាបឋមសិក្សា*

តាមរយៈការបំពេញកម្រងសំណួរ និងសំណួរសម្ភាសអំពីការគ្រប់គ្រងសាលារៀនទី១២នឹងស្តង់ដាសាលាបឋមសិក្សាបានបង្ហាញឱ្យឃើញពីលទ្ធផលដូចតទៅ៖

| លរ | ស្តង់ដាបឋមសិក្សា | តិចតួចណាស់ | តិចតួច | មធ្យម | ច្រើន | ច្រើនណាស់ |
|---|---|---|---|---|---|---|
| ១ | វត្ថុបំណងគោលនយោបាយសាលា | ១ | ០ | ៧ | ៦ | ០ |
| ២ | បំណែងចែកកម្មវិធីនិងការបង្រៀន | ១ | ០ | ៧ | ៦ | ០ |
| ៣ | ការងារមាតាបិតាសិស្សសហគមន៍ | ១ | ០ | ៧ | ៦ | ០ |
| ៤ | សិស្សនិងសេវាជួយសិស្ស | ២ | ៨ | ៤ | ០ | ០ |
| ៥ | ការដឹកនាំនិងគ្រប់គ្រង | ២ | ៥ | ៣ | ៤ | ០ |
| ៦ | ធនធានមនុស្សនិងរចនាសម្ព័ន្ធគ្រប់គ្រង | ៣ | ៣ | ៧ | ១ | ០ |
| ៧ | កម្មវិធីសិក្សា សម្ភារបង្រៀន រៀន | ១ | ៥ | ៥ | ៣ | ០ |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថានសាលា | ១ | ៤ | ៦ | ៣ | ០ |
| ៩ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ៤ | ៤ | ៤ | ២ | ០ |

*គ.ក្រាបស្តង់ដាសាលាបឋមសិក្សាធៀបនឹងសាលាបឋមសិក្សាទី១២*




(រូបភាពទី១២៖ ក្រាបសាលាបឋមសិក្សាទី១២អនុវត្តកម្រិតស្តង់ដាបាន៥%)

## ៤.១៣-សាលាបឋមសិក្សាទី១៣

នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាទី១៣មានគ្រូសរុប៦១នាក់ (ស្រី៥១នាក់) សិស្សសរុប២៣០០នាក់ (ស្រី៣១០៨៤នាក់) មានបន្ទប់ចំនួន៥៤ បង្រៀន២វេន។ សាលាមាន

អគារ៤ខ្នង ៤២បន្ទប់ និងបន្ទប់រៀន៣២ថ្នាក់ ហើយបន្ទប់ប្រើប្រាស់សរុបចំនួន៤២។ សាលារៀនមានគណៈគ្រប់គ្រងសាលា២នាក់ បុគ្គលិកទីចាត់ការ៣នាក់ (ស្រី១នាក់) បណ្ណារក្ស២នាក់ គ្រូបង្រៀនសុទ្ធសាធ៥៨នាក់ (ស្រី៤០នាក់)។ ចំណែកគ្រូបង្រៀនថ្នាក់ទី១ដល់ទី៦មានចំនួន៤០នាក់(ស្រី២០នាក់)។

***ក.ព័ត៌មានអំពីបុគ្គលិកអប់រំ***

គណៈគ្រប់គ្រងសាលា ព្រមទាំងលោកគ្រូ អ្នកគ្រូក្នុងសាលាបឋមសិក្សាទី១៣ បានចូលរួមឆ្លើយសំណួរ និងបំពេញកម្រងសំណួរ អំពីការអនុវត្តគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ។ ការបំពេញកម្រងសំណួរនេះរួមមាន គណៈគ្រប់គ្រងសាលារៀន២នាក់ គ្រូបង្រៀន២៩នាក់ (ស្រី២៥នាក់) និងសហគមន៍៨នាក់ (ស្រី៨នាក់)។

លទ្ធផលទទួលបានតាមផ្នែកនីមួយៗមានដូចខាងក្រោមៈ

| លរ | ភេទ | អាយុ | កម្រិតវប្បធម៌ | តួនាទី | បទពិសោធន៍ | ក្របខណ្ឌ |
|---|---|---|---|---|---|---|
| ១ | -៣១នាក់ (ស្រី២៥) | -តិចជាង៣០ឆ្នាំៈ១នាក់(ស្រី១)<br>-ចន្លោះ៣០-៤០ឆ្នាំៈ ១៩នាក់(ស្រី១៧)<br>-ចន្លោះ៤០-៥០ឆ្នាំៈ ១០នាក់(ស្រី៧)<br>-លើសពី៥០ឆ្នាំៈ១នាក់(ស្រី០) | -ទុតិយភូមិ២០នាក់ (ស្រី១៧)<br>-បរិញ្ញាបត្រៈ៨នាក់ (ស្រី៦)<br>-បរិញ្ញាបត្រជាន់ខ្ពស់ ៣នាក់(ស្រី២) | -នាយក១<br>-នាយករង១<br>-ប្រធានក្រុមបច្ចេកទេស ៣នាក់(ស្រី២)<br>-គ្រូបង្រៀន ២៦នាក់(ស្រី២៣) | -តិចជាង៥ឆ្នាំៈ១នាក់(ស្រី១)<br>-ចន្លោះ៥-១០ឆ្នាំៈ៤នាក់(ស្រី៤)<br>-លើសពី១០ឆ្នាំៈ ២៦នាក់(ស្រី២០) | -បឋមសិក្សាៈ ៣១នាក់(ស្រី២៥)<br>-បឋមភូមិៈនាក់ (ស្រី០) |

តាមរយៈការបំពេញកម្រងសំណួរឱ្យដឹងថា សាលាបឋមសិក្សាទី១៣ មានបុគ្គលិកអប់រំសរុប៣១នាក់(ស្រី២៥នាក់)។ បុគ្គលិកទាំងនោះអាយុតិចជាង៣០ឆ្នាំមាន១នាក់ (ស្រី១នាក់) អាយុ៣០-៤០ឆ្នាំ១៩នាក់ (ស្រី១៧នាក់) អាយុ៤០-៥០ឆ្នាំ១០នាក់(ស្រី៧នាក់) និងលើសពី៥០ឆ្នាំ១នាក់ (ស្រី០នាក់) ។ទាក់ទងកម្រិតវប្បធម៌ទុតិយភូមិ២០នាក់(ស្រី១៧នាក់) បរិញ្ញាបត្រ៨នាក់ (ស្រី៦នាក់) និងបរិញ្ញាបត្រជាន់ខ្ពស់៣នាក់ (ស្រី២នាក់)។ សាលារៀនមាននាយក២នាក់ (ស្រី០នាក់) ប្រធានក្រុមបច្ចេកទេស៣នាក់ (ស្រី២នាក់) និងគ្រូបង្រៀន២៦នាក់ (ស្រី២៣នាក់)។ នៅក្នុងចំណោមបុគ្គលិកអប់រំឃើញថា គ្រូបង្រៀនមានបទពិសោធន៍តិចជាង៥ឆ្នាំ១នាក់ (ស្រី១នាក់) ចន្លោះ៥-១០ឆ្នាំ៤នាក់ (ស្រី៤នាក់) និងលើសពី១០ឆ្នាំ២៦នាក់ (ស្រី២០នាក់)។ គ្រូបង្រៀនមានក្របខណ្ឌជាគ្រូបឋមសិក្សា៣១នាក់ (ស្រី២៥នាក់) គ្រូបឋមភូមិ០នាក់ (ស្រី០នាក់) ។

***ក.១-សាលាបឋមសិក្សាទី១៣អនុវត្តកម្រិតស្តង់ដា***

| លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ |
|---|---|---|---|---|---|---|---|---|

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១ | ស្តង់ដាទី១ | ២០% | ៤ | ស្តង់ដាទី៤ | ១០% | ៧ | ស្តង់ដាទី៧ | ២០% |
| ២ | ស្តង់ដាទី២ | ២៥% | ៥ | ស្តង់ដាទី៥ | ២៥% | ៨ | ស្តង់ដាទី៨ | ១៥% |
| ៣ | ស្តង់ដាទី៣ | ២៥% | ៦ | ស្តង់ដាទី៦ | ២៥% | ៩ | ស្តង់ដាទី៩ | ២០% |

*ក.២-បញ្ហាប្រឈម៖* នៅក្នុងសាលាបឋមសិក្សាទី១៣មានជួបបញ្ហាប្រឈមមួយចំនួនដូចជាអាណាព្យាបាលសិស្សមួយចំនួនតូចមិនសូវយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន សិស្សចំណាកស្រុកមានការផ្លាស់ប្តូរច្រើន អាជ្ញាធរមិនសូវចូលរួមជាមួយនិងសាលា សិស្សពុំសូវចេះថែរក្សាសៀវភៅសិក្សាគោល បង្គន់អនាម័យនៅមានកម្រិត(ទាក់ទងនឹងស្តង់ដាទី១អនុវត្តបាន២០% ស្តង់ដាទី៣បាន២៥% ស្តង់ដាទី៤បាន១០% ស្តង់ដាទី៦បាន២៥% ស្តង់ដាទី៧បាន២០%និងស្តង់ដាទី៨បាន១៥%)។

*ក.៣-បញ្ហាប្រឈមសាលាបឋមសិក្សាទី១៣ទាក់ទងកម្រិតស្តង់ដា*

-ស្តង់ដាទី១៖ សិស្សធ្វើចំណាកស្រុកនាំឱ្យមានការបោះបង់ការសិក្សាច្រើន។

-ស្តង់ដាទី៣៖ អាណាព្យាបាលមួយចំនួនតូចមិនសូវយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន និងអាជ្ញាធរមិនបានចូលរួមជាមួយសហគមន៍។

-ស្តង់ដាទី៤៖ សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ ទស្សនកិច្ចសិក្សា។

-ស្តង់ដាទី៦៖ ការប្រើប្រាស់ធនធានមនុស្សមិនបានសមស្របតាមនិយាមរបស់ក្រសួងអប់រំ។

-ស្តង់ដាទី៧៖ ខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន ឯកសារអំណានស្តង់ដា។ ក្រៅពីនេះ ខ្វះបន្ទប់ពិសោធន៍ បន្ទប់រោងជាង បន្ទប់សិល្បៈ តូរ្យតន្ត្រី គំនូរចម្លាក់និងសូនរូបជាដើម។

-ស្តង់ដាទី៨៖ សម្ភារៈបរិក្ខារ អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស។

ដូច្នេះ សាលាបឋមសិក្សាទី១៣អនុវត្តកម្រិតស្តង់ដាក្រសួងបានស្តង់ដាទី២ ទី៥និងទី៩។

*ក.៤-ទស្សនៈគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀននិងសហគមន៍*

-គណៈគ្រប់គ្រងសាលារៀន២នាក់ស្មើ១០០%បានឆ្លើយថា អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស បន្ទប់រោងជាងបន្ទប់តូរ្យតន្ត្រីគំនូរចម្លាក់និងសូនរូបជាដើម។មូលហេតុសាលាខ្វះថវិកានិងធនធានមនុស្ស។

-គ្រូបង្រៀន២៥នាក់ក្នុងចំណោម២៩នាក់ស្មើ៨៦%បានឆ្លើយថា ខ្វះសៀវភៅគ្រូ សៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន។ មូលហតុ ក្រសួងមិនបានបោះពុម្ពសៀវភៅគ្រូនិងសម្ភារឧបទេស។

-សហគមន៍៦នាក់ក្នុងចំណោម៨នាក់ស្មើ៧៥%បានឆ្លើយថា សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ និងទស្សនកិច្ចសិក្សា។ មូលហេតុការចំណាយជាបន្ទុករបស់ឪពុកម្តាយ។

*ខ.ការធៀបនឹងស្តង់ដាសាលាបឋមសិក្សា*

តាមរយៈការបំពេញកម្រងសំណួរ និងសំណួរសម្ភាសអំពី ការគ្រប់គ្រងសាលារៀនទី១៣នឹងស្តង់ដាសាលាបឋមសិក្សាបានបង្ហាញឱ្យឃើញពីលទ្ធផលដូចតទៅៈ

| លរ | ស្តង់ដាបឋមសិក្សា | តិចតួចណាស់ | តិចតួច | មធ្យម | ច្រើន | ច្រើនណាស់ |
|---|---|---|---|---|---|---|
| ១ | វត្ថុបំណងគោលនយោបាយសាលា | ០ | ១ | ១៩ | ១១ | ០ |
| ២ | បំណែងចែកកម្មវិធីនិងការបង្រៀន | ០ | ០ | ៦ | ២៥ | ០ |
| ៣ | ការងារមាតាបិតាសិស្សសហគមន៍ | ០ | ០ | ២៦ | ៥ | ០ |
| ៤ | សិស្សនិងសេវាជួយសិស្ស | ០ | ៩ | ១០ | ១២ | ០ |
| ៥ | ការដឹកនាំនិងគ្រប់គ្រង | ០ | ០ | ៣ | ២៦ | ២ |
| ៦ | ធនធានមនុស្សនិងរចនាសម្ព័ន្ធគ្រប់គ្រង | ០ | ០ | ៤ | ២៦ | ១ |
| ៧ | កម្មវិធីសិក្សា សម្ភារបង្រៀន រៀន | ០ | ៥ | ២១ | ៥ | ០ |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថានសាលា | ០ | ០ | ១៥ | ១៥ | ១ |
| ៩ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ០ | ០ | ២០ | ១០ | ១ |

*គ.ក្រាបស្តង់ដាសាលាបឋមសិក្សាធៀបនឹងសាលាបឋមសិក្សាទី១៣*




((រូបភាពទី១៣ៈ ក្រាបសាលាបឋមសិក្សាទី១៣អនុវត្តកម្រិតស្តង់ដាបាន២៥%)

# ៤.១៤-សាលាបឋមសិក្សាទី១៤

នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាទី១៤មានគ្រូសរុប៣៥នាក់ (ស្រី២៦នាក់) សិស្សសរុប៨៩៦នាក់ (ស្រី៣៩៨នាក់) មានបន្ទប់ចំនួន២៤ បង្រៀន២វេន។ សាលាមានអគារ៣ខ្នង ១២បន្ទប់និងបន្ទប់រៀន៨ថ្នាក់ ហើយបន្ទប់ប្រើប្រាស់សរុបចំនួន១២។ សាលារៀនមានគណៈគ្រប់គ្រងសាលា២នាក់ បុគ្គលិកទីចាត់ការ២នាក់ (ស្រី២នាក់) បណ្ណារក្ស២នាក់ (ស្រី២នាក់) គ្រូបង្រៀនសុទ្ធ

សាធ២៤នាក់ (ស្រី២១នាក់) និងបុគ្គលិកផ្សេងៗ៥នាក់(ស្រី១នាក់)។ ចំណែកគ្រូបង្រៀនថ្នាក់ទី១ដល់ទី៦មានចំនួន២៤នាក់ (ស្រី២០នាក់)។

*ក.ព័ត៌មានអំពីបុគ្គលិកអប់រំ*

គណៈគ្រប់គ្រងសាលាព្រមទាំងលោកគ្រូ អ្នកគ្រូ ក្នុងសាលាបឋមសិក្សាទី១៤ បានចូលរួមរួមឆ្លើយសំណួរ និង បំពេញកម្រងសំណួរអំពី ការអនុវត្តគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ។ ការបំពេញកម្រងសំណួរនេះរួមមាន គណៈគ្រប់គ្រងសាលារៀន២នាក់ គ្រូបង្រៀន១៩នាក់ (ស្រី១៦នាក់) និងសហគមន៍៦នាក់ (ស្រី៥នាក់)។

លទ្ធផលទទួលបានតាមផ្នែកនីមួយៗមានដូចខាងក្រោម៖

| លរ | ភេទ | អាយុ | កម្រិតវប្បធម៌ | តួនាទី | បទពិសោធន៍ | ក្របខណ្ឌ |
|---|---|---|---|---|---|---|
| ១ | -២១នាក់ (ស្រី១៦) | -តិចជាង៣០ឆ្នាំ: នាក់(ស្រី)<br>-ចន្លោះ៣០-៤០ឆ្នាំ: ៤នាក់(ស្រី២)<br>-ចន្លោះ៤០-៥០ឆ្នាំ:៨ នាក់(ស្រី៦)<br>-លើសពី៥០ឆ្នាំ:៩ នាក់(ស្រី៨) | -ទុតិយភូមិ:១៨ នាក់(ស្រី១៣)<br>-បរិញ្ញាបត្រ:៣ នាក់(ស្រី៣)<br>-បរិញ្ញាបត្រ ជាន់ខ្ពស់ នាក់ (ស្រី) | -នាយក១<br>-នាយករង១<br>-ប្រធានក្រុមបច្ចេកទេស ២នាក់(ស្រី២)<br>-គ្រូបង្រៀន ១៧នាក់(ស្រី ១៤) | -តិចជាង៥ ឆ្នាំ:៣នាក់ (ស្រី៣)<br>-ចន្លោះ៥-១០ ឆ្នាំ:២នាក់ (ស្រី២)<br>-លើសពី១០ ឆ្នាំ:១៧នាក់ (ស្រី១៣) | -បឋមសិក្សា:១៧នាក់ (ស្រី១៤)<br>-បឋមភូមិ:៤នាក់(ស្រី ៤) |

តាមរយៈការបំពេញកម្រងសំណួរឱ្យដឹងថាសាលាបឋមសិក្សាទី១៤ មានបុគ្គលិកអប់រំសរុប ២១នាក់(ស្រី១៦នាក់)។ បុគ្គលិកទាំងនោះអាយុតិចជាង៣០ឆ្នាំមាន០នាក់ (ស្រី០នាក់) អាយុ៣០-៤០ឆ្នាំ៤នាក់ (ស្រី២នាក់) អាយុ៤០-៥០ឆ្នាំ៨នាក់ (ស្រី៦នាក់) និងលើសពី៥០ឆ្នាំ៩នាក់ (ស្រី៨នាក់)។ទាក់ទងកម្រិតវប្បធម៌ទុតិយភូមិ១៨នាក់(ស្រី១៣នាក់) បរិញ្ញាបត្រ៣នាក់(ស្រី៣នាក់) និងបរិញ្ញាបត្រជាន់ខ្ពស់០នាក់ (ស្រី០នាក់)។ សាលារៀនមាននាយក២នាក់ (ស្រី០នាក់) ប្រធានក្រុមបច្ចេកទេស២នាក់ (ស្រី២នាក់) និងគ្រូបង្រៀន១៧នាក់ (ស្រី១៤នាក់)។ នៅក្នុងចំណោមបុគ្គលិកអប់រំឃើញថា គ្រូបង្រៀនមានបទពិសោធន៍តិចជាង៥ឆ្នាំ៣នាក់ (ស្រី៣នាក់) ចន្លោះ៥-១០ឆ្នាំ២នាក់ (ស្រី២នាក់) និងលើសពី១០ឆ្នាំ១៧នាក់ (ស្រី១៣នាក់)។ គ្រូបង្រៀនមានក្របខណ្ឌជាគ្រូបឋមសិក្សា ១៧នាក់ (ស្រី១៤នាក់) គ្រូបឋមភូមិ៤នាក់ (ស្រី៤នាក់) ។

*ក.១-សាលាបឋមសិក្សាទី១៤អនុវត្តកម្រិតស្តង់ដា*

| លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ | លរ | កម្រិតស្តង់ដា | ភាគរយ |
|---|---|---|---|---|---|---|---|---|
| ១ | ស្តង់ដាទី១ | ១៦% | ៤ | ស្តង់ដាទី៤ | ១២% | ៧ | ស្តង់ដាទី៧ | ១២% |
| ២ | ស្តង់ដាទី២ | ១២% | ៥ | ស្តង់ដាទី៥ | ១៤% | ៨ | ស្តង់ដាទី៨ | ១៤% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | ស្តង់ដាទី៣ | ១៤% | ៦ | ស្តង់ដាទី៦ | ៨% | ៩ | ស្តង់ដាទី៩ | ៨% |

*ក.២-បញ្ហាប្រឈម៖* នៅក្នុងសាលាបឋមសិក្សាទី១៨មានជួបបញ្ហាប្រឈមមួយចំនួនដូចជា សម្ភារបង្រៀន សម្ភារឧបទេស ការគ្រប់គ្រងសិស្ស វិធីសាស្រ្តបង្រៀន សិស្សធ្វើបាត់សៀវភៅសិក្សាគោល ឬរហែក(ទាក់ទងនឹងស្តង់ដាទី៤អនុវត្តបាន១២% ស្តង់ដាទី៦បាន៨% ស្តង់ដាទី៧បាន១២% ស្តង់ដាទី៨បាន១៤%)។

*ក.៣-បញ្ហាប្រឈមសាលាបឋមសិក្សាទី១៨ទាក់ទងកម្រិតស្តង់ដា*

-ស្តង់ដាទី៤៖ សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ ទស្សនកិច្ចសិក្សា។

-ស្តង់ដាទី៦៖ ការប្រើប្រាស់ធនធានមនុស្សមិនបានសមស្របតាមនិយាមរបស់ក្រសួងអប់រំ។

-ស្តង់ដាទី៧៖ ខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន ឯកសារអំណានស្តង់ដា។ ក្រៅពីនេះ ខ្វះបន្ទប់ពិសោធន៍ បន្ទប់រោងជាង បន្ទប់សិល្បៈ តូរ្យតន្ត្រី គំនូរចម្លាក់និងសូនរូបជាដើម។

-ស្តង់ដាទី៨៖ សម្ភារៈបរិក្ខារ អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស។

ដូច្នេះ សាលាបឋមសិក្សាទី១៨អនុវត្តកម្រិតស្តង់ដាក្រសួងបានស្តង់ដាទី១ ទី២ ទី៣ ទី៥និង ទី៩តិចតួចហើយអនុវត្តមិនបាន១០០% ពីព្រោះស្តង់ដាទី១ការប្រមូលសិស្សចូលរៀនមិនបាន១០០% ស្តង់ដាទី២ សាលាខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន។ ស្តង់ដាទី៣ខ្វះការចូលរួមពីសហគមន៍ និងមាតាបិតាសិស្ស។ស្តង់ដាទី៥ការប្រជុំក្រុមបច្ចេកទេសគ្រូចូលរួមមិនបានគ្រប់គ្នា។ ស្តង់ដាទី៩ខ្វះថវិកាក្នុងការកែលម្អសាលារៀន។

*ក.៤-ទស្សនៈគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀននិងសហគមន៍*

-គណៈគ្រប់គ្រងសាលារៀន២នាក់ស្មើ១០០%បានឆ្លើយថា អគារស្នាក់នៅសម្រាប់គ្រូនិងសិស្ស បន្ទប់រោងជាង បន្ទប់តូរ្យតន្ត្រី គំនូរចម្លាក់ និងសូនរូបជាដើម។ មូលហេតុសាលាខ្វះថវិកាសម្រាប់សាងសង់និងធនធានមនុស្ស។

-គ្រូបង្រៀន១៥នាក់ក្នុងចំណោម១៩នាក់ស្មើ៧៨%បានឆ្លើយថា ខ្វះសៀវភៅគ្រូ សៀវភៅសិក្សាគោល សម្ភារឧបទេស សម្ភារបង្រៀន។មូលហេតុក្រសួងមិនបានបោះពុម្ពសៀវភៅគ្រូនិងសម្ភារឧបទេសគ្រប់គ្រាន់។

-សហគមន៍៤នាក់ក្នុងចំណោម៦នាក់ស្មើ៦៦%បានឆ្លើយថា សិស្សមិនទទួលបានអាហារូបករណ៍ អាហារពេលព្រឹក/ថ្ងៃត្រង់ និងទស្សនកិច្ចសិក្សា។ មូលហេតុការចំណាយការសិក្សារបស់កូនជាបន្ទុកឪពុកម្តាយ។

*ខ.ការធៀបនឹងស្តង់ដាសាលាបឋមសិក្សា*

តាមរយៈការបំពេញកម្រងសំណួរ និងសំណួរសម្ភាសអំពីការគ្រប់គ្រងសាលារៀនទី១៤ធៀបនឹងស្តង់ដាសាលាបឋមសិក្សាបានបង្ហាញឱ្យឃើញពីលទ្ធផលដូចតទៅ៖

| លរ | ស្តង់ដាបឋមសិក្សា | តិចតួចណាស់ | តិចតួច | មធ្យម | ច្រើន | ច្រើនណាស់ |
|---|---|---|---|---|---|---|
| ១ | វត្ថុបំណងគោលនយោបាយសាលា | ០ | ១ | ៣ | ១៧ | ០ |
| ២ | បំណែងចែកកម្មវិធីនិងការបង្រៀន | ០ | ០ | ៩ | ១២ | ០ |
| ៣ | ការងារមាតាបិតាសិស្សសហគមន៍ | ០ | ០ | ១៤ | ៧ | ០ |
| ៤ | សិស្សនិងសេវាជួយសិស្ស | ០ | ៣ | ១២ | ៦ | ០ |
| ៥ | ការដឹកនាំនិងគ្រប់គ្រង | ០ | ៣ | ៤ | ១៤ | ០ |
| ៦ | ធនធានមនុស្សនិងរចនាសម្ព័ន្ធ គ្រប់គ្រង | ៥ | ០ | ៩ | ៧ | ០ |
| ៧ | កម្មវិធីសិក្សា សម្ភារបង្រៀន រៀន | ០ | ៣ | ១៣ | ៥ | ០ |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថានសាលា | ៣ | ០ | ១៤ | ៤ | ០ |
| ៩ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ៣ | ០ | ៧ | ៨ | ៣ |

*គ.ក្រាបស្តង់ដាសាលាបឋមសិក្សាធៀបនឹងសាលាបឋមសិក្សាទី១៤*




(រូបភាពទី១៤៖ ក្រាបសាលាបឋមសិក្សាទី១៤អនុវត្តកម្រិតស្តង់ដាបាន១៥%)

## ៤.១៥-សាលាបឋមសិក្សាទាំង១៤ក្នុងក្រុងសៀមរាប

នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាទាំង១៤ក្នុងក្រុងខេត្តសៀមរាបមានគ្រូសរុប៦០២នាក់(ស្រី៤៧៤នាក់) សិស្សសរុប២២៩៨នាក់ (ស្រី១០៨៤៦នាក់) មានបន្ទប់ចំនួន២៩២ និងបង្រៀន២វេន។ សាលាមានអគារ៧៧ខ្នង ៣៤៨បន្ទប់ និងបន្ទប់រៀន២៩២ថ្នាក់ហើយបន្ទប់ប្រើប្រាស់សរុបចំនួន៣៣៥។ សាលារៀនមានគណៈគ្រប់គ្រងសាលា២៦នាក់ (ស្រី៩នាក់) បុគ្គលិកទី

ចាត់ការ៣៤នាក់ (ស្រី២០នាក់) បណ្ណារក្ស២៥នាក់ (ស្រី១៥នាក់) គ្រូបង្រៀនសុទ្ធសាធ៨៨២នាក់ (ស្រី៣៩៨នាក់) គ្រូជាប់កិច្ចសន្យា១៣នាក់ (ស្រី១០នាក់) គ្រូបឋមសិក្សាទៅបង្រៀននៅមត្តេយ្យ៧នាក់(ស្រី៧នាក់) និងបុគ្គលិកផ្សេងៗ២៥នាក់ (ស្រី៨នាក់)។ ចំណែកគ្រូបង្រៀនថ្នាក់ទី១ដល់ទី៦មានចំនួន៨៣៤នាក់ (ស្រី៣៨៦នាក់)។

***ក.ព័ត៌មានអំពីបុគ្គលិកអប់រំ***

គណៈគ្រប់គ្រងសាលាព្រមទាំងលោកគ្រូ អ្នកគ្រូ ក្នុងសាលាបឋមសិក្សាទាំង១៤បានចូលរួមឆ្លើយសំណួរ និងបំពេញកម្រងសំណួរអំពី ការអនុវត្តគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ។ ការបំពេញកម្រងសំណួរនេះរួមមាន គណៈគ្រប់គ្រងសាលារៀន២៦នាក់(ស្រី៩នាក់) គ្រូបង្រៀន២៧៦នាក់ (ស្រី២២៣នាក់) និងសហគមន៍៨៤នាក់ (ស្រី៧១នាក់)។ លទ្ធផលទទួលបានតាមផ្នែកនីមួយៗមានដូចខាងក្រោមៈ

| លរ | ភេទ | អាយុ | កម្រិតវប្បធម៌ | តួនាទី | បទពិសោធន៍ | ក្របខណ្ឌ |
|---|---|---|---|---|---|---|
| ១ | -៣០២នាក់(ស្រី២៣២) | -តិចជាង៣០ឆ្នាំ:៤៩នាក់(ស្រី៤០)<br>-ចន្លោះ៣០-៤០ឆ្នាំ:១០៨នាក់(ស្រី៨០)<br>-ចន្លោះ៤០-៥០ឆ្នាំ:១០៩នាក់(ស្រី៨៧)<br>-លើសពី៥០ឆ្នាំ:៣៦នាក់(ស្រី២៥) | -ទុតិយភូមិ២១៧នាក់(ស្រី១៩៤)<br>-បរិញ្ញាបត្រ:៦៧នាក់(ស្រី៥៤)<br>-បរិញ្ញាបត្រជាន់ខ្ពស់៣៤នាក់(ស្រី១៣) | -នាយក១៤(ស្រី៤)<br>-នាយករង១២(ស្រី៥)<br>-ប្រធានក្រុមបច្ចេកទេស២២នាក់(ស្រី១៨)<br>-គ្រូបង្រៀន២៥៤នាក់(ស្រី២០៥) | -តិចជាង៥ឆ្នាំ:៥៤នាក់(ស្រី៤១)<br>-ចន្លោះ៥-១០ឆ្នាំ:៥៣នាក់(ស្រី៤១)<br>-លើសពី១០ឆ្នាំ:១៩៨នាក់(ស្រី១៥១) | -បឋមសិក្សា:២៧៤នាក់(ស្រី២១០)<br>-បឋមភូមិ:២៨នាក់(ស្រី២២)<br>គ្រូជាប់កិច្ចសន្យា:១៣នាក់(ស្រី១០) |

តាមរយៈការបំពេញកម្រងសំណួរឱ្យដឹងថាសាលាបឋមសិក្សាទាំង១៤ មានបុគ្គលិកអប់រំសរុប៣០២នាក់(ស្រី២៣២នាក់)។ បុគ្គលិកទាំងនោះអាយុតិចជាង៣០ឆ្នាំមាន៤៩នាក់ (ស្រី៤០នាក់) អាយុ៣០-៤០ឆ្នាំ១០៨នាក់ (ស្រី៨០នាក់) អាយុ៤០-៥០ឆ្នាំ១០៩នាក់ (ស្រី៨៧នាក់) និងលើសពី៥០ឆ្នាំ៣៦នាក់ (ស្រី២៥នាក់)។ ទាក់ទងកម្រិតវប្បធម៌ទុតិយភូមិ២១៧នាក់ (ស្រី១៩៤នាក់) បរិញ្ញាបត្រ៦៧នាក់ (ស្រី៥៤នាក់) និងបរិញ្ញាបត្រជាន់ខ្ពស់៣៤នាក់ (ស្រី១៣នាក់)។ សាលារៀនមាននាយក១៤នាក់ (ស្រី៤នាក់) នាយករង១២នាក់(ស្រី៥នាក់) ប្រធានក្រុមបច្ចេកទេស២២នាក់ (ស្រី១៨នាក់) និងគ្រូបង្រៀន២៥៤នាក់ (ស្រី២០៥នាក់)។ នៅក្នុងចំណោមបុគ្គលិកអប់រំឃើញថា គ្រូបង្រៀនមានបទពិសោធន៍តិចជាង៥ឆ្នាំ៥៤នាក់ (ស្រី៤១នាក់) ចន្លោះ៥-១០ឆ្នាំ៥៣នាក់ (ស្រី៤១នាក់) និងលើសពី

១០ឆ្នាំ១៩៨នាក់ (ស្រី១៥១នាក់)។  គ្រូបង្រៀនមានក្របខណ្ឌជាគ្រូបឋមសិក្សា២៧៩នាក់ (ស្រី២១០នាក់) គ្រូបឋមភូមិ២៨នាក់ (ស្រី២២នាក់) និងគ្រូជាប់កិច្ចសន្យាចំនួន១៣នាក់ (ស្រី១០នាក់)។

***ក.១-សាលាបឋមសិក្សាទាំង១៤អនុវត្តកម្រិតស្តង់ដា***

| លរ | ឈ្មោះសាលា | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | ស្តង់ដាទី៦ | ស្តង់ដាទី៧ | ស្តង់ដាទី៨ | ស្តង់ដាទី៩ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | សាលាទី១ | ២៥% | ៣៥% | ៣០% | ១៥% | ២០% | ២០% | ១៥% | ១៥% | ២៥% |
| ២ | សាលាទី២ | ៥% | ៤% | ៤% | ៤% | ៣% | ៤% | ៣% | ៣% | ៥% |
| ៣ | សាលាទី៣ | ២០% | ២៥% | ២៥% | ១៥% | ២៥% | ២០% | ១៥% | ២៥% | ២៥% |
| ៤ | សាលាទី៤ | ១០% | ១២% | ១៦% | ១២% | ១០% | ១០% | ១០% | ១២% | ១០% |
| ៥ | សាលាទី៥ | ១០% | ៨% | ៦% | ១០% | ១០% | ៦% | ៦% | ៦% | ១០% |
| ៦ | សាលាទី៦ | ១២% | ១៤% | ១៦% | ១២% | ១២% | ១២% | ១២% | ១០% | ១២% |
| ៧ | សាលាទី៧ | ១០% | ៨% | ៦% | ៨% | ១២% | ៦% | ៦% | ១០% | ៤% |
| ៨ | សាលាទី៨ | ៦% | ៨% | ៦% | ៦% | ៧% | ៧% | ៨% | ៦% | ៦% |
| ៩ | សាលាទី៩ | ២០% | ២៥% | ១៥% | ១៥% | ១៥% | ២០% | ១៥% | ១៥% | ១៥% |
| ១០ | សាលាទី១០ | ១០% | ១០% | ១២% | ៨% | ១២% | ១០% | ៨% | ៦% | ៨% |
| ១១ | សាលាទី១១ | ១៤% | ១៨% | ២០% | ១៦% | ២០% | ១៨% | ១២% | ១៤% | ១៦% |
| ១២ | សាលាទី១២ | ៧% | ៧% | ៧% | ៨% | ៥% | ៧% | ៥% | ៦% | ៥% |
| ១៣ | សាលាទី១៣ | ២០% | ២៥% | ២៥% | ១០% | ២៥% | ២៥% | ២០% | ១៥% | ២០% |
| ១៤ | សាលាទី១៤ | ១៦% | ១២% | ១៤% | ១២% | ១៤% | ៨% | ១២% | ១៤% | ៨% |




(រូបភាពទី១៥៖ ភាគរយក្រោបសាលាបឋមសិក្សាទាំង១៤)

នៅក្នុងចំណោមសាលាបឋមសិក្សាទាំង១៤ក្នុងក្រុងសៀមរាប  អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ភាគរយការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សាតាមសាលាខុសៗគ្នា។ នេះជាលំដាប់ភាគរយនៃសាលាបឋមសិក្សាទាំង១៤មានដូចខាងក្រោម៖

| លរ | ឈ្មោះសាលារៀន | ភាគរយ | ផ្សេងៗ |
|---|---|---|---|

| | | | |
|---|---|---|---|
| ១ | បឋមសិក្សាទី១ | ៣៥% | |
| ២ | បឋមសិក្សាទី២ | ៥% | |
| ៣ | បឋមសិក្សាទី៣ | ២៥% | |
| ៤ | បឋមសិក្សាទី៤ | ១៥% | |
| ៥ | បឋមសិក្សាទី៥ | ១០% | |
| ៦ | បឋមសិក្សាទី៦ | ១៥% | |
| ៧ | បឋមសិក្សាទី៧ | ១០% | |
| ៨ | បឋមសិក្សាទី៨ | ៥% | |
| ៩ | បឋមសិក្សាទី៩ | ២៥% | |
| ១០ | បឋមសិក្សាទី១០ | ១០% | |
| ១១ | បឋមសិក្សាទី១១ | ២០% | |
| ១២ | បឋមសិក្សាទី១២ | ៥% | |
| ១៣ | បឋមសិក្សាទី១៣ | ២៥% | |
| ១៤ | បឋមសិក្សាទី១៤ | ១៥% | |

*ក.២-បញ្ហាប្រឈមក្នុងសាលាបឋមសិក្សាទាំង១៤*

សាលារៀនទាំង១៤នៅក្នុងក្រុងសៀមរាប មានបញ្ហាប្រឈមមួយចំនួនទាក់ទងការងារគណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសហគមន៍។ ផលវិបាកទាំងនោះរួមមាន សិស្សមានជម្ងឺប្រចាំកាយ (តេតាណុសឬបេះដូង) សិស្សរៀនយឺត គោលវិធីសិស្សមជ្ឈមណ្ឌល ស្ថានភាពសិស្សក្រីក្រផ្លាស់ទីលំនៅ សិស្សខ្លះមិនចូលរួម មេរៀនខ្លះពិបាករកសម្ភារឧបទេសមកប្រើប្រាស់ ខ្វះអគារសិក្សា បរិក្ខារសាលា សៀវភៅគ្រូ សម្ភារបង្រៀន សិស្សច្រើនមិនមានសម្ភារៈគ្រប់គ្រាន់ ការគ្រប់គ្រងថ្នាក់រៀន។ សាលាមួយចំនួនខ្វះអគារសិក្សាមិនគ្រប់កម្រិតថ្នាក់ ខ្វះសៀវភៅសិក្សាគោល សម្ភារឧបទេសពុំសូវសំបូរ ការដឹកនាំនិងគ្រប់គ្រង សម្ភារបង្រៀន និងរៀនមិនគ្រប់គ្រាន់។ ការមិនសហការមិនសូវមានការចូលរួមផ្តល់ព័ត៌មានត្រឡប់ ខ្វះការចូលរួមថែរក្សាបរិស្ថាន មិនយល់ពីតួនាទី និងកាតព្វកិច្ច។ កង្វះគ្រូក្របខណ្ឌ គ្រូមានជំងឺ សិស្សឈប់ច្រើន (សិស្សក្រីក្រ) បញ្ហាបរិស្ថាន (កាកសំណល់ច្រើន) តុបាក់បែកច្រើន បញ្ហាហិរញ្ញវត្ថុព្រោះ ថវិកាមិនមានគ្រប់គ្រាន់ក្នុងការអភិវឌ្ឍសាលារៀន។ ការខ្វះខាតសម្ភារសិស្ស វិធីសាស្ត្របង្រៀន ពិបាកក្នុងការផលិតសម្ភារឧបទេសក្នុងមេរៀនមួយចំនួនហាត់ក្នុងការបង្រៀនតាមកម្មវិធីថ្មី (ថ្នាក់ទី២)។ អគារមួយខ្នងចាស់ទ្រុឌទ្រោម ត្រៀមជួសជុលនិងកសាងថ្មី ពិបាកបង្រៀន តាមវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល មាតាបិតាសិស្សមិនសូវទំនាក់ទំនងមកសាលារៀន ការដឹកនាំនិងគ្រប់គ្រង មិនសូវមានវិធីសាស្ត្រថ្មី ចែករំលែកដល់គ្រូនៅមានកម្រិត សិស្សខ្សោយ

មករៀនយឺត សម្ភារចាស់ពិបាកប្រើ (តុកៅអីសិស្ស) សម្ភារបង្រៀនមិនទាន់គ្រប់គ្រាន់ការគ្រប់គ្រងរដ្ឋបាលសាលារៀន។ មិនតែប៉ុណ្ណោះ បញ្ហាជីវភាពរស់នៅរបស់សិស្សការផ្លាស់ទីលំនៅ សិស្សបោះបង់ការសិក្សាខ្វះសៀវភៅភាសាខ្មែរថ្នាក់ទីមួយ បង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល បន្ទប់រៀនសិស្សខ្សោយបញ្ញានិងមិនសូវយកចិត្តទុកដាក់រៀន។ ម្យ៉ាងវិញទៀត សិស្សមករៀនមិនទៀងទាត់ អគារនិងបន្ទប់រៀនតូច បន្ទប់ទឹកតូចចង្អៀត ខ្វះសម្ភារឧបទេសដូចជា មេរៀនវិទ្យាសាស្ត្រ និងសិក្សាសង្គម ។ ឪពុកម្តាយមិនសូវយកចិត្តទុកដាក់ក្នុងការសិក្សារបស់កូនកិច្ចការនៅផ្ទះ និងសាលារៀនសិស្សថ្នាក់ទីមួយ ពិបាកនិយាយគ្នាមិនងាយបាន។ វិធីសាស្ត្របង្រៀនថ្មី (IBL) បទពិសោធន៍ការបង្រៀនថ្នាក់ទី៥ ការកំណត់ម៉ោងបង្រៀនមិនបានត្រឹមត្រូវតាមកម្មវិធីសិក្សា ពិបាកក្នុងការណែនាំនិងគ្រប់គ្រងសិស្ស សិស្សច្រើនពេកក្នុងថ្នាក់ សម្ភារខ្លះពិបាករក វិធីសាស្ត្រថ្នាក់ទី១ និងទី២សិស្សចាប់អត់បាន ការប្រើកម្មវិធីអានសរសេរ គ្រូប្រើប្រាស់សកម្មភាពច្រើនសំឡេងខ្លាំងតែសិស្សពុំសូវអនុវត្តតាមសកម្មភាព ខ្វះសម្ភារបង្រៀន វិធីសាស្ត្រច្រើនពិបាកចាប់យក ខ្វះសម្ភារពិសោធន៍ គ្មានអគារទ្រុឌទ្រោម ខ្វះសម្ភារបច្ចេកវិទ្យា គ្រប់គ្រងសំរាមមិនបាន (សាលាអត់មានរបង)។ ការគ្រប់គ្រងរដ្ឋបាលសាលារៀន(ផលវិបាកខ្លះៗ លើតារាងស្ថិតិអគារសិក្សាប្រេះស្រាំ១ខ្នង២ជាន់) កំពុងពិភាក្សាជាមួយក្រសួងនិងមន្ទីរសាងសង់កែលម្អអគារ។ វិធីសាស្ត្របង្រៀនថ្មី សិស្សមួយចំនួនតូចពុំចេះស្រៈនិងព្យញ្ជនៈ សិស្សពុំសូវយកចិត្តទុកដាក់រៀននៅផ្ទះបន្ថែម និងអាណាព្យាបាលសិស្សមួយចំនួនពុំសូវជួយជំរុញកូនឱ្យរៀនបន្ថែមនៅផ្ទះ។ អាណាព្យាបាលសិស្សមួយចំនួនតូច មិនសូវយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន សិស្សចំណាកស្រុកមានការផ្លាស់ប្តូរច្រើន អាជ្ញាធរមិនសូវចូលរួមជាមួយនិងសាលា សិស្សពុំសូវចេះថែរក្សាសៀវភៅសិក្សាគោល និងបង្គន់អនាម័យនៅមានកម្រិត។ ដូច្នេះ សាលាបឋមសិក្សាទី១អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន៣៥%។ សាលាបឋមសិក្សាទី២អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន៥%។ សាលាបឋមសិក្សាទី៣អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន២៥%។ សាលាបឋមសិក្សាទី៤អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន១៥%។ សាលាបឋមសិក្សាទី៥អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន១០%។ សាលាបឋមសិក្សាទី៦អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន១៥%។ សាលាបឋមសិក្សាទី៧អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន១០%។ សាលាបឋមសិក្សាទី៨អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន៥%។ សាលាបឋមសិក្សាទី៩អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន២៥%។ សាលាបឋមសិក្សាទី១០អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន១០%សាលាបឋមសិក្សាទី១១អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន២០%។សាលាបឋមសិក្សាទី១២អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន៥%។ សាលាបឋមសិក្សាទី១៣អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន២៥%។ សាលាបឋមសិក្សាទី១៤អនុវត្តស្តង់ដាសាលាបឋមសិក្សាបាន១៥%។

*ខ.បញ្ហាប្រឈមសាលាបឋមសិក្សាទាំង១៤ទាក់ទងកម្រិតស្តង់ដា*

| លរ | កម្រិតស្តង់ដា | ចំនួនសាលារៀន | ឈ្មោះសាលារៀន |
|---|---|---|---|
| ១ | ស្តង់ដាទី១ | ៣សាលា | បឋមសិក្សាទី៤ ទី៨និងទី១៣ |
| ២ | ស្តង់ដាទី២ | ៣សាលា | បឋមសិក្សាទី៧ ទី១០និងទី១១ |
| ៣ | ស្តង់ដាទី៣ | ៣សាលា | បឋមសិក្សាទី៣ ទី១២និងទី១៣ |
| ៤ | ស្តង់ដាទី៤ | ១៤សាលា | បឋមសិក្សាទី១ដល់ទី១៤ |
| ៥ | ស្តង់ដាទី៥ | ៥សាលា | បឋមសិក្សាទី៣ ទី៦ ទី៧ ទី១០ និងទី១២ |
| ៦ | ស្តង់ដាទី៦ | ១៤សាលា | បឋមសិក្សាទី១ដល់ទី១៤ |
| ៧ | ស្តង់ដាទី៧ | ១៤សាលា | បឋមសិក្សាទី១ដល់ទី១៤ |
| ៨ | ស្តង់ដាទី៨ | ១៤សាលា | បឋមសិក្សាទី១ដល់ទី១៤ |
| ៩ | ស្តង់ដាទី៩ | ១សាលា | បឋមសិក្សាទី៥ |

ជារួមមក សាលាបឋមសិក្សាទាំង១៤ ជួបបញ្ហាប្រឈមទាំង៩នៃស្តង់ដាសាលាបឋមសិក្សា។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាននិងសំណូមពរ

## ៥.១-សេចក្តីសន្និដ្ឋាន

បុគ្គលិកអប់រំទាំងអស់ក្នុងគ្រឹះស្ថានសិក្សា សុទ្ធតែមានកម្រិតវប្បធម៌ និងគុណវុឌ្ឍិគ្រប់គ្រាន់ ទោះបីជាគ្រូជាប់កិច្ចសន្យាក្តី។ លោកគ្រូ អ្នកគ្រូ បានឆ្លងកាត់ការបណ្តុះបណ្តាលនិងវិក្រឹតការ គរុកោសល្យនិងបានចូលរួមរៀនវគ្គបំប៉នផែនការ ការបង្រៀននិងរៀន វិធីសាស្ត្របង្រៀនថ្មីៗថែម ទៀតផង។ ពួកគាត់មានកម្រិតសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិ បរិញ្ញាបត្ររហូតដល់សញ្ញា បត្របរិញ្ញាបត្រជាន់ខ្ពស់។ ទាក់ទងការអនុវត្តការគ្រប់គ្រងសាលារៀន ធៀបទៅនឹងស្តង់ដាសាលា បឋមសិក្សា ករណីសិក្សាសាលាបឋមសិក្សាចំនួន១៤នៅក្នុងក្រុង ខេត្តសៀមរាបវិញ គឺលទ្ធផល ទទួលបានអំពីសាលាបឋមសិក្សាទាំង១៤នៅមានកម្រិតទាបនៅឡើយ(១៥%) នៃការអនុវត្តការងារ គ្រប់គ្រងសាលារៀននិងជួបបញ្ហាប្រឈមនានា។

តាមរយៈសូចនាករទាំង៩ នៃស្តង់ដាសាលាបឋមសិក្សា ធៀបមកការគ្រប់គ្រងសាលារៀន ទាំង១៤ក្នុងក្រុងសៀមរាបបានបង្ហាញឱ្យឃើញអំពីរបកគំហើញដូចខាងក្រោម៖

-សាលាបឋមសិក្សាទី១អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សាបាន៣៥%។

-សាលាបឋមសិក្សាទី៣ ទី៩និងទី១៣អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សាបាន២៥%។

-សាលាបឋមសិក្សាទី១១អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សាបាន២០%។

-សាលាបឋមសិក្សាទី៤ ទី៦និងទី១៤អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សាបាន១៥%។

-សាលាបឋមសិក្សាទី៥ ទី៧ ទី១០អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សាបាន១០%។

-សាលាបឋមសិក្សាទី២ ទី៨និងទី១២អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សាបាន៥%។

សាលានីមួយៗអនុវត្តស្តង់ដាច្រើនជាងគេគឺស្តង់ដាទី១,២,៣,៥,៧,៨ ពីព្រោះក្នុងចំណោមស្តង់ ដាទាំង៦ខាងលើនេះ សាលាមួយចំនួនដំណើរការសាលារៀនស្របតាមកម្មវិធីសិក្សានិងស្តង់ដា សាលាបឋមសិក្សារបស់ក្រសួងនិងការចូលរួមរបស់នាយក គ្រូ សិស្សនិងសហគមន៍។ ចំណែក សាលាអនុវត្តស្តង់ដាតិចជាងគេគឺស្តង់ដាទី៤,៦,៩ ដោយសារសាលារៀនភាគច្រើនមានកង្វះខាត បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ បន្ទប់រៀនភាសាបរទេស។ សាលាគ្មានអាហារូបករណ៍ អាហារពេល ព្រឹក ថ្ងៃត្រង់និងដំណើរទស្សនកិច្ចសិក្សា។ ដោយឡែក បញ្ហាធនធានមនុស្សមិនស្របតាមតម្រូវការ ក្នុងសាលា អាចខ្វះឬលើសពិសេសផ្នែកសិល្បៈតូរ្យតន្ត្រី គំនូរចម្លាក់និងសូនរូប។

ជារួមមក សាលាបឋមសិក្សាទាំង១៤ នៅក្នុងក្រុងសៀមរាបនាឆ្នាំសិក្សា២០១៨-២០១៩នេះ អនុវត្តកម្រិតស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹម១៥%និងមានបញ្ហាប្រឈមជាច្រើនថែមទៀត។ ទាក់ទងបញ្ហាប្រឈមនៅក្នុងសាលារៀនទាំងមូលគឺផ្តោតសំខាន់ទៅលើការដឹកនាំ និងគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលារៀន និយាមបុគ្គលិកអប់រំ ការងារបង្រៀននិងរៀន សៀវភៅសិក្សាគោលគ្រូនិងសិស្ស បរិស្ថាន បង្គន់អនាម័យ បរិក្ខារសាលាហើយសាលាមួយចំនួនតូចមានការចូលរួមកែលម្អនិងអភិវឌ្ឍសាលារៀនតិចតួចពីសហគមន៍។ មិនតែប៉ុណ្ណោះ តាមរយៈការសិក្សាស្រាវជ្រាវដោយការបំពេញកម្រងសំណួរ និងស្ថិតិសាលារៀន ព្រមសំណួរទាក់ទងស្តង់ដាសាលាបឋមសិក្សាពីសំណាក់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសហគមន៍បានឱ្យដឹងអំពីស្ថានភាពទូទៅនៃការអនុវត្តស្តង់ដាសាលារៀនជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា សាលារៀនក្នុងក្រុងសៀមរាបគ្មានប្រាក់អាហារូបករណ៍សម្រាប់សិស្ស ពុំមានអាហារពេលព្រឹក/ថ្ងៃត្រង់ អគារស្នាក់នៅសម្រាប់បុគ្គលិកអប់រំ និងអន្តេវាសិកដ្ឋានសិស្សឡើយ។ សាលារៀនភាគច្រើនមិនមានបន្ទប់រៀនចម្លាក់គំនូរ និងសូនរូប តូរ្យតន្ត្រី កុំព្យូទ័រ ដំណើរទស្សនកិច្ចសិក្សាសម្រាប់គ្រូ និងសិស្សជាដើម។

## ៥.២-សំណូមពរ

បន្ទាប់ពីបញ្ចប់ការសិក្សាស្រាវជ្រាវរួចមក អ្នកសិក្សាយល់ឃើញថា ការអនុវត្តការងារគ្រប់គ្រងសាលារៀនធៀប នឹងស្តង់ដាសាលាបឋមសិក្សាទាំង១៤ក្នុងក្រុងសៀមរាប មានភាពខ្វះខាតនិងជួបបញ្ហាប្រឈមមួយចំនួន មិនបានឆ្លើយតបទៅនឹងស្តង់ដាទាំង៩ នៃសាលាបឋមសិក្សារបស់ក្រសួងអប់រំឡើយ។ ដើម្បីធានាឱ្យមានដំណើរការល្អ ក្នុងការអនុវត្តស្តង់ដាសាលាបឋមសិក្សាប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិនោះ គួរតែអ្នកពាក់ព័ន្ធចូលរួមការងារនេះទាំងអស់គ្នា តាមរយៈ

-នាយកសាលាត្រូវផ្សព្វផ្សាយដល់បុគ្គលិកក្នុងសាលារៀន ឱ្យយល់ដឹងអំពីការអនុវត្តស្តង់ដាសាលាបឋមសិក្សាឱ្យមានប្រសិទ្ធភាព។ស្តង់ដានេះចែកចេញជា៣ប្រភេទនិង៩ស្តង់ដា។(១)គោលនយោបាយសាលារៀនមានប្រសិទ្ធភាព (វត្ថុបំណងគោលនយោបាយរបស់សាលារៀនៈ ចូលរៀនតាមថ្នាក់ត្រួតថ្នាក់ បោះបង់ ឡើងថ្នាក់ លទ្ធផលតេស្តមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា សមត្ថភាពអានភាសាខ្មែរ ថ្នាក់ទី៣ និងទី៦ លទ្ធផលវាយតម្លៃសូចនាករ ធៀបនឹងសូចនាករស្តង់ដាសាលាមានប្រសិទ្ធភាព)។ (២)សាលារៀនប្រើធាតុចូល (ការបង្រៀននិងបំណែងចែកកម្មវិធីបង្រៀនរបស់គ្រូ

មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ សិស្សនិងសេវាជួយសិស្ស ការដឹកនាំនិងការគ្រប់គ្រង)។ (៣)ថ្នាក់ជាតិផលិត និងផ្តល់ធាតុចូល (ធនធានមនុស្ស សម្ភារបង្រៀននិងរៀន ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន ការគ្រប់គ្រងហិរញ្ញវត្ថុ)។

-ការិយាល័យអប់រំ យុវជននិងកីឡាស្រុក ក្រុង ត្រូវប្រជុំគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនណែនាំឱ្យអនុវត្តកម្មវិធីសិក្សាស្របតាមស្តង់ដាសាលាបឋមសិក្សា។

-មន្ទីរអប់រំខេត្ត ពិសេសការិយាល័យបឋមសិក្សា ជាការិយាល័យជំនាញ ត្រូវរៀបចំកម្មវិធីលម្អិតលើការដឹកនាំនិងគ្រប់គ្រង ការបង្រៀននិងរៀន បរិស្ថានសាលា ការប្រើប្រាស់ថវិកា កម្មវិធីសិក្សាដល់គណៈគ្រប់គ្រងសាលារៀន រួមជាមួយការិយាល័យអធិការកិច្ច និងការិយាល័យអប់រំស្រុក ក្រុង និងការិយាល័យពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើឱ្យសម្រេចបាននូវស្តង់ដាសាលាបឋមសិក្សានេះ។

-សហគមន៍ អង្គការដៃគូ សប្បុរសជនជាតិ អន្តរជាតិ និងអាជ្ញាធរមូលដ្ឋាន មានភារកិច្ចក្នុងការរួមចំណែកជួយដល់ការកែលម្អ និងអភិវឌ្ឍសាលារៀន ឱ្យមានភាពស្រស់បំព្រងជាសាលាកុមារមេត្រី ឬសាលាបៃតង។

# ឯកសារយោង

-ក្រសួងអប់រំ យុវជន និងកីឡា (២០០៧) កម្មវិធីសាលាកុមារមេត្រី ក្រុមប្រឹក្សាកុមារ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១២) ខ្លឹមសារសង្ខេបសម្រាប់ជំនួយគណៈគ្រប់គ្រងសាលារៀន

-ក្រសួងអប់រំ យុវជន និងកីឡា (២០១២) គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១២) គោលនយោបាយស្តីពីសាលាកុមារមេត្រី ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៤-២០១៨) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ ភ្នំពេញ

-ក្រសួងអប់រំ យុវជននិងកីឡា (២០១៦)សេចក្តីណែនាំស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) សៀវភៅស្តង់ដាសាលាបឋមសិក្សា ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) ស្តង់ដានាយកសាលារៀន ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) បណ្ណព័ត៌មានសាលារៀន ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) វិធីសាស្ត្របង្រៀន ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) គោលនយោបាយនិងនីតិវិធីគ្រប់គ្រងសាលារៀនសម្រាប់បឋមសិក្សា ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ប្រកាសស្តីពីការបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនៅវិទ្យាស្ថានជាតិអប់រំ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងសាលារៀន

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំយុវជននិងកីឡា ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) និយាមក្នុងការប្រើប្រាស់បុគ្គលិកអប់រំ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៨-២០១៩) ស្ថិតិនិងសូចនាករអប់រំសាធារណៈ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ជំនាញសតវត្សទី២១ ភ្នំពេញ

-ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) សៀវភៅផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ ភ្នំពេញ
- ជួន ណាត (១៩៦៧) វចនានុក្រមខ្មែរ ភ្នំពេញ
-រដ្ឋសភា (១៩៩៣) ច្បាប់រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ភ្នំពេញ
-រដ្ឋសភា (១៩៩៤) ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ភ្នំពេញ
-កែវ ចាន់ណា និងញ៉ែម ចាន់ (២០១០) ជំនាញនៃការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ ភ្នំពេញ
-វិទ្យាល័យហ៊ុនសែនស្វាយធំ (២០១៦-២០១៧) ការគ្រប់គ្រងនិងដឹកនាំនៅវិទ្យាល័យហ៊ុនសែន ស្វាយធំ សៀមរាប
-សាលាបឋមសិក្សាបន្ទាយឈើ (២០១៧-២០១៨) ការគ្រប់គ្រងនិងដឹកនាំនៅសាលាបឋមសិក្សា បន្ទាយឈើ សៀមរាប
-សាលាបឋមសិក្សាមុខនាគ (២០១៨-២០១៩) ការគ្រប់គ្រងនិងដឹកនាំនៅសាលាបឋមសិក្សាមុខនាគ សៀមរាប
-ស៊ឹម វិសុទ្ធ (២០១៧) មេរៀនការគ្រប់គ្រងសាលារៀន
-ចំណេះដឹងទូទៅ (២០១៧) តើការគ្រប់គ្រងគឺជាអ្វី? ភ្នំពេញ
-គណៈរដ្ឋមន្ត្រី (២០១៨) សារលិខិតសម្តេចតេជោហ៊ុនសែនថ្ងៃបើកបវេសនកាល ភ្នំពេញ
- គួយ សូគាន (២០១៨) មេរៀនការគ្រប់គ្រងសាលារៀន
-សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងសេដ្ឋកិច្ច (២០១៨) គោលការណ៍គ្រឹះនៃការគ្រប់គ្រង ភ្នំពេញ
-គណៈរដ្ឋមន្ត្រី (២០១៩) សទ្ទានុក្រមគោលនយោបាយជាតិស្តីពីភាសាខ្មែរ ភ្នំពេញ
-គណៈរដ្ឋមន្ត្រី (២០១៩) សារលិខិតសម្តេចតេជោហ៊ុនសែនថ្ងៃបើកបវេសនកាល ភ្នំពេញ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៣ ២០១៥ និង២០១៩ ប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ ចំណាយសម្រាប់អនុវត្តកម្មវិធីថវិកានៅក្រសួងអប់រំ យុវជន និងកីឡា
-តាន់ មុន្នីវិសាលា (២០១៩) បដិវត្តឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤0) ភ្នំពេញ
- ហាង់ ជួនណារ៉ុន (២០១៩) ការកសាងចំណេះដឹងក្នុងយុគសម័យឌីជីថល ភ្នំពេញ
- ហ្វូ ឈុនគ្រី (២០១៩) មេរៀនក្រមសីលធម៌វិជ្ជាជីវៈនាយកសាលារៀន
- សៀង សុវណ្ណា (២០១៩) មេរៀនការអនុវត្តនិងកែលម្អកម្មវិធីសិក្សា
- នូវ វីរ៉ា (២០១៩) មេរៀនឧត្តមភាពបុគ្គល

- ស៊ិន សេងហុក (២០១៩) មេរៀនទស្សនវិជ្ជាអប់រំ
- ថៅ សារ៉ាត់ហ៊ុំ (២០១៩) មេរៀនគោលការណ៍អភិវឌ្ឍអប់រំនិងការវាយតម្លៃ
- បាន គនហេង (២០១៩) មេរៀនការលើកកម្ពស់ការទទួលខុសត្រូវចំពោះសាលារៀន
- ហ៊ុន ម៉ានី (២០១៩) ស្ថានភាពអប់រំក្នុងបរិបទកម្ពុជា
-UNESCO2003: Ministry of planning(2003) Cambodia Millennium Development Goals Report2003
-Brian J.Caldwell(2005) (School-based management UNESCO,Paris,p11)

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

# កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន
# សាលាបឋមសិក្សា.......................................

ខ្ញុំបាទឈ្មោះ **គោគ ស៊ីថន** ជានិស្សិតវគ្គឯកទេសនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ នៃវិទ្យាស្ថានជាតិអប់រំ។ សព្វថ្ងៃនេះ ខ្ញុំបាទកំពុងសរសេរនិក្ខេបបទអំពី «ការអនុវត្តការគ្រប់គ្រងសាលារៀនធៀបនឹងស្តង់ដាសាលាបឋមសិក្សា»។ ការស្រាវជ្រាវនេះជាផ្នែកមួយនៃនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ។ រាល់ព័ត៌មានដែលទទួលបានត្រូវរក្សាការសម្ងាត់និងប្រើប្រាស់សម្រាប់តែការស្រាវជ្រាវប៉ុណ្ណោះ។

សូមថ្លែងអំណរគុណទុកជាមុនសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកនាយកនាយករងនៅក្នុងការបំពេញកម្រងសំណួរនេះ។

សូមអរគុណ

## I.ផ្នែកទី១៖ ព័ត៌មានទូទៅ

សូមគូសសញ្ញា☑ក្នុងប្រអប់ខាងក្រោម៖

១.ភេទ: □ប្រុស □ស្រី

២អាយុ: □តិចជាង៣០ឆ្នាំ □ចន្លោះ៣០ទៅ៤០ឆ្នាំ □ចន្លោះ៤០ទៅ៥០ឆ្នាំ □លើសពី៥០ឆ្នាំ

៣.កម្រិតវប្បធម៌: □ក្រោមបរិញ្ញាបត្រ □បរិញ្ញាបត្រ □បរិញ្ញាបត្រជាន់ខ្ពស់ □បណ្ឌិត

៤.តួនាទីសព្វថ្ងៃ: □នាយក □នាយករង

៥.បទពិសោធន៍ការងារ: □តិចជាង៥ឆ្នាំ □ចន្លោះពី៥ទៅ១០ឆ្នាំ □លើសពី១០ឆ្នាំ

៦.តើអ្នកធ្លាប់បានទទួលការបណ្តុះបណ្តាលឬវិក្រឹតការលើផ្នែករៀបចំផែនការនិងដឹកនាំការរៀននិងបង្រៀនពីមុនមកដែរឬទេ? □បាទ/ចាស □ទេ (បើធ្លាប់សូមរៀបរាប់ត្រួសៗ)

..........................................................................................................................................

..........................................................................................................................................

ក្នុងផ្នែកទី២និងទី៣ខាងក្រោម សូមលោក លោកស្រីឆ្លើយនឹងកម្រងសំណួរដោយគូស☑ទៅតាមកម្រិតសមត្ថភាពឬការបំពេញការងារជាក់ស្តែងរបស់លោក លោកស្រី។

**សម្គាល់៖** ១.តិចតួចណាស់ ២.តិចតួច ៣.មធ្យម ៤.ច្រើន ៥.ច្រើនណាស់

**II.ផ្នែកទី២៖ ស្តង់ដាសាលាបឋមសិក្សា**

| ល.រ | **១.វត្ថុបំណងគោលនយោបាយសាលារៀន** | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| ១ | តើការចូលរៀន សិស្សឡើងថ្នាក់ និងបោះបង់ការសិក្សាកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ២ | តើលទ្ធផលតេស្តមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១ដល់ទី៦បានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៣ | តើលទ្ធផលតេស្តមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១ដល់ទី៦បានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៤ | តើលទ្ធផលតេស្តសមត្ថភាពអានភាសាខ្មែរ ថ្នាក់ទី៣ និងទី៦បានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៥ | តើលទ្ធផលតេស្តសមត្ថភាពការអនុវត្តលេខនព្វន្ត ថ្នាក់ទី៣និងទី៦បានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| | **២.បំណែងចែកកម្មវិធីនិងការបង្រៀនរៀន** | 1 | 2 | 3 | 4 | 5 |
| ១ | តើបំណែងចែកកម្មវិធីបង្រៀន និង កិច្ចតែងការបង្រៀនរបស់គ្រូអនុវត្តបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ២ | តើតេស្តល្បឿនអំណានភាសាខ្មែរ តេស្តសរសេរតាមអាន តេស្តសំណេរតែងសេចក្តីថ្នាក់ទី៣ដល់ទី៦ទទួលលទ្ធផលកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៣ | តើតេស្តគណិតវិទ្យាគ្រប់កម្រិតថ្នាក់ លទ្ធផលប្រឡងឆមាសលើមុខវិជ្ជាគោល តេស្តឡើងថ្នាក់សម្រាប់សិស្សធ្លាក់មធ្យមភាគកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៤ | ការជួបជាមួយមាតាបិតាសិស្សនិងសិស្សប្រចាំត្រីមាសបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៥ | តើចំនួនម៉ោងសិក្សាបានបង្រៀនតាមកាលវិភាគ វត្តមានសិស្ស និងកិច្ចការផ្ទះដាក់ឱ្យសិស្ស និងមានការកែពីគ្រូបានលទ្ធផលកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៦ | តើការប្រើប្រាស់សៀវភៅតាមដានការសិក្សា និងសៀវភៅទំនាក់ទំនងមាតាបិតាសិស្សអនុវត្តបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៧ | តើការសិក្សាស្រាវជ្រាវមេរៀន ដោយក្រុមបច្ចេកទេសអនុវត្តបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៨ | តើកម្មវិធីណែនាំគ្រូចេញថ្មីនិងគ្រូកិច្ចសន្យាអនុវត្តបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៩ | តើរដ្ឋបាលថ្នាក់អនុវត្តបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ១០ | តើសកម្មភាពអប់រំកាយនិងកីឡា សុខភាព និងបំណិនជីវិតមូលដ្ឋានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | **៣.ការងារមាតាបិតាសិស្សនិងសហគមន៍** | 1 | 2 | 3 | 4 | 5 |
| ១ | តើការជួបប្រជុំពិគ្រោះយោបល់រវាងមាតាបិតាសិស្ស គ្រូបង្រៀននិងសិស្ស មាតាបិតា/ អាណាព្យាបាលសិស្សសន្យាជួយសិស្សដែលមករៀនមិនទៀងទាត់ និងមិនទាន់ពេល ហើយជួយតាមដានការសិក្សារបស់កូនបានជោគជ័យកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ២ | តើការបង្កើត និង ដំណើរការរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអាជ្ញាធរមូលដ្ឋានមានការចូលរួមកិច្ចការសាលារៀនកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| | **៤.សិស្សនិងសេវាជួយសិស្ស** | 1 | 2 | 3 | 4 | 5 |
| ១ | នៅក្នុងសាលារៀន តើសិស្សប្រើប្រាស់បណ្ណាល័យបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ២ | នៅក្នុងសាលារៀន តើសិស្សប្រើបន្ទប់ពិសោធន៍បានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៣ | នៅក្នុងសាលារៀន តើសិស្សប្រើប្រាស់បន្ទប់រៀនភាសាបរទេសនិងកុំព្យូទ័របានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៤ | តើថ្នាក់ដែលមានក្រុមសិស្សជួយគ្នា និងសាលាមានក្រុមប្រឹក្សាកុមារ និងប្រឹក្សាកុមារី ការគាំទ្រសិស្សខ្សោយគំហើញ និងសិស្សខ្សោយស្តាប់ ព្រមទាំងលទ្ធផលសិក្សាសិស្សខ្សោយគំហើញ និងខ្សោយស្តាប់បានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៥ | តើសិស្សទទួលបានអាហារូបករណ៍ អាហារពេលព្រឹក /ថ្ងៃត្រង់ ការអនុវត្តកម្មវិធីលើកកម្ពស់ដល់សុខភាពសិក្សា និងទស្សនកិច្ចសិក្សាសម្រាប់គ្រូបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| | **៥.ការដឹកនាំនិងគ្រប់គ្រង** | 1 | 2 | 3 | 4 | 5 |
| ១ | តើការគ្រប់គ្រង និងដំណើរការរដ្ឋបាលសាលារៀនព្រមទាំងផែនការអភិវឌ្ឍសាលារៀនអនុវត្តបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ២ | តើការប្រជុំរបស់សាលារៀន ការងារអធិការកិច្ចថ្នាក់រៀននិងការវាយតម្លៃប្រចាំឆ្នាំ លើការអនុវត្តការងាររបស់គ្រូបង្រៀនបានកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| ៣ | តើប្រសិទ្ធភាពនៃការអនុវត្តសាលាកុមារមេត្រី និងការទប់ស្កាត់បាតុភាពមិនប្រក្រតីក្នុងសាលាបានលទ្ធផលកម្រិតណា? | ☐ | ☐ | ☐ | ☐ | ☐ |
| | **៦.ធនធានមនុស្សនិងរចនាសម្ព័ន្ធគ្រប់គ្រង** | 1 | 2 | 3 | 4 | 5 |

| | | | | | | |
|---|---|---|---|---|---|---|
| ១<br>២ | តើគណៈគ្រប់គ្រងសាលារៀន មានគុណវុឌ្ឍិ និងសមត្ថភាពពេញលេញកម្រិតណា?<br>តើគុណវុឌ្ឍិគ្រូបង្រៀន និងការប្រើប្រាស់គ្រូបង្រៀនក្នុងសាលា សមស្របដល់កម្រិតណា? | ☐<br>☐ | ☐<br>☐ | ☐<br>☐ | ☐<br>☐ | ☐<br>☐ |
| | **៧.កម្មវិធីសិក្សានិងសម្ភារបង្រៀននិងរៀន** | 1 | 2 | 3 | 4 | 5 |
| ១<br>២<br>៣ | តាមរយៈកម្មវិធីសិក្សាមុខវិជ្ជាគោល ស្ថានភាពសៀវភៅសិក្សាគោល សៀវភៅគ្រូ សម្ភារឧបទេសតើសាលាបានប្រើប្រាស់អនុវត្តកម្រិតណា?<br>តើបណ្ណាល័យ បន្ទប់រៀនភាសាបរទេស បន្ទប់ពិសោធន៍ បន្ទប់រោងជាង បន្ទប់រៀនកសិកម្មដំណើរការបានដល់កម្រិតណា?<br>តើបន្ទប់រៀនសិល្បៈ និងតូរ្យតន្ត្រី បន្ទប់រៀនចម្លាក់គំនូរ និងសូនរូប បន្ទប់រៀនគេហកិច្ច បន្ទប់រៀនកុំព្យូទ័រ កីឡា និងសកម្មភាពនៅក្នុងសាលារៀនប្រើប្រាស់គ្រប់គ្រាន់ដល់កម្រិតណា? | ☐<br>☐<br>☐ | ☐<br>☐<br>☐ | ☐<br>☐<br>☐ | ☐<br>☐<br>☐ | ☐<br>☐<br>☐ |
| | **៨.ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន** | 1 | 2 | 3 | 4 | 5 |
| ១<br>២<br>៣ | តើអគារសិក្សានិងបន្ទប់រៀនគ្រប់គ្រាន់ដល់កម្រិតណា?<br>តើសាលាមានអគារស្នាក់នៅសម្រាប់បុគ្គលិក និង អន្តេវាសិកដ្ឋានសិស្សកម្រិតណា?<br>តើសាលាមានសម្ភារបរិក្ខារ និងការផ្គត់ផ្គង់ ព្រមទាំងបរិស្ថានសាលារៀនកម្រិតណា? | ☐<br>☐<br>☐ | ☐<br>☐<br>☐ | ☐<br>☐<br>☐ | ☐<br>☐<br>☐ | ☐<br>☐<br>☐ |
| | **៩.ការគ្រប់គ្រងហិរញ្ញវត្ថុ** | 1 | 2 | 3 | 4 | 5 |
| ១<br>២ | តើការគ្រោងនិងទទួលថវិកាសមស្របដំណើរការសាលាកម្រិតណា?<br>តើការចំណាយថវិកាប្រចាំឆ្នាំទទួលបានកម្រិតណា? | ☐<br>☐ | ☐<br>☐ | ☐<br>☐ | ☐<br>☐ | ☐<br>☐ |

**III.ផ្នែកទី៣៖ ការគ្រប់គ្រងសាលារៀន**

១-ចក្ខុវិស័យ បេសកកម្ម ☐មាន ☐គ្មាន

២-ការគ្រប់គ្រងលិខិតរដ្ឋបាល ☐សមស្រប ☐មិនសមស្រប

៣-រចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន ☐មាន ☐គ្មាន

